ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ដើម្បីស្វែងរកការពិតនិងយុត្តិធម៌
- អង្គការសហប្រជាជាតិព្រមព្រៀងចំពោះកម្ពុជា

លេខ៣៧ ខែមករា ឆ្នាំ២០០៣

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤១ ខែឧសភា ឆ្នាំ២០០៣

## មាតិកា

◆ សំបុត្រៈ ដើម្បីស្វែងរកការពិតនិងយុត្តិធម៌.......................... ១

**ផ្នែកឯកសារ**

◆ ស៊ាន អានៈ ជីវិតនៅក្នុងតម្លៀបបដិវត្តន៍.............................. ៣

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស........................................ ៦

◆ ទូរលេខ ៩៤ៈ គោរពជូនបង ប៉ុល ជាទីគោរព..................... ៧

◆ អត្ថន័យនៃធាតុឈានមុខ................................................. ៩

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មិនមានប្រយោជន៍អ្វីទាំងអស់សម្រាប់ខ្លួនខ្ញុំ........................ ១២

◆ ជម្លោះរវាងចិននិងកម្ពុជាក្នុងរវាងឆ្នាំ១៩៧០-១៩៧៥ ........ ១៤

**ផ្នែកច្បាប់**

◆ សុក្រឹតភាពគឺជាសត្រូវនៃយុត្តិធម៌.................................... ៣៦

◆ អង្គការសហប្រជាជាតិព្រមព្រៀងជាមួយកម្ពុជា.................... ៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ សម្រង់កិច្ចសម្ភាសន៍ជាមួយលោក កូហ្វី អាណាន់................ ៤០

◆ ជនរងគ្រោះនៃរបបខ្មែរក្រហម........................................ ៤២

◆ សុន្ទរកថារបស់ប្រទេសហុល្លង់អំពីតុលាការខ្មែរក្រហម........... ៥១

◆ សុន្ទរកថារបស់ប្រទេសស៊ុយអែដអំពីតុលាការខ្មែរក្រហម........ ៥២

◆ ជប៉ុនៈ ការសញ្ជឹងគិតរបស់ខ្ញុំទៅលើបញ្ហាខ្មែរក្រហម............ ៥៣

**ទំព័រស្វែងរកគ្រួសារ**

◆ ឃើញតែរូបថត........................................................ ៥៦

◆ សិទ្ធិដែលបាត់បង់...................................................... ៥៨



រូបថតដោយៈ ហេង ស៊ីនិត

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះៈ** សុខ វណ្ណៈ, ផាត របនា, នង ឧត្តតារា, ឃិន នាន, ដួង សុភារិទ្ធ, ហ្គោតារ៉ូ អូហ្កាវ៉ា, ហ្រ្គេហ្គោរី ស្តេនតុន, ឈាំង ចៃ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សើ សាយព្យាណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ដើម្បីស្វែងរកការពិតនិងយុត្តិធម៌

អស់ជាច្រើនឆ្នាំមកហើយដែលប្រជាជនកម្ពុជារង់ចាំយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយរបបខ្មែរក្រហមដែលបានគ្រប់គ្រងប្រទេសកម្ពុជារវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ការរំលោភរបស់កម្ពុជាប្រជា-ធិបតេយ្យ បានតាមបន្តជាឧបសគ្គដល់ការអភិវឌ្ឍន៍ប្រទេសនិងអន្ទោលតាមប្រាណរបស់បុគ្គលនិងសមាជិកគ្រួសាររងគ្រោះគ្រប់ៗរូប ។ ចាប់តាំងពីចាប់បដិសន្ធិនៅឆ្នាំ១៩៩៥មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំស្វែងរកការពិត និងការទទួលខុសត្រូវទាក់ទងនឹងសម័យខ្មែរក្រហមជាប់ជាប្រចាំ ។ ជារឿយៗដំណើរការស្វែងរកការពិតនិងការដាក់ឲ្យទទួលខុសត្រូវនេះបានជួបប្រទះនូវការលំបាកមិនចេះចប់មិនចេះហើយ ក៏ប៉ុន្តែដោយប្រជាជនកម្ពុជានិងសមាជិកសហគមន៍អន្តរជាតិដែលពាក់ព័ន្ធធ្វើការរួមគ្នានាំឲ្យយើងសម្រេចបាននូវសមិទ្ធផលដ៏សំខាន់ឈានទៅរកយុត្តិធម៌នៅកម្ពុជា ។ ចុងបញ្ចប់ ការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់បានលេចចេញជារូបរាងពិតប្រាកដហើយ ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចសេចក្តីព្រាងកិច្ចព្រមព្រៀងរួមគ្នាមួយឈានទៅបង្កើតបានអង្គជំនុំជម្រះវិសាមញ្ញដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភដ៏ធ្ងន់ធ្ងរនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ នៅថ្ងៃទី២ ខែឧសភា គណៈកម្មាធិការទីបីនៃអង្គការសហប្រជាជាតិបានអនុម័តសេចក្តីព្រាងកិច្ចព្រមព្រៀងដោយមតិឯកច្ឆ័ន្ទ ។ នៅថ្ងៃទី១៣ ខែឧសភា មហាសន្និបាតអង្គការសហប្រជាជាតិដែលមានប្រទេសជាសមាជិកចំនួន១៩១ បានអនុម័តជាឯកច្ឆ័ន្ទនូវសេចក្តីសម្រេចដែលផ្តុកទៅដោយសេចក្តីព្រាងកិច្ចព្រមព្រៀង ។ ចំណែកឯសហរដ្ឋអាមេរិកនៅតែផ្តល់កិច្ចគាំទ្រខាងការទូតចំពោះតុលាការនេះទោះជាបង្កើតនៅពេលណាក៏ដោយ ។

សភាជាតិកម្ពុជាត្រូវបានរំពឹងយ៉ាងមុតមាំថា នឹងអនុម័តសេចក្តីព្រាងនាពេលឆាប់ៗខាងមុខ ។ ការវិវត្តន៍ទៅមុខទាំងនេះគឺជាជំហានដ៏សំខាន់នៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយនិងលំបាកលំបិនក្នុងការដោះស្រាយអតីតកាលប្រកបដោយសោកនាដកម្ម ។ ជំហានដ៏សំខាន់ៗទាំងនេះបង្ហាញអំពីឆន្ទៈរបស់អន្តរជាតិ និងកម្ពុជា ដើម្បីបញ្ចប់និទណ្ឌភាព និងជួយឲ្យកម្ពុជាធ្វើដំណើរឆ្ពោះទៅមុខទៅរកអនាគតកាន់តែភ្លឺថ្លា និងកាន់តែសម្បូររុងរឿង ។ ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងស្វាគមន៍ចំពោះការរីកចម្រើនទៅមុខដែលសម្រេចបាននៅប៉ុន្មានខែថ្មីៗនេះ ហើយសូមជម្រុញឲ្យមានការបន្តកិច្ចសហប្រតិបត្តិការតទៅមុខទៀតរវាងកម្ពុជានិងអន្តរជាតិ ។

ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះបុគ្គលនិងអង្គការជាច្រើនដែលបានធ្វើឲ្យមានការរីកចម្រើនទៅមុខបែបនេះ ។ ដើម្បីជម្នះបាននូវនិទណ្ឌភាពនេះគឺត្រូវទាមទារភាពក្លាហាន ការលះបង់ និងធនធាន ។ រដ្ឋាភិបាលនិងបុគ្គលជាច្រើនបាននាំគ្នាជម្រុញឲ្យមានយុត្តិធម៌នៅកម្ពុជា ហើយជាលទ្ធផលកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនិងបុគ្គលទាំងនោះបានសម្រេចផលជាផ្លែផ្កាពិតប្រាកដមែន ។ មានបុគ្គលជាច្រើនសម្រេចជ្រើសរើសយកការគាំទ្រដល់ការពិត និងការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់តាមរយៈការជួយជ្រោមជ្រែងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះសមានចិត្តបែបនេះ ។ ចាប់តាំងពីឆ្នាំ១៩៩៥មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនូវគុណប្រយោជន៍ពីក្រុមអ្នកស្ម័គ្រចិត្ត ទីប្រឹក្សាជំនាញៗ និងបណ្តាប្រទេសផ្តល់ជំនួយនានា ។ យើងក៏បានទទួលផ្លែផ្កាពីកិច្ចសហការជាមួយរាជរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលដែលមានសមានចិត្តដូចគ្នា ហើយនិងមានគោលដៅរួមគ្នាក្នុងការសម្រេចឲ្យបាននូវយុត្តិធម៌នៅកម្ពុជា ។ បើគ្មានការគាំទ្រប្រកបដោយសប្បុរសខាងហិរញ្ញវត្ថុ គតិយុត្តិ ប្រវត្តិសាស្ត្រ និងបច្ចេកទេស ម៉្លេះសមយើងមិនអាចទទួលផ្លែផ្កាដូចពេលនេះឡើយ ។

ប្រការនេះក៏ដូចអង្គតុលាការដែលនឹងចេញជារូបរាងនាពេលខាងមុខនេះដែរ ។ កិច្ចព្រមព្រៀងដែលអនុម័តដោយគណៈកម្មការទីបីរបស់អង្គការសហប្រជាជាតិ គឺជាការចាប់ផ្តើមដ៏សំខាន់ ប៉ុន្តែកិច្ចព្រមព្រៀងនេះ មិនអាចធានាបាននូវជោគជ័យរបស់អង្គតុលាការ ក្នុងការផ្តល់នូវយុត្តិធម៌អាចជឿទុកចិត្តបានដែលប្រជាជនកម្ពុជាសមនឹងទទួលបាននោះទេ ។ ការព្រួយបារម្ភចម្បងៗនៅតែមានទាក់ទងនឹងឆន្ទៈនយោបាយ ដែលជាកត្តាកំណត់ដើម្បីធានាថា តុលាការពិតជាគួរឲ្យទុកចិត្តបាន ។ តុលាការមួយដែលទទួលបានជោគជ័យ គឺតម្រូវឲ្យមានការបន្តចូលរួមពីសំណាក់ប្រជាជននិងក្រុមបុគ្គលក្នុងស្រុកនិងអន្តរជាតិ តាមរយៈការចូលរួមដោយផ្ទាល់និងការរិះគន់ប្រកបដោយន័យស្ថាបនា ។ បណ្តាមិត្តទាំងឡាយដែលបានជួយឲ្យដំណើរការឈានដល់ចំណុចបច្ចុប្បន្ននេះត្រូវតែចូលរួមបន្តទៅទៀត ដើម្បីចូលរួមស្វែងរកយុត្តិធម៌ និងចាំឃ្លាំមើលដំណើរការនៃអង្គតុលាការចាប់ទាំងពីដើមរហូតដល់ទីបញ្ចប់ ។ ការគាំទ្រខាងហិរញ្ញវត្ថុ គតិយុត្តិ និងខាងបច្ចេកទេសគឺជាការសំខាន់ណាស់ ។ ចំណែកឯការផ្សព្វផ្សាយពត៌មានអំពីសកម្មភាពរបស់តុលាការដល់អ្នកស្តាប់ និងទស្សនិកជនជាតិ និងអន្តរជាតិក៏មានសារសំខាន់ដូចគ្នាដែរ ។ រដ្ឋាភិបាលនានា អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយសុទ្ធតែមានជំនាញផ្សេងៗគ្នាដើម្បីរួមចំណែកក្នុងដំណើរការនេះ ។ ដោយរួបរួមគ្នាជាធ្លុងមួយ យើងអាចធានាបានថាយុត្តិធម៌ពិតជាសម្រេចបាន ហើយតុលាការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមពិតជាជម្រុញឲ្យមានការផ្សះផ្សាជាតិនិងធម្មាធិបតេយ្យនៅប្រទេសកម្ពុជានិងនៅក្រៅប្រទេស ។

ចំណុចចុងក្រោយមួយទៀតគឺថា ទោះបីជាតុលាការខ្មែរក្រហមជាជំហានដ៏សំខាន់ឆ្ពោះទៅរកយុត្តិធម៌ ការចងចាំ និងការផ្សះផ្សាជាតិក៏ដោយ ក៏នៅតែមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ការដោះស្រាយនូវកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម គឺជាដំណើរការដ៏វែងឆ្ងាយនៅកម្ពុជា ។ ដំណើរការដ៏វែងឆ្ងាយនេះទាក់ទងដល់ការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ការពង្រឹងនូវលទ្ធិប្រជា-ធិបតេយ្យ និងការអប់រំយុវវ័យជំនាន់ក្រោយ និងតម្រូវឲ្យមានការផ្សះរបួសផ្លូវចិត្តនិងការអត់ឱននៅក្នុងបណ្តាសហគមន៍ដែរ ។ តុលាការនឹងគាំទ្រដល់ដំណើរការទាំងនេះ ប៉ុន្តែតុលាការនឹងមិនលុបចោលនូវតម្រូវការចាំបាច់របស់សហគមន៍ឡើយ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលទាំងឡាយដែលខិតខំធ្វើការរៀងរាល់ថ្ងៃក្នុងការនាំយកនូវទស្សនវិស័យនៃការផ្សះផ្សានៅកម្ពុជា ។ ខ្ញុំមានសង្ឃឹមថា ប្រជាជនកម្ពុជានិងសមាជិកនៅក្នុងសហគមន៍អន្តរជាតិដែលពាក់ព័ន្ធនឹងជួយប្រទេសកម្ពុជាផ្សះរបួសនិងមានការអភិវឌ្ឍន៍យ៉ាងរឹងមាំនៅពេលអនាគត ។

**ឆាំង យុ**



*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ស៊ាន អាន: ជីវិតនៅក្នុងគន្លងបដិវត្តន៍



ស៊ាន អាន មុនឆ្នាំ១៩៧៥

ស៊ាន អាន ជាអតីតឯកអគ្គរដ្ឋទូតរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំនៅទីក្រុងហាណូយ ប្រទេសវៀតណាម ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ ស៊ាន អាន ត្រូវអង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ ជាទីកន្លែងដែលគាត់ត្រូវសួរចម្លើយនិងសម្លាប់ចោល ។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ស៊ាន អាន ÷

ស៊ាន អាន មានកំណើតនៅឃុំក្បាលរមាស ស្រុកកំពត ខេត្តកំពត ឪពុកឈ្មោះ ហួត ស៊ាន ម្តាយឈ្មោះ ចេវ ហៀង និងម្តាយចុងឈ្មោះ អ៊ំ ជាកសិករនៅឃុំក្បាលរមាស ស្រុកកំពត ខេត្តកំពត ។

ស៊ាន អាន ជានិស្សិតសាលាស្ថិតិនៅទីក្រុងប៉ារីស ប្រទេសបារាំង ។ នៅឆ្នាំ១៩៥១ ស៊ាន អាន ចូលរួមជាមួយបក្សកុម្មុយនិស្តបារាំង ក្នុងទិសដៅរួមកម្លាំងប្រឆាំងនាយទុនអាណានិគមនិយមបារាំង ។ ឆ្នាំ១៩៥៤ ស៊ាន អាន វិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយក៏បានចូលរួមក្នុងចលនាឥស្សរៈនៅខេត្តកំពត ។

ខែកក្កដា ឆ្នាំ១៩៥៤ សង្គ្រាមនៅប្រទេសកម្ពុជាបានផ្អាកតាមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ ស៊ាន អាន បានធ្វើជាអ្នកបកប្រែភាសាក្នុងគណៈកម្មការអន្តរជាតិត្រួតពិនិត្យកិច្ចព្រមព្រៀងហ្សឺណែវ ។ អ្នកបកប្រែក្នុងគណៈកម្មការនោះមាន៦នាក់៖ តំណាងរាជរដ្ឋាភិបាល៣នាក់ មានឈ្មោះ អ៊ុច អ៊ុំ (ប៉ូលិស) កា ទិត (យោធា) កា ម៉ែល (គ្រូបង្រៀន) និងតំណាងចលនាតស៊ូឥស្សរៈ ៣នាក់ មានឈ្មោះ កែវ មាស, ជី គឹមអាន, ស៊ាន អាន។ ក្រោយមក ជី គឹមអាន និង កែវ មាស លាឈប់ទៅធ្វើសារព័ត៌មាន "ប្រជាជន" និងឈរជាបេក្ខភាពបោះឆ្នោតតំណាងរាស្ត្រ ឯខាងរដ្ឋាភិបាលក៏ដកចេញ២នាក់ គឺឈ្មោះ កា ទិត និង កា ម៉ែល ។ ដូច្នេះខាងឥស្សរៈនៅសល់តែ ស៊ាន អាន និងខាងរដ្ឋាភិបាលនៅសល់តែ អ៊ុច អ៊ុំ ប៉ុណ្ណោះ ។ ក្នុងពេលជាមួយគ្នានោះ ស៊ាន អាន ក៏ឆ្លៀតទៅបង្រៀននៅសាលាឯកជនចំរើនវិជ្ជា និងជួយសរសេរអត្ថបទឲ្យកាសែត "ប្រជាជន" ។ នៅឆ្នាំ១៩៦៥ សាលាចំរើនវិជ្ជាត្រូវបិទ ។ ឆ្នាំ១៩៦៦ គណៈកម្មការអន្តរជាតិត្រួតពិនិត្យកិច្ចព្រមព្រៀងហ្សឺណែវបានបញ្ចប់អាណត្តិរបស់ខ្លួន ។ ស៊ាន អាន រកបានការងារថ្មីនៅឆ្នាំ១៩៦៧ គឺជាអ្នកលក់ដូរ បន្ទាប់មកក្លាយជាអ្នកត្រួតពិនិត្យ និងជាចាងហ្វាងរងនៅក្នុងរដ្ឋាភណ្ឌាគារ ដែលមាន ចៅ សេង ជាអ្នកទទួលខុសត្រូវទី១ និង ខែក វ៉ាន់ឌី ជាអ្នកទទួលខុសត្រូវទី២ ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៨ ស៊ាន អាន បានភៀសខ្លួនទៅរស់នៅប្រទេសបារាំងក្រោមរូបភាពទៅធ្វើទស្សនកិច្ចនៅប្រទេសប៉ូឡូញ អាល្លឺម៉ង់ខាងកើត និងឆេកូស្លូវ៉ាគី ។ ស៊ាន អាន បានរំឭកថា មុនពេលភៀសខ្លួនទៅបរទេស បក្សបានហៅគាត់ចូលព្រៃដែរ ប៉ុន្តែដោយគាត់មានទស្សនៈមិនដាច់ខាត ម្យ៉ាងដោយសុខភាពរបស់គាត់មិនសូវល្អ និងម្យ៉ាងដោយមើលសភាពការណ៍មិនច្បាស់ ទើបគាត់សម្រេចចិត្តមិនចូលរួមក្នុងចលនាតស៊ូអាវុធនៅក្នុងព្រៃឡើយ ។

នៅទីក្រុងប៉ារីស ស៊ាន អាន ស្នាក់នៅផ្ទះជាមួយជនជាតិបារាំងម្នាក់ឈ្មោះ ហង់រី វ៉ាន់ឌី គើមរទេ ដែលធ្លាប់ស្គាល់គ្នាកាលនៅជានិស្សិត ។ រស់នៅប្រទេសបារាំងដំបូង ស៊ាន អាន ជួបនឹងការលំបាកខ្លះៗ ព្រោះមិនទាន់មានការងារធ្វើ ចង់ត្រឡប់មកភ្នំពេញវិញក៏មិនហ៊ាន ព្រោះ ប៉េងសៃ ដែលទើបនឹងធ្វើដំណើរពីទីក្រុងភ្នំពេញទៅដល់ប៉ារីស បានប្រាប់ថា អង្គការមិនទាន់អនុញ្ញាតឲ្យ ស៊ាន អាន ត្រឡប់ចូលប្រទេសកម្ពុជាវិញទេ ព្រោះខ្លាចរដ្ឋាភិបាលចាប់ខ្លួន ។ ស៊ាន អាន ក៏បើកផ្ទះលក់

សៀវភៅមួយជាមួយដើមទុនចំនួន ១១០០០០ហ្វ្រង់ (ប្រាក់បារាំង) ។ គាត់ជួនពេលជាមួយគ្នានោះ តាមការឧទ្ទេសនាមពីមិត្តម្នាក់របស់ ជួន ប្រាសិទ្ធិ, ស៊ាន អាន ក៏រកបានការងារធ្វើក្នុងក្រុមហ៊ុនដឹកជញ្ជូនមួយនៅទីក្រុងប៉ារីសឈ្មោះ កាលប៉ែរសុន ។

ខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីឮដំណឹងអំពីរដ្ឋប្រហារនៅភ្នំពេញ ស៊ាន អាន ឃើញថាជាឱកាសល្អសម្រាប់គាំទ្រសម្តេចសីហនុ ដែលខ្លួនធ្លាប់ចាត់ទុកជាមនុស្សកណ្តាល ។ នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧០ ស៊ាន អាន, ជួន មុំ និង ចៅ សេង ក៏បានស្រុះស្រួលគ្នាព្រមធ្វើដំណើរមកទីក្រុងប៉េកាំងដើម្បីចូលរួមក្នុងសកម្មភាពបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ។ នៅចុងខែមេសា ឆ្នាំ១៩៧០ រណសិរ្សរួបរួមជាតិកម្ពុជាប្រកាសបង្កើតជារូបរាង ។ ក្រោយពីបង្កើតបានរណសិរ្សហើយ ស៊ាន អាន បានបន្តជួយដោះស្រាយបង្កើតគណៈរដ្ឋមន្ត្រីរួបរួមជាតិទៀត ដោយរៀបចំសមាសភាពតាមទូរលេខណែនាំរបស់ ខៀវ សំផន ។

នៅដើមខែឧសភា ឆ្នាំ១៩៧០ កែវ មាស បានប្រគល់ការងារមួយឲ្យ ស៊ាន អាន គឺធ្វើយ៉ាងណាឲ្យការិយាល័យនយោបាយរណសិរ្សយល់ព្រមបន្ថែមសមាសភាពគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា១០រូបទៀត មានតំណាងនារី យុវជន កម្មករ កសិករ កវី ជនជាតិឥស្លាម ថៃ អ្នកនិពន្ធ និងបន្ថែមអនុរដ្ឋមន្ត្រីខ្លះទៀតដូចជាខាងអប់រំ ហិរញ្ញវត្ថុ ឃោសនា យោធា មហាផ្ទៃ និង កសិកម្ម ។ ស៊ាន អាន បានទទួលការងារនេះយកទៅអនុវត្តរហូតបានសម្រេចលទ្ធផល ។ បន្ទាប់ពីនោះមក ស៊ាន អាន បានព្យាយាមរកតួនាទីមួយសម្រាប់ខ្លួនឯង ។ ខាងរណសិរ្សក៏ប្រគល់តួនាទីឲ្យ ស៊ាន អាន ជាលេខាទូតនៅហាណូយ ចំណែក កែ មាស ជាទូតនៅប៉េកាំងផងនៅហាណូយផង ។ ស៊ាន អាន បានតវ៉ាថែមទៀតរហូតបានទទួលតួនាទីជាឯកអគ្គរដ្ឋទូតរណសិរ្សប្រចាំនៅទីក្រុងហាណូយ ។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ ស៊ាន អាន បានចេញដំណើរពីប៉េកាំងទៅហាណូយ ដើម្បីបំពេញភារកិច្ចជាឯកអគ្គរដ្ឋទូតរបស់រដ្ឋាភិបាលរណសិរ្សប្រចាំនៅទីក្រុងហាណូយប្រទេសវៀតណាម ។ នៅហាណូយ ស៊ាន អាន ជួបប្រទះការស្មុគស្មាញខ្លាំងណាស់ ព្រោះគាត់គ្មានបទពិសោធន៍ខាងការងារទូត ។ ស៊ាន អាន ស្នើសុំជួប កែវ មាស ប៉ុន្តែ កែវ មាស មិនព្រមជួបគាត់ឡើយ ដោយយកលេសថា អគ្គការមិនឲ្យជួប ។ ស៊ាន អាន ជួបការស្មុគស្មាញកាន់តែខ្លាំងឡើងៗ ម្យ៉ាងក្តាប់ចលនាតស៊ូនៅក្នុងប្រទេសមិនបាន ហើយម្យ៉ាងទៀតជនកម្ពុជាគ្រប់គ្នាគេចមុខមិនព្រមជួបទៀត មានតែខាងក្រសួងការបរទេសនិងខាងប៉េសេ (រដ្ឋាភិបាល) វៀតណាមប៉ុណ្ណោះ ដែលមកទាក់ទងជាមួយ ស៊ាន អាន ។ ទំនាក់ទំនងរវាងរដ្ឋាភិបាលរណសិរ្សនិងវៀតណាមនៅក្នុងឆ្នាំ១៩៧០-៧១ មានភាពកក់ក្តៅនិងស្និទ្ធស្នាល ។ ស៊ាន អាន និយាយថា វៀតណាមយកចិត្តទុកដាក់នឹងខ្លួនហួសពីក្របខ័ណ្ឌនៃពិធីការទូតទៅទៀត ។ ពេលខ្លះ ផាំ វ៉ាន់ដុង ចូលមកអង្គុយលេងនៅបន្ទប់ទទួលភ្ញៀវរបស់ស្ថានទូតរណសិរ្សនៅថ្ងៃបុណ្យចូលឆ្នាំសកល ។ ផាំ វ៉ាន់ដុង មកស្ថានទូតដោយខ្លួនឯងដើម្បីសរសើរនិងជូនពរថ្ងៃបុណ្យឯករាជ្យ ៩ វិច្ឆិកា ។ ពេលខ្លះ ង្វៀង យុយទ្រិញ និងគ្រួសារ បានមកហូបបាយជាគ្រួសារនៅស្ថានទូតខ្មែរ ។

នៅពីដើមឆ្នាំ១៩៧១ ស៊ាន អាន បានទទួលភារៈសំខាន់មួយគឺ សម្របសម្រួលជាមួយវៀតណាមដើម្បីឲ្យវៀតណាមយល់ព្រមជួយដឹកអាវុធឲ្យកម្លាំងតស៊ូនៅក្នុងព្រៃនៃប្រទេសកម្ពុជា ។ ពាក់កណ្តាលឆ្នាំ១៩៧២ ការចរចារវាងវៀតណាមនិងចក្រពត្តិអាមេរិកមានតម្រុយថា នឹងអាចឈានដល់ភាពត្រូវរ៉ូវគ្នាឆាប់ៗ ប៉ុន្តែកម្ពុជាសុខចិត្តបន្តវាយតទៅទៀត ។ ដូច្នេះទំនាក់ទំនងរវាងប្រទេសទាំងពីរមានភាពល្អក់កករខ្លះ ។ ចាប់ពីចុងឆ្នាំ១៩៧២ ទំនាក់ទំនងរវាងរដ្ឋាភិបាលរណសិរ្សនិងវៀតណាមមានសភាពតឹងតែងទាំងរូបភាពនិងខ្លឹមសារ ។ ភាពតានតឹងនេះបានឈានដល់ចំណុចកំពូលនៅពេលដែលមានទំនាស់រឿងកោះវៃ និងរឿងព្រំដែន ។

ថ្ងៃទី២៧ មករា ឆ្នាំ១៩៧៣ វៀតណាមនិងចក្រពត្តិអាមេរិកចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាមនៅវៀតណាម ។ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំដដែល សាមនឿ និង វៀងច័ន្ទ ព្រមចុះហត្ថលេខាលើបទឈប់បាញ់និងបង្កើតគណៈរដ្ឋមន្ត្រីចម្រុះលាវ ។ ចំណែកកម្ពុជាប្រកាសមិនព្រមចរចា ហើយនៅ

តែបន្តការតស៊ូប្រដាប់អាវុធ ។ ទំនាក់ទំនងរវាងវៀតណាមនិងរដ្ឋាភិបាលរណសិរ្សរឹតតែល្អក់កករខ្លាំងឡើងៗ ។ វៀតណាមបានផ្សាយពត៌មានមិនល្អពីរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដូចជាថា "មានការប្រជុំគ្នារវាងប្រទេសឥណ្ឌូចិននៅទីក្រុងព្រៃនគរដើម្បីពិភាក្សាបញ្ហាសហព័ន្ធឥណ្ឌូចិន" "រដ្ឋាភិបាលកម្ពុជាបង្ខំឲ្យនិស្សិតកម្ពុជាលែងប្រពន្ធវៀតណាម" "កម្ពុជាបណ្តេញជនជាតិវៀត-ណាមចេញពីកម្ពុជា" ជាដើម ។ សកលលោកស្ទើរតែទាំងមូលបានដាក់ការគាបសង្កត់លើរដ្ឋាភិបាលរណសិរ្ស ។ ទាំងអស់នេះធ្វើឲ្យ ស៊ាន អាន មានការលំបាកក្នុងការពន្យល់អន្តរជាតិឲ្យយល់អំពីមូលហេតុដែលកម្ពុជាត្រូវធ្វើសង្រ្គាមរំដោះជាតិណាស់ ។ ភាពស្មុគស្មាញជាច្រើនធ្វើឲ្យ ស៊ាន អាន ស្ទើរតែដាក់ពាក្យសុំលាឈប់ពីមុខតំណែង ។

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ កម្លាំងខ្មែរក្រហមវាយសម្រុកខ្លាំងទូទាំងប្រទេស ។ ទូតបរទេសនានាសម្រុកមករកពត៌មានពីទូតរណសិរ្សនៅហាណូយ ប៉ុន្តែ ស៊ាន អាន គេចខ្លួនទៅប៉េកាំងរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលកងកម្លាំងប្រដាប់អាវុធខ្មែរក្រហមវាយកាន់កាប់បានទីក្រុងភ្នំពេញ ។ ចាប់ពីខែ៦-៧ ឆ្នាំ១៩៧៥ មានលេចព្រឿងវៀតណាមឈ្លានពានចូលទឹកដីកម្ពុជា ។ ចាប់តាំងពីពេលនោះមក ស្ថានទូតរណសិរ្សប្រចាំនៅហាណូយបានទទួលការគាបសង្កត់យ៉ាងខ្លាំងពីអាជ្ញាធរវៀតណាម ។

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៥ ស៊ាន អាន បានចាកចេញពីហាណូយត្រឡប់មកកម្ពុជាវិញ ដោយឆ្លងកាត់តាមទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដើម្បីជូនដំណើរគណៈប្រតិភូឡាវដែលមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ ។

## ចម្លើយសារភាពរបស់ ស៊ាន អាន

ឯកសារចម្លើយសារភាពរបស់ ស៊ាន អាន ចែកជាពីរផ្នែក ÷ ផ្នែកទីមួយមានចំនួន២៥ទំព័រ និយាយអំពីឪពុកម្តាយបងប្អូន និងប្រវត្តិការងាររបស់ ស៊ាន អាន ពីឆ្នាំ១៩៥១ដល់ឆ្នាំ១៩៧៥ ។ ឯកសារនេះសរសេរមិនទាន់ចប់ និងមិនមានហត្ថលេខាឬកាលបរិច្ឆេទអ្វីទាំងអស់ ។ នៅផ្នែកខាងមុខមានសរសេរថា "ចម្លើយ ស៊ាន អាន, វៀតណាម, បរទេស" និងមានក្រដាសមួយសន្លឹកទៀតក៏បដាប់ពីលើសរសេរថា " S-១៦៣, ស៊ាន អាន ទូតនៅហាណូយ, ២៥-២-៧៨" ។ ឯកសារមួយផ្នែកទៀតមានចំនួន២៦ទំព័រ និយាយអំពីការបង្កើតបក្សមួយទៀតនៅហាណូយ និងប្រវត្តិសកម្មភាពរបស់ ស៊ាន អាន ។ ឯកសារផ្នែកនេះក៏សរសេរមិនទាន់ចប់ ប៉ុន្តែមានហត្ថលេខារបស់ ស៊ាន អាន និងចុះកាលបរិច្ឆេទពីថ្ងៃទី ១៦ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៧ ។ នៅក្នុង"បញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេច" ដែលរៀបចំដោយមន្ទីរស-២១ មិនមានឈ្មោះ ស៊ាន អាន ទេ ប៉ុន្តែមានឈ្មោះ ព្រំ សៀង ប្រពន្ធរបស់ ស៊ាន អាន ត្រូវចាប់ខ្លួនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៦ និងកម្ទេចថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ។

## ប្រវត្តិរូបសង្ខេប

- ◆ ឈ្មោះ ស៊ាន អាន អាយុ៥១ឆ្នាំ (ឆ្នាំ១៩៧៧)
- ◆ ឪពុកឈ្មោះ ហួត ស៊ាន
- ◆ ម្តាយឈ្មោះ ចេវ ហៀង
- ◆ ម្តាយចុងឈ្មោះ អ៊ីវ ទាំងអស់គ្នាជាកសិករនៅឃុំក្បាលរមាស ស្រុកកំពត ខេត្តកំពត ។
- ◆ មានបងប្អូន៩នាក់ ស្រី៥នាក់ ប្រុស៤នាក់ ។
- ◆ ប្រពន្ធឈ្មោះ ព្រំ សៀង មុនបដិវត្តន៍ជាសាស្ត្រាចារ្យ
- ◆ មានកូន៥នាក់ ប្រុស៤នាក់ ស្រី១នាក់ ។ កូនច្បង៣នាក់ធ្វើការនៅកងចល័តភូមិភាគពាយ័ព្យ ។ កូនទី៤និងទី៥រស់នៅឯបរទេស ។
- ◆ មុនឆ្នាំ១៩៥៤ រៀនសាលាស្ថិតិនៅទីក្រុងប៉ារីស
- ◆ ឆ្នាំ១៩៥៤ វិលត្រឡប់មកប្រទេសកម្ពុជាវិញ និងចូលរួមក្នុងចលនាឥស្សរៈនៅខេត្តកំពត ។
- ◆ ឆ្នាំ១៩៥៤ ធ្វើជាអ្នកបកប្រែនៅក្នុងគណៈកម្មការអន្តរជាតិត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងហ្សឺណែវ ។
- ◆ ឆ្នាំ១៩៦៧ ធ្វើការនៅរដ្ឋភណ្ឌាគារ
- ◆ ឆ្នាំ១៩៦៨ ភៀសខ្លួនទៅរស់នៅប្រទេសបារាំង
- ◆ ឆ្នាំ១៩៧០ ចូលរួមបង្កើតរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង ។
- ◆ ខែឧសភា ឆ្នាំ១៩៧០ ធ្វើជាឯកអគ្គរដ្ឋទូតរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅទីក្រុងហាណូយ ។ **សាន់ កល្យាណ**

# បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

*(តពីលេខមុន)*

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ៣៤៥ | ត្រឹន វ៉ិនទី ហ ញ៉ៅ | យួន | អនុសេនីយ៍ផ្កាយ២ | តំបន់២៤ | ?-១-៧៨ | ២៧-៣-៧៨ |
| ៣៤៦ | ង្វៀង មិញតឹម | យួន | ពលបាលផ្កាយ១ | តាកែវ | ២-១-៧៨ | ២៧-៣-៧៨ |
| ៣៤៧ | ង្វៀង ធីវើ (ស) | យួន | ចារនារី | ស្វាយរៀង | ២៨-១-៧៨ | ២៧-៣-៧៨ |
| ៣៤៨ | ឡេ វ៉ាន់យូ ហ យុង | យួន | ពលទោផ្កាយ២ | ស្វាយរៀង | ? | ២៧-៣-៧៨ |
| ៣៤៩ | ផាប់ វ៉ាន់ថូង | យួន | សក្តិ២ចារបុរស | ស្វាយរៀង | ១៤-២-៧៨ | ២៧-៣-៧៨ |
| ៣៥០ | ដូ វ៉ាន់ស៊ិន់ | យួន | សក្តិ២ចារបុរស | ស្វាយរៀង | ?-២-៧៨ | ២៧-៣-៧៨ |
| ៣៥១ | ដាំង វ៉ិនខឹយ | យួន | ផ្កាយ៣ | សមុទ្រកម្ពុជា | ១៣-២-៧៨ | ២៧-៣-៧៨ |
| ៣៥២ | ត្រិន វ៉ិនហ៊ុង | យួន | ចារបុរស | សមុទ្រកម្ពុជា | ១១-២-៧៨ | ២៧-៣-៧៨ |
| ៣៥៣ | ទ្រឿង វ៉ាន់ថាញ់ | យួន | ចារបុរស | សមុទ្រកម្ពុជា | ១៤-២-៧៨ | ២៧-៣-៧៨ |
| ៣៥៤ | ទៀវ ឡុក | យួន | ពលបាលផ្កាយ១ | សមុទ្រកម្ពុជា | ?-២-៧៨ | ២៧-៣-៧៨ |
| ៣៥៥ | ឡេ វ៉ាន់សឺន | យួន | ចារបុរស | តាកែវ | ?-១-៧៨ | ២៧-៣-៧៨ |
| ៣៥៦ | លឿង មិញទន់ហា យ | យួន | ចារបុរស | សមុទ្រកម្ពុជា | ១៦-២-៧៨ | ២៧-៣-៧៨ |
| ៣៥៧ | ផាប់ ទេព | យួន | ចារបុរស | សមុទ្រកម្ពុជា | ១៤-២-៧៨ | ២៧-៣-៧៨ |
| ៣៥៨ | សំ គីម | យួន | អនុសេនីយ៍ផ្កាយ២ | សមុទ្រកម្ពុជា | ២១-២-៧៨ | ២៧-៣-៧៨ |
| ៣៥៩ | ឡឹម ទី | យួន | ? | សមុទ្រកម្ពុជា | ២១-២-៧៨ | ២៧-៣-៧៨ |
| ៣៦០ | ត្រិន វ៉ា | យួន | ? | សមុទ្រកម្ពុជា | ២១-២-៧៨ | ២៧-៣-៧៨ |
| ៣៦១ | ទ្រិញ វ៉ុកហួ | យួន | ? | សមុទ្រកម្ពុជា | ២១-២-៧៨ | ២៧-៣-៧៨ |
| ៣៦២ | លូវ វ៉ាក់សួង | យួន | ? | សមុទ្រកម្ពុជា | ២១-២-៧៨ | ២៧-៣-៧៨ |
| ៣៦៣ | ង្វៀង វ៉ាន់រ៉ូ | យួន | ឈ្លប | សមុទ្រកម្ពុជា | ២៤-២-៧៨ | ២៧-៣-៧៨ |
| ៣៦៤ | គីម ភួង | ? | ចារបុរស | ស្វាយរៀង | ៣-៣-៧៨ | ២៧-៣-៧៨ |
| ៣៦៥ | គីម អែម (ស) | ? | ចារបុរស | ស្វាយរៀង | ៣-៣-៧៨ | ២៧-៣-៧៨ |
| ៣៦៦ | ង្វៀង វ៉ាន់សយ | យួន | ចារបុរស | ស្វាយរៀង | ៣-៣-៧៨ | ២៧-៣-៧៨ |
| ៣៦៧ | ឡេ វ៉ាន់ភិប | យួន | ធ្វើស្រែ | កំពង់ចាម | ១៤-៣-៧៨ | ២៧-៣-៧៨ |
| ៣៦៨ | ឡេ វ៉ាន់ហាយ | យួន | ធ្វើស្រែ | កំពង់ចាម | ១៤-៣-៧៨ | ២៧-៣-៧៨ |
| ៣៦៩ | ង្វៀង វ៉ាន់ធី | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៩-៥-៧៨ | ១០-៦-៧៨ |
| ៣៧០ | ង្វៀង វ៉ាន់លន់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៩-៥-៧៨ | ១០-៦-៧៨ |
| ៣៧១ | ត្រិន ង៉ុកតឿង | យួន | ចារកិច្ចយួន | ត្បូងឃ្មុំ | ៣-៥-៧៨ | ១០-៦-៧៨ |
| ៣៧២ | ទាង មិញខា | យួន | ចារកិច្ចយួន | ត្បូងឃ្មុំ | ២៧-៤-៧៨ | ១០-៦-៧៨ |
| ៣៧៣ | ង្វៀង ផាញ់កាង | យួន | ចារកិច្ចយួន | កំពង់សោម | ២០-៣-៧៨ | ១០-៦-៧៨ |

(នៅមានត)

# សូមគោរពជូនបង ប៉ុល ជាទីគោរព

## ឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ទូរលេខៈ ៩៤, ១១០០ខ្ទង់

ខ្ញុំសូមរាយការណ៍ជូនបងអំពីសភាពការណ៍ខ្មាំង សភាពការណ៍មហាជន និងសភាពការណ៍បង្កបង្កើនផល នៅភូមិភាគឧត្តរ មានដូចតទៅ÷

១) សភាពការណ៍ខ្មាំងនៅភូមិភាគឧត្តរទាំងមូល ជាមូលដ្ឋានខ្មាំងមិនទាន់មានធ្វើសកម្មភាពអ្វីខ្លាំងដែលនាំឱយប៉ះពាល់ប្រជាជនក៏ដូចជាចលនាបង្កបង្កើនផលទេ ជារួម សភាពការណ៍នឹងនរតែទន្ទឹមនឹងនេះវាក៏មានធ្វើសកម្មភាពខ្លះៗដែរ ដូចជាវាឃោសនាថា បដិវត្តមានការតឹងតែង វាឃោសនាទប់ទល់សហករណ៍ ឃោសនាទប់ទល់នឹងការលើកប្រព័ន្ធភ្លឺស្រែថ្មី ក៏ដូចជាឃោសនាអំពីការអត់ឃ្លាន ជាក់ស្តែងគឺមានបាតុភាពលេចឡើងនៅស្រុកចំការលើ ពួកអាខ្មាំងជាទាហានចាស់ រួមផ្សំជាមួយពួកចាមនិងពួកអតីតប្រធានក្រុមសហករណ៍ បានយករូបថតអាណុលនិងសេចក្តីថ្លែងការណ៍របស់អាណុលនៅថ្ងៃ ១៨-៣-៧០ ទៅបិទនឹងដើមឈើនៅក្បែរភូមិត្រពាំងក្រញោ ស្រុកចំការលើ និងសកម្មភាពខ្លះទៀតវាដើរអុជព្រៃបំផ្លាញដំណាំ ជាចេក ជាខ្នុរ ។ល ។

សភាពការណ៍ខ្មាំងខាងលើនេះ វិធានការរបស់ភូមិភាគបានណែនាំទៅខាងតំបន់ឱយយកចិត្តទុកដាក់តាមដានសកម្មភាពនេះ ក្នុងការតាមដានសកម្មភាពនេះទៀតជាក់ស្តែងយើងចាប់បានពួកអាសមាសភាពជាអតីតប្រធានក្រុមសហករណ៍ចាស់ ។

ជាមួយនេះទៀត វាមានខ្សែបង្កប់នៅក្នុងផ្ទៃក្នុង យើងបានតាមដានពិនិត្យតទៅទៀត ឃើញសកម្មភាពយ៉ាងណា យើងនឹងមានវិធានការតាមការជាក់ស្តែងថែមទៀត ។

២) សភាពការណ៍មហាជន ជារួមប្រជាជនចាស់និងប្រជាជនថ្មីមានជំនឿជឿជាក់លើបក្សដឹកនាំ ជានយោបាយក៏ដូចជាសតិអារម្មណ៍និងការចាត់តាំងជាក់ស្តែង បងប្អូនទូទាំងភូមិភាគទាំងចាស់ ទាំងថ្មី កំពុងតែវាយសម្រុកយ៉ាងសស្រាក់សស្រាំលើកប្រព័ន្ធភ្លឺស្រែថ្មីតាមទិសដែលអង្គការលើកឡើង ព្រមជាមួយគ្នានេះក៏មានការសាមគ្គីជិតស្និទ្ធជួយខបត្តម្ភគ្នាទៅវិញទៅមក ទាំងស្បៀងទាំងជម្រករស់នៅ ។

◆ តែការលំបាករបស់ប្រជាជននៅភូមិភាគឧត្តរទាំងមូលមានការគ្រុនក្តៅចុកពោកជាច្រើនដែរ ។

◆ មូលហេតុគឺមកពីធ្វើការក្តៅពេក បងប្អូនហូបទឹកត្រជាក់មិនបានហូបទឹកក្តៅឱយទៀងទាត់ ។

◆ វិធានការបានលើកគោលការណ៍បន្ថយពេលវេលាធ្វើការតាមទិសដែលបក្សកំណត់ ព្រមទាំងបំផុសការអប់រំសតិអារម្មណ៍នយោបាយ ឱយបងប្អូនប្រុងប្រយ័ត្នប្រើទឹកក្តៅថែមទៀត ។

៣) បញ្ហាចលនាបង្កបង្កើនផលនៅក្នុងភូមិភាគឧត្តរទាំងមូលបានលើកៈ

◆ ទិសវាយសម្រុកធ្វើស្រែដើមឆ្នាំយ៉ាងសស្រាក់សស្រាំនៅតំបន់ទាំង... កំពុងតែវាយសម្រុកសាបស្រូវដើមឆ្នាំ ដើមឆ្នាំនេះសាបទៀត ដែលមានសំណាបសាបពីមុនមកបានស្ទូងខ្លះៗ ហើយនៅស្រុកស្ទឹងត្រង់ ស្រុកចំការលើ ស្រុកបារាយណ៍ កំពុងតែវាយសម្រុកដកស្ទូងជាបន្តបន្ទាប់ ហើយសំណាបនិងសន្ទូងដើមឆ្នាំនេះតាមពត៌មានមានការលូតលាស់ល្អ ។

◆ បញ្ហាប្រព័ន្ធភ្លឺស្រែ កំពុងតែវាយសម្រុកលើកប្រព័ន្ធភ្លឺស្រែនេះយ៉ាងខ្លាំងក្លា ចំនួនដូចបានជំរាបថ្ងៃមុន ៦ខាងក្រោយមកទៀតមិនទាន់បានសរុបទេ តាមការវិភាគ ស្រែ៣០ភាគរយនេះដាច់ខាតពិតជាយកជ័យជម្នះបាន ។

◆ កំពុងតែវាយសម្រុកធ្វើទ្វារទឹកនៅតាមប្រព័ន្ធភ្លឺស្រែប្រឡាយទឹក ធ្វើជាស៊ីម៉ង់តិ៍ក៏មាន ធ្វើជាឈើក៏មាន ។

◆ កំពុងតែសម្រុកប្រមូលជីយ៉ាងសស្រាក់សស្រាំដែរដោយប្រុងប្រយ័ត្នយកតាមទិសនិងផែនការរបស់បក្សឲ្យបាន ។

◆ កំពុងវាយសម្រុកភ្ជួរស្រែក្រោមយ៉ាងខ្លាំងដែរ ជាស្រែរបស់សហករណ៍និងជាស្រែរដ្ឋ ។

យោលទៅលើសភាពការណ៍បង្កបង្កើនផលយ៉ាងសស្រាក់សស្រាំនេះ តាមខ្ញុំវិភាគគឺកំណត់ជាយកជ័យជម្នះតាមផែនការរបស់បក្ស ។

◆ ការលំបាកក្នុងចលនាបង្កបង្កើនផលនេះ តាមពិនិត្យ

សភាពការណ៍ទូទៅដែលចោទចំពោះមុខគឺ ÷

◆ ឧបករណ៍ប្រើប្រាស់ខាងមធ្យោបាយផលិតកម្ម គោ-ក្របីមានកើតជំងឺអាសន្នរោគ អុតក្តាម ស្លាប់គ្រប់តំបន់នៅខាងវាលស្រែក្រោមក៏មានស្លាប់ច្រើន បញ្ហានេះដែលនាំឲ្យប៉ះពាល់ដល់ចលនាបង្កបង្កើនផល ពិសេសក្នុងការវាយសម្រុកភ្ជួរស្រែក្រោមនេះដែរ ។ វិធានការបានរៀបចំទស្សនៈនិងគោលជំហរ ដោយវាយសម្រុកចាត់ចែងកម្លាំងឧបករណ៍នេះ ដោយប្រមូលលើកកម្លាំងឧបករណ៍នេះវាយសម្រុកកន្លែងមួយៗ ព្រមទាំងសម្រុកដោះស្រាយថ្នាំព្យាបាលជំងឺអាសន្នរោគ គោក្របីនេះឱយបានសកម្មខ្លាំងក្លាថែមទៀត ។

ទន្ទឹមនឹងនេះទៀត សម្រេចឱយសមមិត្តយើងតាមមូលដ្ឋានធ្វើស្ថិតិក្របីគោនេះឱយច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការក្តាប់និងចាត់ចែងប្រើប្រាស់ ។

◆ បញ្ហាចាត់តាំងកម្លាំងដឹកនាំនៅភូមិភាគ បានរៀបចំចាត់តាំងគណៈបញ្ឈាការដឹកនាំបង្កបង្កើនផលខាងលើ គឺគណៈភូមិភាគដែលទទួលខុសត្រូវរួម គិតគូរខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង តាមដានគ្រប់សកម្មភាពទាំងអស់ ប្រជុំដកពិសោធន៍លើបញ្ហានេះ ដោយកំណត់៨ថ្ងៃប្រជុំដកពិសោធន៍ម្តង ។

◆ នៅគណៈតំបន់ក៏រៀបចំគណៈបញ្ឈាការដឹកនាំបង្កបង្កើនផល ។

◆ នៅស្រុកក៏មានការរៀបចំជាគណៈបញ្ឈាការដឹកនាំប្រយុទ្ធផ្ទាល់ដែរ ។

◆ ព្រមទាំងរៀបចំយុទ្ធវិធីល្អិតក្នុងការដឹកនាំប្រយុទ្ធថែមទៀត ។

◆ ថ្ងៃនេះ គណៈភូមិភាគចុះទៅរៀបចំតាមតំបន់និងស្រុក ហើយនូវគណៈបញ្ឈាការដឹកនាំបង្កបង្កើនផលនេះ ឯពិសោធន៍ខុសត្រូវយ៉ាងណាខ្ញុំនឹងរាយការណ៍ជូនបងជាបន្តបន្ទាប់ ។

សេចក្តីរាយការណ៍ខាងលើនេះ សូមស្នើបងជួយមតិ ។

សូមគោរពជូនពរបងសុខសប្បាយនិងជ័យជំនះ

សមមិត្ត ពក

ថ្ងៃ ២-៤-៧៦

ចម្លងជូនៈ បងនួន បងខៀវ មន្ទីរ ឯកសារ



ប៉ុល ពត

# អត្ថន័យនៃធាតុឈានមុខ

*(ឯកសារដកស្រង់ពីទស្សនាវដ្ដី យុវជននិងយុវនារីបដិវត្ត លេខ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៨)*

ដែលហៅថា ឈានមុខគឺត្រូវធ្វើជាគំរូល្អ ឈានមុខលើគ្រប់ផ្នែក ឈានមុខទាំងខាងនយោបាយ ឈានមុខទាំងខាងសតិអារម្មណ៍ ឈានមុខទាំងខាងចាត់តាំង ឈានមុខទាំងក្នុងការបំពេញភារកិច្ចបដិវត្តតូចធំសព្វបែបយ៉ាង ឈានមុខទាំងខាងសីលធម៌រស់នៅប្រចាំថ្ងៃ ។

១) ឈានមុខខាងនយោបាយ

គឺក្ដាប់មាគ៌ានយោបាយគ្រប់ផ្នែករបស់បក្សបានណែនច្បាស់លាស់ ហើយវាយសម្រុកអនុវត្តមាគ៌ានយោបាយរបស់បក្សបានត្រឹមត្រូវនិងមានប្រសិទ្ធភាពខ្ពស់បំផុត ។ ក្នុងការវាយសម្រុកបំពេញភារកិច្ចតូចធំប្រចាំថ្ងៃគឺខ្លាំងក្លា ហើយត្រឹមត្រូវតាមមាគ៌ារបស់បក្សទៀត ។ តែបើវាយសម្រុកធ្វើការងារទាំងយប់ទាំងថ្ងៃតែមិនចំទិស មិនត្រូវតាមមាគ៌ារបស់បក្ស នោះក៏មិនហៅថា ឈានមុខខាងនយោបាយដែរ ។

២) ឈានមុខខាងសតិអារម្មណ៍

គឺមិនសូវជំពាក់ជំពិននឹងអ្វីទាំងអស់ ទោះជាខាងកម្មសិទ្ធិសតិអារម្មណ៍ក្ដី ឬខាងកម្មសិទ្ធសម្ភារក្ដី ឬខាងកម្មសិទ្ធិបុគ្គលសួនតួក្ដី ។ និយាយឱយខ្លី ដើម្បីឈានមុខខាងសតិអារម្មណ៍គឺត្រូវមានសតិអារម្មណ៍ជ្រះថ្លាជានិច្ចចំពោះភារកិច្ចតូចធំដែលបក្សនិងសមូហភាពប្រគល់ជូន មានជំនឿជឿជាក់លើចលនាបដិវត្តរបស់ខ្លួន ហើយមានចិត្តទូលាយអធ្យាស្រ័យច្រើនចំពោះសមមិត្តផងគ្នា ។ បើមានទស្សនៈគោលជំហរសតិអារម្មណ៍ជ្រះថ្លាយ៉ាងនេះហើយ វាយសម្រុកធ្វើការងារអីក៏ខ្លាំងក្លា សម្រេចភារកិច្ចធ្ងន់ស្រាលលំបាកស្រួលយ៉ាងណាក៏បានជោគជ័យទាំងអស់ ។ នេះហើយហៅថា ឈានមុខខាងសតិអារម្មណ៍ ។

៣) ឈានមុខខាងចាត់តាំង

គឺក្ដាប់និងជ្រួតជ្រាបមាគ៌ាចាត់តាំងគ្រប់ផ្នែករបស់បក្ស ហើយវាយសម្រុកអនុវត្តមាគ៌ាចាត់តាំងរបស់បក្សបានត្រឹមត្រូវល្អជានិច្ច ដោយឈរលើមាគ៌ាវណ្ណៈរបស់បក្សយ៉ាងរឹងមាំខ្ជាប់ខ្ជួន ។

ឧទាហរណ៍ៈ ក្នុងការឃោសនាអប់រំប្រជាជន-មហាជន គឺយកចិត្តទុកដាក់ឃោសនាអប់រំប្រជាជន-មហាជនទូទៅផង តែជាពិសេសគឺយកចិត្តទុកដាក់ប្រជាជន-មហាជនមូលដ្ឋានជាសំខាន់បំផុត ។ នេះក៏ជាការអនុវត្តមាគ៌ាចាត់តាំងរបស់បក្សត្រឹមត្រូវដែរ ។

ឧទាហរណ៍ៈ ក្នុងការជ្រើសរើសចាត់តាំងស្នូលឬអង្គការដឹកនាំផ្សេងៗ គឺយកចិត្តទុកដាក់ពិនិត្យខាងគោលជំហរវណ្ណៈអធនរបស់បក្សជាសំខាន់បំផុត តែមិនមែនពិនិត្យតែលើសមត្ថភាពបច្ចេកទេសប៉ុណ្ណោះទេ ។ នេះក៏ជាការអនុវត្តមាគ៌ាចាត់តាំងរបស់បក្សបានល្អត្រឹមត្រូវដែរ ។

ឧទាហរណ៍ៈ ក្នុងការចាត់តាំងផ្សេងៗ យើងផ្អែកលើកម្លាំងសម្ព័ន្ធភាពកម្មករ-កសិករជាមូលដ្ឋាន ដោយខិតខំប្រមូលនិងសាមគ្គីជាមួយកម្លាំងផ្សេងទៀតទាំងអស់ ។ នេះក៏ជាការឈានមុខខាងចាត់តាំងដែរ ។

ឧទាហរណ៍ៈ ក្នុងការដឹកនាំនិងធ្វើការងារផ្សេងៗ យើងអនុវត្តប្រជាធិបតេយ្យប្រមូលផ្ដុំ ដោយសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែក បានទៀងទាត់ម៉ត់ចត់ល្អ ក៏សន្មតថាឈានមុខខាងចាត់តាំងដែរ ។

ដូច្នេះ ឱយតែឈរលើមាគ៌ាចាត់តាំងរបស់បក្សគ្រប់ផ្នែកបានរឹងមាំ ហើយអនុវត្តមាគ៌ាចាត់តាំងរបស់បក្សនេះបានត្រឹមត្រូវល្អគ្រប់ពេលវេលា គឺយើងបំពាក់បាននូវធាតុឈានមុខខាងចាត់តាំងនៃវណ្ណៈអធនរបស់បក្សហើយ ។

៤) ឈានមុខខាងការងារ

គឺវាយសម្រុកបំពេញភារកិច្ចស្នូលរបស់ខ្លួនបានខ្លាំងក្លាគ្រប់

ពេលវេលា សម្រេចផែនការប្រចាំឆ្នាំរបស់បក្សដោយជោគជ័យទាំងស្រុង និងលើសថែមទៀតជាប់ជាបន្តបន្ទាប់ ។ មិនរើសអើងការងារ ទោះបីជាការងារនោះតូចក្តី ធំក្តី លំបាកក្តី ស្រួលក្តី ធ្ងន់ក្តី ស្រាលក្តី ឱយតែបក្សនិងសមូហភាពចាត់តាំងហើយគឺវាយសម្រុកធ្វើការងារនោះបានល្អនិងដោយសន្សំសំចៃជាប់ជានិច្ច ។

៥) ឈានមុខខាងសីលធម៌រស់នៅ

ក្នុងការរស់នៅប្រចាំថ្ងៃ គឺសុភាពរាបសា អំណត់អត់ធន ហើយខស្សាហ៍ព្យាយាមជាប់ជានិច្ច ។ ក្នុងការស៊ីចុក ស្លៀកពាក់ ដេកដើរ ឈរអង្គុយ លេងសើច មានលក្ខណៈសាមញ្ញមិនឆ្មើងឆ្មៃ មិនវាយឫកពា មិនស្រវាស្រទេញ មិនឆើតឆាយ មិនខ្ជះខ្ជាយ មិនរាយមាយរយីករយាក តែរៀបរយ សណ្តាប់ធ្នាប់សមរម្យ ស្អាតស្អំត្រឹមត្រូវ មិនពាលាអាវ៉ាសែ ។ល ។ ពោលគឺជាគំរូល្អដល់មហាជនទូទៅ ធ្វើឲ្យមហាជនទូទៅគោរពស្រលាញ់ពេញចិត្តពេញថ្លើម ។ នេះហើយហៅថា ឈានមុខខាងសីលធម៌រស់នៅ ។

ដូច្នេះ ដែលហៅថាឈានមុខ គឺត្រូវឈានមុខលើគ្រប់ផ្នែកទាំងអស់ ធ្វើជាគំរូល្អលើគ្រប់ផ្នែកទាំងអស់ ។ បើមិត្តយុវជនយុវនារីយើងបំពាក់បំប៉នបាននិងពង្រីងថែមនូវធាតុឈានមុខវណ្ណៈអធនរបស់បក្សដូចពោលខាងលើនេះបាននោះ មិត្តយើងកសាងខ្លួនក៏បានល្អនិងឆាប់រហ័ស វាយសម្រុកបំពេញភារកិច្ចការពារប្រទេសក៏បានខ្លាំងក្លា ហើយវាយសម្រុកសម្រេចភារកិច្ចកសាងប្រទេសក៏បានលឿនឆាប់រហ័សមហាលោតផ្លោះ ។ ដូច្នេះ ធាតុឈានមុខនេះវាជាធាតុវណ្ណៈអធនរបស់បក្សផង ហើយក៏ជាធាតុមូលដ្ឋានរបស់សម្ព័ន្ធយុវកកយើងផង ។ បើបំពាក់បំប៉ននូវធាតុឈានមុខនេះបានហើយ ធាតុផ្សេងៗទៀត ទស្សនៈគោលជំហរបដិវត្តផ្សេង ក៏នឹងអាចបំពាក់បំប៉នបានជាលំដាប់និងយ៉ាងឆាប់រហ័សផងដែរ ។ ដូច្នេះ ធាតុឈានមុខនេះ វាជាគន្លឹះក្នុងការបំពាក់បំប៉នទស្សនៈគោលជំហរបដិវត្តគ្រប់ផ្នែកផ្សេងទៀត ។



# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៧១១ | ចាន់ ផាច ហៅ លី | កងវរសេនាតូច | មន្ទីរឃ្លាំងរដ្ឋ | ១៨-៧-៧៦ | ២០-៧-៧៦ |
| ៧១២ | ឈឹម សាក់ | វិស្វករទំនប់ទឹក | បាត់ដំបង | ១៦-១-៧៦ | ២២-៧-៧៦ |
| ៧១៣ | ណុប គុប | ប្រជាជន | តំបន់២៥ | ១០-៣-៧៦ | ២២-៧-៧៦ |
| ៧១៤ | ឡុង ទ្រី | យុទ្ធជន | ២១យ | ២២-៧-៧៦ | ២៤-៧-៧៦ |
| ៧១៥ | យាម ហ៊ាង | យុទ្ធជន | ២១យ | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧១៦ | អ៊ុន ហ៊ល ហៅ អ៊ុយ | ប្រជាជន | កំពង់សោម | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧១៧ | ណឹម ណម ហៅ រិន | ប្រជាជន | កំពង់សោម | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧១៨ | ទិត ចុំ | ប្រជាជន | កំពង់សោម | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧១៩ | រិន ជិនហួត | ប្រជាជន | កំពង់សោម | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧២០ | ឡៅ សាលី | ប្រជាជន | តំបន់២៥ | ១១-៤-៧៦ | ២៤-៧-៧៦ |
| ៧២១ | ឡាំ ឌ័រ | កម្មករ | រោងចក្រថ្មពិល | ១៤-៦-៧៦ | ២៤-៧-៧៦ |
| ៧២២ | ទេព ទ្រី | កម្មករ | កំពង់សោម | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧២៣ | ស៊ុម ភិន ហៅ ផាត | ស្មៀនធនាគារ | បាត់ដំបង | ១៦-៦-៧៦ | ២៤-៧-៧៦ |
| ៧២៤ | កែវ ជឿន | គិញ | កំពង់សោម | ៧-៥-៧៦ | ២៤-៧-៧៦ |
| ៧២៥ | សៅ គង់ | និស្សិត | តំបន់២៥ | ១០-៣-៧៦ | ២៤-៧-៧៦ |
| ៧២៦ | នួន ស៊ីដារ៉ា | កូនសិស្ស | ស្រែអំបិល | ២៨-៥-៧៦ | ២៤-៧-៧៦ |
| ៧២៧ | អ៊ា ឆៃប៉ូវ | កូនសិស្ស | ចំការដូង | ៧-៥-៧៦ | ២៤-៧-៧៦ |
| ៧២៨ | អ៊ុក ឆេងអ៊ាង | យុទ្ធជន | ស២១-យ | ២៤-៧-៧៦ | ២៤-៧-៧៦ |
| ៧២៩ | ទូច ឃុត | មេក្រុម | ស២១-យ | ៩-៧-៧៦ | ២៤-៧-៧៦ |
| ៧៣០ | បេ ម៉េងហេង | យុទ្ធជន | ស២១-យ | ១៣-៧-៧៦ | ២៤-៧-៧៦ |
| ៧៣១ | គីម លី | ពេទ្យ | ស២១-យ | ១៧-៧-៧៦ | ២៤-៧-៧៦ |
| ៧៣២ | អ៊ីង ហួត | យុទ្ធជន | ស២១-យ | ២០-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៣ | អឿង ផាត | យុទ្ធជន | ស២១-យ | ២១-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៤ | សន សុង | យុទ្ធជន | ស២១-យ | ២២-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៥ | អោម ព្រាម | យុទ្ធជន | ស២១-យ | ២២-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៦ | អ៊ឹម ផល | យុទ្ធជន | ស២១-យ | ២២-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៧ | ម៉ម ឆុន | មេក្រុម | ស២១-យ | ២២-៧-៧៦ | ២៤-៧-៧៦ |
| ៧៣៨ | ទូច លន | អនុក្រុម | កងពល៥០២ | ៨-៥-៧៦ | ២៥-៧-៧៦ |
| ៧៣៩ | ទេព លន | យុទ្ធជន | ស២១-យ | ២៥-៧-៧៦ | ២៥-៧-៧៦ |

(នៅមានត)

# មិនមានប្រយោជន៍អ្វីទាំងអស់សម្រាប់ខ្លួនខ្ញុំ



ឆែម ឈិន មានស្រុកកំណើតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឪពុកឈ្មោះ ហែម ឆែម និងម្តាយឈ្មោះ ស៊ិន សាន ។ ឈិន មានបងប្អូនពីរនាក់ គឺខ្លួនគាត់និងប្អូនស្រីម្នាក់ឈ្មោះ ឆែម ចាន់រី បច្ចុប្បន្ននៅរស់ ។ មុនបដិវត្តន៍ ក្រុមគ្រួសាររបស់ ឈិន មានវណ្ណៈភាពជាកសិករកណ្តាលថ្នាក់ក្រោម ។ កាលពីអាយុ៨ឆ្នាំ ឈិន បានចូលរៀនអក្សរលេខនព្វន្តនៅ "វត្តភ្នំ" (នៅក្នុងស្រុកកំណើតរបស់គាត់) ។ រៀនបានមួយរយៈ ឈិន ក៏ឈប់រៀនដើម្បីមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៦៩ ឈិន បានត្រឡប់ទៅរៀនបន្តទៀតបាន១ឆ្នាំក៏ឈប់រហូតដល់ឆ្នាំ១៩៧១ ទើបឪពុកម្តាយឲ្យ ឈិន បួសជាសង្ឃ ។ ឈិន លាចាកសិក្ខាបទនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៣ ដើម្បីចូលរួមក្នុងចលនាបដិវត្តន៍ខ្មែរក្រហម ។

ឈិន បានចូលរួមក្នុងចលនាបដិវត្តន៍តាមការឃោសនារបស់ឈ្មោះ ពុំ ជាប្រធានភូមិ ។ ឈិន នៅក្នុងកងយោធាស្រុក ១៥៤ (ស្រុកកណ្តាលស្ទឹង) តំបន់១៥ ។ នៅខែកញ្ញា ឆ្នាំ១៩៧៣ អង្គការបានចាត់តាំង ឈិន ឲ្យទៅនៅអង្គភាពយោធាតំបន់ ក្រោមការដឹកនាំរបស់ឈ្មោះ ស ។ ខែមករា ឆ្នាំ១៩៧៤ ឈិន ត្រូវផ្លាស់ទៅអង្គភាព១៣៨ កងអនុសេនាធំ៨២ ដែលដឹកនាំដោយឈ្មោះ ផល, ឈន និង សាមន ។ ក្រោយមកទៀត ឈិន បានចូលទៅនៅកងពលលេខ១២ ក្រោមការគ្រប់គ្រងរបស់ តាពីន និង តាណាត ។ នៅក្នុងគម្រោងវាយដណ្តើមយកទីក្រុងភ្នំពេញកាលពីដើមឆ្នាំ១៩៧៥ ឈិន បានទទួលមុខព្រួញតាមដងទន្លេមេគង្គនិងទន្លេបាសាក់ ប៉ុន្តែ ឈិន មិនបានចូលដល់ទីក្រុងភ្នំពេញទេ ដោយសារត្រូវរបួសមកសម្រាកព្យាបាលនៅមន្ទីរពេទ្យស្រុកកោះធំ ។

បន្ទាប់ពីបានជាសះស្បើយ អង្គការក៏បញ្ជូន ឈិន មករៀនសូត្រអក្សរសាស្ត្រនៅបឹងត្របែក ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ មានការជ្រើសរើសទាហានមួយចំនួនដែលមានប្រវត្តិរូបល្អឲ្យមកធ្វើការនៅភ្នំពេញ ។ ឈិន នឹកស្មានថា ក្រោយពេលដែលផ្តួលរំលំរបបលន់ណុលបានហើយ គាត់អស់ភារកិច្ចរឿងសង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯងទៀតហើយ ហើយគាត់ពិតជាបានវិលត្រឡប់ទៅជួបជុំឪពុកម្តាយវិញ ប៉ុន្តែការគិតរបស់ ឈិន គឺខុសស្រឡះ ព្រោះគាត់ត្រូវអង្គការជ្រើសរើសឲ្យធ្វើជាកងការពារអ្នកទោសនៅមន្ទីរស-២១ ។ ឈិន ត្រូវបានចាត់តាំងឲ្យយាមអ្នកទោសដែលដាក់នៅក្នុងផ្ទះតូចៗនៅខាងលិចគុកទួលស្លែង ។ ក្រោយមកទើបមានការរៀបចំគុកទួលស្លែងជាគុកធំសម្រាប់ដាក់អ្នកទោស ។ ឈិន បានឲ្យដឹងថា គាត់ធ្លាប់ឃើញខ្មែរក្រហមដឹកមនុស្សចូលក្នុងគុកទួលស្លែង ពេលខ្លះឃើញដឹកចេញ ដោយប្រើរថយន្តទ្រុងធំៗរបស់ចិនដែលគ្របក្រណាត់ពីលើជិត ។ ឈិន មិនដឹងថា តើខ្មែរក្រហមយកអ្នកទោសទាំងអស់នោះទៅសម្លាប់នៅទីណាទេ ប៉ុន្តែមានករណីខ្លះគាត់ឃើញសម្លាប់នៅក្នុងបរិវេណគុកតែម្តង ។ ឈិន បានប្រាប់ថា គាត់ចេះតែនឹកឆ្ងល់ ព្រោះកាលពីដំបូង ខ្មែរក្រហមប្រាប់ថា ធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិឲ្យរួចផុតពីការជិះជាន់កេង

ប្រវិញ ពីខ្នោះឃ្នាងគុកច្រវាក់ ចុះហេតុអ្វីពេលនេះ ខ្មែរក្រហមយកមនុស្សមកដាក់គុកច្រវាក់និងសម្លាប់ចោលដោយគ្មានរកខុសត្រូវបែបនេះទៅវិញ ។ នៅឆ្នាំ ១៩៧៧ អង្គការបានបញ្ជូន ឈិន ទៅធ្វើស្រែនៅព្រៃស ។

រយៈពេលជាង២ឆ្នាំដែលគាត់ធ្វើការនៅក្នុងគុកទួលស្លែង ឈិន បានស្គាល់ ឌុច ដែលជាប្រធានគុកទួលស្លែង ។ ឈិន បានឲ្យដឹងថា ឌុច មានរាងស្តើង ស្គមសម្បុរសទំនងជាកូនកាត់ចិន អត្តចរិតមិនសូវកាចប៉ុន្មានទេ ។ ឈិន បានបង្ហាញការខកចិត្តយ៉ាងខ្លាំងចំពោះបដិវត្តន៍របស់ខ្មែរក្រហម ។ គាត់និយាយថា "ខ្ញុំដឹងថាខ្ញុំបានចូលក្នុងអន្ទាក់របស់ខ្មែរក្រហមហើយ ប៉ុន្តែខ្ញុំមិនដឹងជាត្រូវរត់គេចទៅទីណា ម៉្លោះហើយក៏ចេះតែទ្រាំទៅ ។ នៅពេលដែលអង្គការបញ្ជូនខ្ញុំមកនៅព្រៃស ខ្ញុំបានធូរស្រាលចិត្តខ្លះ ព្រោះទីនោះធ្វើតែស្រែមិនលំបាកដូចយាមកាមអ្នកទោសទេ" ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ឈិន បានភៀសខ្លួនឡើងលើភ្នំនៅភាគខាងលិចប្រទេសកម្ពុជា ហើយរស់នៅទីនោះរហូតដល់ឆ្នាំ១៩៨០ ។ ដោយនឹកស្រុកកំណើតពេក ឈិន បានសម្រេចចិត្តចុះចូលជាមួយរដ្ឋាភិបាល ។ បច្ចុប្បន្ន ឈិន មានអាយុ៤៨ឆ្នាំ មានក្រុមគ្រួសាររស់នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ រហូតមកដល់ពេលនេះ ឈិន នៅតែមិនអស់ចិត្តសោះចំពោះអំពើដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។ ឈិន និយាយថា "ខ្ញុំពិតជាខកចិត្តខ្លាំងណាស់ កាលដែលខ្ញុំស្ម័គ្រចិត្តចូលព្រៃតស៊ូជួបខបសគ្គគ្រប់បែបយ៉ាង ហ៊ានពលីជីវិតដើម្បីជាតិមាតុភូមិ ខ្ញុំនឹកសង្ឃឹមថា ពេលទទួលបានជ័យជម្នះ ប្រជាជននិងប្រទេសជាតិមានការរីកចម្រើន លូតលាស់ ប៉ុន្តែនៅទីបំផុតមិនមានប្រយោជន៍អ្វីទាំងអស់សម្រាប់ខ្លួនខ្ញុំនិងប្រទេសជាតិទាំងមូល មានតែការវិនាសអន្តរាយប៉ុណ្ណោះ" ។

**សុខ ខណ្ឌៈ**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ **"វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ"** ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ជាកម្មវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការទីងទុំក្ខួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការរចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ និង ០១២ ៩៨៨ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។

សូមអរគុណ ។

# ជម្លោះរវាងចិននិងកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥

សតវត្សរ៍នេះជាសតវត្សរ៍ដែលប្រកបទៅដោយសោកនាដកម្មចំពោះប្រទេសជាច្រើន ប៉ុន្តែវាពិបាកនឹងគិតថាមានកន្លែងផ្សេងនៅលើផែនដីនេះដែលទទួលរងសោកនាដកម្មយូរជាង និងមិនចាំបាច់ដូចជាករណីប្រទេសកម្ពុជានោះឡើយ ។ ចាប់តាំងពីវៀតណាមខាងជើងចាប់ផ្តើមការតស៊ូដោយអាវុធជាថ្មីដើម្បីបង្រួបបង្រួមជាមួយវៀតណាមខាងត្បូងនៅឆ្នាំ១៩៥៩មក ប្រទេសកម្ពុជាបានរស់នៅក្រោមស្រមោលនៃសង្គ្រាមវៀតណាមជានិច្ច ។ ហាណូយបានប្រើប្រាស់ទឹកដីកម្ពុជាដើម្បីបញ្ជូនយុទ្ធជននិងសម្ភារសឹកមកវៀតណាមខាងត្បូង ក្នុងគោលបំណងធ្វើសង្គ្រាមបដិវត្តន៍ ។ ដើម្បីបញ្ឈប់វៀតណាមខាងជើងកុំឲ្យជ្រៀតចូលមកវៀតណាមខាងត្បូង ក្នុងឆ្នាំ១៩៦៩ រដ្ឋការនិចសុន បានចាប់ផ្តើមទម្លាក់គ្រាប់បែកជាសម្ងាត់ទៅលើទីជម្រកនានារបស់វៀតណាមនៅលើទឹកដីកម្ពុជា ។ រដ្ឋប្រហាររបស់ពួកស្តាំនិយមប្រឆាំងនឹងសម្តេច សីហនុ នៅក្នុងឆ្នាំ១៩៧០ និងការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះរបបលន់ណុលបានរុញច្រានឲ្យសម្តេច សីហនុ ធ្លាក់ចូលទៅក្នុងការតស៊ូដោយអាវុធជាមួយក្រុមខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត ។ នៅឆ្នាំ១៩៧៥ ប៉ុល ពត បានកាន់កាប់អំណាចនៅទីក្រុងភ្នំពេញ ជាពេលនៃការចាប់ផ្តើមសុបិនអាក្រក់ទូទាំងប្រទេសកម្ពុជាដែលសន្ធប់អស់ពេលដ៏យូរ ។

ការសិក្សាស្រាវជ្រាវកន្លងមកច្រើនតែផ្តោតការយកចិត្តទុកដាក់ទៅលើតួនាទីរបស់សហរដ្ឋអាមេរិកនៅក្នុងការបង្កអស្ថិរភាពដល់ប្រទេសកម្ពុជានៅអំឡុងឆ្នាំ១៩៦៩-១៩៧០ និងការគ្រួសត្រាយផ្លូវឲ្យ ប៉ុល ពត ឡើងកាន់អំណាច ។ ក៏ប៉ុន្តែការឆ្លើយតបរបស់ចិនចំពោះវិបត្តិកម្ពុជាពុំទាន់មានការសិក្សាច្រើននៅឡើយទេ ។ ផ្អែកលើប្រភពនានាដែលទើបតែបញ្ចេញឲ្យដឹងពីសំណាក់ប្រទេសចិននិងសហរដ្ឋអាមេរិក អត្ថបទនេះពិនិត្យទៅលើទំនាក់ទំនងដែលមានលក្ខណៈស្មុគស្មាញរវាងប្រទេសចិនសម្តេច សីហនុ និងខ្មែរក្រហម ក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ ដោយផ្តោតសំខាន់ទៅលើបញ្ហាថា តើការប្រកួតប្រជែងរបស់ក្រុងប៉េកាំងជាមួយសហភាពសូវៀត និងវៀតណាមខាងជើងមានផលប៉ះពាល់យ៉ាងដូចម្តេចចំពោះនយោបាយរបស់ក្រុងប៉េកាំងចំពោះកម្ពុជា ។

### ទំនាក់ទំនងរវាងចិនជាមួយសម្តេច សីហនុ មុនឆ្នាំ១៩៧០

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ដល់មុនពេលមានបដិវត្តវប្បធម៌ឆ្នាំ១៩៦៦ ក្រុងប៉េកាំងបានថែរក្សាទំនាក់ទំនងយ៉ាងស្មោះស្ម័គ្រជាមួយកម្ពុជា ។ មេដឹកនាំចិនបានឲ្យសម្តេច សីហនុ សម្រេចគោលដៅពីរយ៉ាង ។ ទីមួយតាមរយៈការជំរុញឲ្យកម្ពុជាឈប់ចងសម្ព័ន្ធមិត្តជាមួយសហរដ្ឋអាមេរិក ។ ចិនបានរិះរកវិធីធ្វើឲ្យខូចនយោបាយអាមេរិកដែលទប់ចិនមិនឲ្យមានឥទ្ធិពល ។ ការគិតដល់បញ្ហានេះនាំឲ្យកើតជាការជំរុញមុនដំបូងនៅក្នុងការគាក់តែងគោលនយោបាយរបស់ចិន ។ ទីពីរ ម៉ៅមានចេតនាច្បាស់ក្រឡែតចង់ប្រើសម្តេច សីហនុ ដែលជាអ្នកជាតិនិយមប្រកបដោយមោទកភាពនិងក្លៀវក្លា ជាឧបករណ៍កម្រិតឥទ្ធិពលរបស់វៀតណាមនៅកម្ពុជា ។

ទំនាក់ទំនងមិត្តភាពរបស់ចិនជាមួយ សម្តេច សីហនុ ចាប់ផ្តើមនៅឆ្នាំ១៩៥៥ នៅឯសន្និសីទបានឌុង ដែលនៅក្នុងសន្និសីទនោះ នាយករដ្ឋមន្ត្រីចិន ជូ អេន ឡាយ បានសន្យាថា នឹងគាំទ្រអព្យាក្រឹតភាពរបស់កម្ពុជា ។ ជូ អេន ឡាយ បានប្រាប់ឲ្យដឹងជាមុននូវគ្រោះថ្នាក់នៃនយោបាយរបស់សហរដ្ឋអាមេរិក ព្រមទាំងបានជំរុញឲ្យសម្តេច សីហនុ ជួលទីប្រឹក្សាយោធាបារាំងឲ្យជួយហ្វឹកហ្វឺនកងទ័ពកម្ពុជា ជាជាងប្រើទីប្រឹក្សាអាមេរិកាំង ។ ជូ អេនឡាយ បានយាងសម្តេច សីហនុ ទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ។ មេដឹកនាំកម្ពុជារូបនេះធានាចំពោះ ជូ អេន ឡាយ ថា ព្រះអង្គនឹងមិនចូលបក្សយោធាណាមួយនិងមិនផ្តល់មូលដ្ឋានយោធាដល់សហរដ្ឋអាមេរិកទេ ។

ក្នុងអំឡុងពេលទស្សនកិច្ចរបស់សម្តេច សីហនុ នៅប្រទេសចិនរវាងថ្ងៃទី ១៣-២១ ខែកុម្ភៈ ឆ្នាំ១៩៥៦ ម៉ៅ បានសរសើរនយោបាយសន្តិភាពនិងអព្យាក្រឹតនិយមរបស់សម្តេច ដោយប្រកាសថា នយោបាយបែបនេះមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងពិភពលោក ។ ជូ អេន ឡាយ បានសង្កត់ធ្ងន់ទៅលើគោលការណ៍សមភាពរវាងរដ្ឋនិងរដ្ឋនៅក្នុងកិច្ចការអន្តរជាតិ ដោយមិនគិតអំពីទំហំរបស់រដ្ឋនោះទេ ។ នៅក្នុងសេចក្តីប្រកាសរួមចេញផ្សាយនៅពេលចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់សម្តេច សីហនុ ប្រទេសទាំងពីរបានយល់ព្រមជាមួយគ្នាទៅលើគោលការណ៍សន្តិសហវិជ្ជមាន ប្រាំ “៥” ដោយចាត់ទុកថាជាគោលការណ៍ណែនាំសម្រាប់ទំនាក់ទំនងរវាងចិននិងកម្ពុជា ។ ក្រោយពីដំណើរយាងទស្សនកិច្ចនៅប្រទេសចិនរបស់សម្តេច សីហនុ ចិនយល់ព្រមផ្តល់ដល់កម្ពុជានូវជំនួយឥតសំណងផ្នែកសេដ្ឋកិច្ច គិតជាទឹកប្រាក់ប្រមាណ៨លានដុល្លារ ។ កម្ពុជាអាចប្រើជំនួយនេះដើម្បីកសាងរោងចក្រវាយនភ័ណ្ឌ រោងចក្រស៊ីម៉ង់ត៍ រោងចក្រក្រដាស សង់ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធបញ្ចេញបញ្ចូលទឹក និងកសាងសាលារៀន និងមន្ទីរពេទ្យ ។ កម្ពុជាគឺជាប្រទេសមិនមែនសង្គមនិយមទីមួយដែលបានទទួលជំនួយឥតសំណងផ្នែកសេដ្ឋកិច្ចពីប្រទេសចិន ។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៦ ជូ អេន ឡាយ បានធ្វើដំណើរទស្សនកិច្ចមកកាន់ទីក្រុងភ្នំពេញ ដែលនៅទីនោះ ជូ អេន ឡាយ បានបញ្ជាក់សាជាថ្មីនូវការគោរពរបស់ចិនចំពោះអព្យាក្រឹតនិយមរបស់កម្ពុជា ។ នាយករដ្ឋមន្ត្រីចិនក៏បានរិះរកមធ្យោបាយកាត់បន្ថយការភ័យខ្លាចរបស់សម្តេច សីហនុ ថា ចិនចង់គ្របសង្កត់កម្ពុជាដោយប្រយោលតាមរយៈឥទ្ធិពលរបស់ប្រជាជនចិននៅលើទឹកដីកម្ពុជាដែលមានចំនួនរហូតដល់៤សែននាក់ រួមទាំងអ្នកជំនួញនិងឈ្មួញធំៗផង ដោយជំរុញឲ្យអ្នកទាំងនោះស្មោះត្រង់នឹងកម្ពុជា ។ តាងនាមឲ្យរដ្ឋាភិបាលចិន ជូ អេន ឡាយ បានផ្តល់អំណោយដល់កម្ពុជាជាសម្ភារបរិក្ខារពេទ្យក៏ដូចជាជំនួយសង់សាលាសិល្បៈ ។

ជាការច្បាស់ណាស់ថា ទំនាក់ទំនងរវាងចិននិងកម្ពុជារួមមានទាំងការវង្វៀសចិត្តផងនៅក្នុងអំឡុងពេលនេះ ។ ក្រុងប៉េកាំងមិនសប្បាយចិត្តនឹងការដែលសម្តេច សីហនុ ទទួលជំនួយយោធារបស់សហរដ្ឋអាមេរិកទេ ។ ដោយមានការមមៃដល់ការការពារព្រំប្រទល់ប្រទេសរបស់ព្រះអង្គចំពោះការទាមទារទឹកដីរបស់វៀតណាមខាងត្បូងនិងប្រទេសថៃផងនោះ សម្តេច សីហនុ បានរិះគន់ចិនដែលមានភាពស្ទាក់ស្ទើរក្នុងការធានាតែសំបកក្រៅដល់បូរណភាពទឹកដីរបស់កម្ពុជា ។ ទោះជាមានការខ្វែងយោបល់គ្នាយ៉ាងនេះក្តី ក៏និយាយជារួម ទំនាក់ទំនងរវាងចិននិងកម្ពុជានៅតែមានភាពស្និទ្ធស្នាលនឹងគ្នាដដែល ។

ការយល់ព្រមរបស់មេដឹកនាំចិនទៅលើអព្យាក្រឹតនិយមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ គឺជាការចេញដំណើរដ៏សំខាន់ពីការផប់ទៅលើទ្រឹស្តី “ជំរំពីរ” ដ៏តឹងរ៉ឹងកន្លងមក ។ នៅឆ្នាំ១៩៤៩ ម៉ៅបានចំអកឡកឡឺយដល់ “ការភ័ត្តវិញ្ញាណនៃផ្លូវទីបី” ចំណែកឯ លីវ ចាវជី បានចំអកដាក់បុរសរដ្ឋអព្យាក្រឹតនិយមទាំងនោះថា ជា ហ្សាវ៉ាហាឡាល់ នេរុ, អ៊ូ នូ ហើយបានហៅ ស៊ូកាណូ ថា ជា“ពួកចក្រពត្តិ” ព្រមទាំងជំរុញឲ្យក្រុមកុម្មុយនិស្តនៅក្នុងរដ្ឋអព្យាក្រឹតទាំងនេះបង្កើតចលនាតស៊ូដោយអាវុធតាមគំរូរបស់ចិនផង ។ ប៉ុន្តែនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ គំនិតមូលវិវដ្តនិយមបែបនេះត្រូវបានដាក់ជំនួសដោយគោលនយោបាយសន្តិសហវិជ្ជមានដែលមានលក្ខណៈជាក់ស្តែងនិងល្មមមិនខ្លាំងពេក ជាមួយប្រទេសនានានៅអាស៊ីដែលមានប្រព័ន្ធនយោបាយខុសគ្នា ។

នៅឆ្នាំ១៩៥៨ ម៉ៅ បានចាប់ផ្តើមសង្កត់ធ្ងន់ទៅលើការគាំទ្រដល់ការតស៊ូរំដោះជាតិក្នុងគោលបំណងធ្វើឲ្យខូចដល់ការគាំទ្ររបស់មេដឹកនាំសូវៀត នីគីតា គ្រូសឆេវ ចំពោះសន្តិសហវិជ្ជមានជាមួយសហរដ្ឋអាមេរិក ។ ទោះជាមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងគោលនយោបាយក្រៅប្រទេសយ៉ាងនេះក៏ដោយ ក៏ថ្នាក់ដឹកនាំចិននៅតែបន្តទាក់ទាញសម្តេច សីហនុ ដដែល ។ មេដឹកនាំចិនចាត់ទុកថា នយោបាយអព្យាក្រឹតរបស់សម្តេច សីហនុ មានផលប្រយោជន៍សម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបំបែកការធ្វើឲ្យឯកោពីសំណាក់សហរដ្ឋអាមេរិកមកលើចិន ។ នៅខែមិថុនា ឆ្នាំ១៩៥៨ ភាពតានតឹងរវាងកម្ពុជានិងវៀតណាមខាងត្បូងចេះតែកើនឡើងដោយសារជម្លោះព្រំដែន ។ នៅថ្ងៃទី៣០ ខែមិថុនា រដ្ឋមន្ត្រីការបរទេសចិន ជិន អ៊ី

បានប្រកាសថា ចិនគាំទ្រកម្ពុជានៅក្នុងជម្លោះជាមួយវៀតណាមខាងត្បូង ។ នៅថ្ងៃទី១៩ ខែកក្កដា ចិននិងកម្ពុជាបានបង្កើតទំនាក់ទំនងការទូតជាមួយគ្នា ។ ពេលវេលានៃការសម្រេចចិត្តរបស់សម្តេច សីហនុ ក្នុងការបង្កើតទំនាក់ទំនងការទូតជាមួយទីក្រុងប៉េកាំងបានបង្ហាញឲ្យឃើញថា នយោបាយរបស់ព្រះអង្គជាមួយចិន គឺទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងទំនាក់ទំនងជាមួយវៀតណាមខាងត្បូងនិងប្រទេសថៃ ។ សម្តេចបានចាត់ទុកថារដ្ឋាភិបាលសហរដ្ឋអាមេរិកជាពិសេសភ្នាក់ងារស៊ើបការណ៍សម្ងាត់ (សេ.អ៊ី.អា) ជាអ្នកទទួលខុសត្រូវចំពោះទង្វើដែលបានប្រព្រឹត្តឡើងដោយទីក្រុងសៃហ្គននិងបាងកក ។ ការទទួលស្គាល់របស់កម្ពុជាចំពោះសាធារណរដ្ឋប្រជាមានិតចិន បង្ហាញឲ្យឃើញនូវការផាកក្រោយទៅរកនយោបាយអាមេរិកស្តីអំពីការទប់ស្កាត់ការរីករាលដាលឥទ្ធិពលនៅអាស៊ី-អាគ្នេយ៍ ។ ប្រការនេះបញ្ជាក់ថា អ្នកតាក់តែងគោលនយោបាយរបស់សហរដ្ឋអាមេរិកគិតក្នុងចិត្តជាប់ជានិច្ចពីការប្រឈមមុខនានានៅក្នុងសង្គ្រាមត្រជាក់ហើយមិនបានផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើការប្រកួតរយៈពេលយូរជាមួយគូអង្គប្រចាំតំបន់នៅអាស៊ី-អាគ្នេយ៍ឡើយ ។

នៅថ្ងៃទី១៥ខែសីហា ឆ្នាំ១៩៥៨ សម្តេច សីហនុ បានយាងមកទស្សនកិច្ចជាផ្លូវរដ្ឋនៅទីក្រុងប៉េកាំង ។ សម្តេច យាងមកប្រទេសចិននៅចំពេលដែលភាពតានតឹងនៃលទ្ធិកុម្មុយនិស្តរបស់ម៉ៅ សេទុង ឡើងដល់កំពូល ។ នៅរដូវក្តៅនោះ ម៉ៅ សេទុង កំពុងតែចាប់ផ្តើមនាំប្រទេសចិនចូលទៅក្នុងចលនាមហាលោតផ្លោះមហាអស្ចារ្យដែល ម៉ៅ ខ្លួនឯងជឿថា ចលនានេះអាចសម្រេចទៅបានតាមរយៈ “ចលនាមហាជន” ។ ជាមួយនឹងការសរសេរអក្សរដោយជក់ជាមួយទឹកខ្មៅ មេដឹកនាំចិនរូបនេះបានប្របាច់ប្រជាជននៅតាមជនបទឲ្យរស់នៅជាឃុំៗ នៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ហើយឲ្យធ្វើការដូចៗគ្នា ។ ប្រជាកសិករបានលះបង់ទ្រព្យសម្បត្តិ សូម្បីតែផាលនិងចបក៏មិនទុកដែរ ។ រោងបាយរួម និងកន្លែងបោកអ៊ុតរួមបានដោះលែងស្ត្រីចេញពីចំណងការងារផ្ទះឲ្យចេញទៅធ្វើការនៅតាមវាលស្រែ ចំណែកឯបុរសវិញរៀនសង់ឡស្លដែក ព្រមទាំងបំពេញបន្ថែមនូវទិន្នផលជាដែកថែបនៅតាមរោងចក្រនៅជនបទ ។ នៅថ្ងៃទី១៧ ខែសីហា ជូ អេន ឡាយ បាននាំសម្តេច សីហនុ យាងទតរោងចក្រដែកថែបនៅទីក្រុងប៉េកាំង ដែលជាការបង្ហាញឲ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់ ម៉ៅ ក្នុងការកសាងឧស្សាហកម្មរបស់ចិន ។ ជូ អេន ឡាយ បានពិភាក្សាជាមួយ សម្តេច សីហនុ ទៅលើវិធីក្នុងការបង្កើតផលិតផលដែកថែប ។ នៅពេលផ្តល់យោបល់ដល់សម្តេចក្នុងការកសាងរោងចក្រផលិតដែកថែបនៅកម្ពុជា នាយករដ្ឋមន្ត្រីចិនបានសង្កត់ធ្ងន់ថា នៅពេលដែលប្រទេសមួយចាប់ផ្តើមផលិតដែកថែប ប្រទេសនោះអាចលែងងាយទទួលរងនូវការឈ្លានពានពីខាងក្រៅទៀតហើយ ។ ជូ អេន ឡាយ បានពន្យល់ថា នៅពេលដែលចិនផលិតដែកថែបមិនទាន់បាន ចិនទទួលរងនូវការសម្លុតពីមហាអំណាចបរទេស ។ ក្រោយពីបានសម្តែងចេញនូវឆន្ទៈចង់ជួយឲ្យកម្ពុជាកសាងរោងចក្រដែកថែបបាន ជូ អេន ឡាយ សង្ឃឹមថា ប្រទេសទាំងអស់នៅលោកខាងកើតសុទ្ធតែមានសមត្ថភាពផលិតទាំងអស់គ្នា ។ នៅថ្ងៃទី២១ ខែសីហា ជូ អេន ឡាយ បានយាងសម្តេច សីហនុ ទៅទស្សនកិច្ចភូមិមួយនៅស្រុកវូឈីង ខេត្តហេបិ ។ មិនដឹងច្បាស់ថា ក្នុងដំណើរយាងទៅទស្សនកិច្ចនោះសម្តេចមានព្រះតម្រិះយ៉ាងដូចម្តេចទេ ចំពោះគំនិតមហាលោតផ្លោះមហាអស្ចារ្យរបស់ ម៉ៅ សេទុង ។ សម្តេចសព្វព្រះហឫទ័យខ្លាំងណាស់ចំពោះការស្វាគមន៍ដ៏កក់ក្តៅដែលសម្តេចបានទទួលនៅក្នុងប្រទេសចិន ។

មន្ត្រីសហរដ្ឋអាមេរិកថប់ក្នុងចិត្តយ៉ាងខ្លាំងចំពោះដំណើរយាងទស្សនកិច្ចរបស់សម្តេច សីហនុ នៅប្រទេសចិន ។ មន្ត្រីសហរដ្ឋអាមេរិកបារម្ភថា សម្តេចអាចនឹងទទួលជំនួយយោធាពីទីក្រុងប៉េកាំង ។ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក កាលស្រ្តូម មានការធូរទ្រូងដោយសារថា សម្តេច សីហនុ បានបដិសេធជំនួយយោធារបស់ចិន ទោះបីជាចិនបានផ្តល់ទាំងជំនួយផ្នែកសេដ្ឋកិច្ចនិងយោធាដល់កម្ពុជាក្តី ដោយហេតុថា ទ្រង់សព្វព្រះទ័យនឹងជំនួយដែលព្រះអង្គទទួលបានពីសហរដ្ឋអាមេរិកនិងបារាំង ។ សម្តេច សីហនុ បានមានព្រះបន្ទូលជម្រាប ស្រ្តូម វិញថា ដំណើរយាងទស្សនកិច្ចរបស់សម្តេចមិនបានធ្វើឲ្យមានការប្រែប្រួលនៅក្នុងនយោបាយកម្ពុជាទេ ប៉ុន្តែ ស្រ្តូម និយាយថា

សេចក្តីប្រកាសរបស់កម្ពុជាអំពីការគាំទ្ររបស់ខ្លួនក្នុងការអនុញ្ញាតឲ្យសាធារណរដ្ឋប្រជាមានិតចិនចូលជាសមាជិកអង្គការសហប្រជាជាតិ គឺជាការផ្លាស់ប្តូរ ។ សម្តេច សីហនុ ក៏មានព្រះបន្ទូលជម្រាបទៅ ស្ត្រូម វិញថា សម្តេចបានពិភាក្សាជាមួយ ជូ អេនឡាយ អំពីទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ។ ជូ អេន ឡាយ កត់សម្គាល់ថា បញ្ហាពិតប្រាកដរវាងចិននិងសហរដ្ឋអាមេរិកគឺរឿងកោះតៃវ៉ាន់ ។ ការបដិសេធរបស់សម្តេច សីហនុ មិនព្រមទទួលជំនួយយោធាពីចិន ឆ្លុះបញ្ចាំងអំពីការបន្តនយោបាយរបស់ព្រះអង្គក្នុងការធ្វើឲ្យមានតុល្យភាព និងការប្រើល្បិចដ៏ប្រុងប្រយ័ត្នជាទីបំផុត ។ ក្រោយពីបានទៅកៀកនឹងចិនហើយ សម្តេច សីហនុ អន្ទះសាមិនចង់ដើរវិលងគោលបំណងរបស់ព្រះអង្គ ហើយលែងជិតស្និទ្ធនឹងសហរដ្ឋអាមេរិកនោះឡើយ ។

កិច្ចសហប្រតិបត្តិការរវាងចិននិងកម្ពុជាចេះតែបន្តរហូតដល់ទសវត្សរ៍ឆ្នាំ១៩៦០ ។ នៅឆ្នាំ១៩៦០ សម្តេច សីហនុ បានបញ្ជូនព្រះរាជបុត្របីព្រះអង្គឲ្យទៅសិក្សានៅប្រទេសចិន រួចបានបង្កើតសមាគមមិត្តភាពកម្ពុជា-ចិន ព្រមទាំងយល់ព្រមជាមួយសំណើរបស់ ជូ អេន ឡាយ ចង់បង្កើតនូវ "តំបន់សន្តិភាព" មួយនៅឥណ្ឌូចិន ។ ជិតដល់ចុងឆ្នាំនោះ សម្តេច សីហនុ បានយាងទៅទស្សនកិច្ចនៅទីក្រុងប៉េកាំង ហើយប្រទេសទាំងពីរបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពនិងការមិនឈ្លានពានគ្នា ។ សន្ធិសញ្ញាចែងថា ចិននិងកម្ពុជាត្រូវដើរតាមគោលនយោបាយមិនឈ្លានពានគ្នា ហើយភាគីទាំងពីរមិនត្រូវចូលប្លុកយោធាណាមួយដែលមានលក្ខណៈប្រឆាំងនឹងគ្នាទេ ។ ចិនទទួលបានជោគជ័យក្នុងការទប់ស្កាត់កម្ពុជាមិនឲ្យទទួលយកនូវ"ការគាំពារ" ពីសំណាក់អង្គការសន្ធិសញ្ញាអាស៊ី-អាគ្នេយ៍ ដែលហៅកាត់ថា "សេអាតូ" ។

នៅឆ្នាំ១៩៦២ ទាំងកម្ពុជា ទាំងចិន សុទ្ធតែមានជម្លោះជាមួយប្រទេសភូមិផងរបងជាមួយ ហើយប្រទេសទាំងពីរស្វែងរកការគាំទ្រពីគ្នាទៅវិញទៅមក ។ នៅពេលភាពតានតឹងរវាងកម្ពុជានិងថៃចេះតែកើនឡើងដោយសារជម្លោះព្រំដែន សម្តេច សីហនុ បានសុំឲ្យមានសន្និសីទអន្តរជាតិមួយដើម្បីធានានូវអធិបតេយ្យភាពប្រទេសរបស់ព្រះអង្គ និងកុំឲ្យមានការរំលោភព្រំដែន ។ ចិនបានគាំទ្រព្រះរាជសំណើរបស់សម្តេច សីហនុ ។ នៅពេលដែលទំនាក់ទំនងរវាងចិននិងឥណ្ឌាកាន់តែយ៉ាប់យ៉ឺន ក្រោយពីមានភាពតានតឹងចេះតែកើនឡើងនៅតាមព្រំដែនរបស់ផងខ្លួន ក្រុងប៉េកាំងបានស្វែងរកសមានចិត្តនិងការគាំទ្រជំហររបស់ខ្លួននៅក្នុងចំណោមបណ្តាប្រជាជាតិនៅអាស៊ី រួមទាំងកម្ពុជាផង ។ នៅថ្ងៃទី៨ ខែមិថុនា ជូ អេន ឡាយ បានពន្យល់អំពីជំហររបស់ចិនទាក់ទងនឹងជម្លោះព្រំដែនឥណ្ឌា-ចិន ទៅកាន់សម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេលទស្សនកិច្ចរបស់លោកនៅប្រទេសចិន ។ ជូ អេន ឡាយ និយាយថា ចិនប្រកាន់ខ្ជាប់នូវគោលការណ៍ពីរក្នុងការដោះស្រាយជម្លោះ ។ ទីមួយ រក្សាសភាពការណ៍ដូចសព្វថ្ងៃនៅតាមព្រំដែន ។ ទីពីរ ដោះស្រាយបញ្ហាតាមរយៈការចរចា ។ ចាប់តាំងពីពេលដែលចិនដោះស្រាយបញ្ហាព្រំដែនរបស់ខ្លួនជាមួយភូមានិងនេប៉ាល់តាមរយៈការចរចា និងចាប់តាំងពីចិនបានចាប់ផ្តើមការចរចាបញ្ហាព្រំដែនជាមួយប៉ាគីស្ថានមក ជូ អេន ឡាយ ចោទសួរថា ហេតុអ្វីបានជាចិននិងឥណ្ឌាមិនអាចដោះស្រាយបញ្ហាព្រំដែនរបស់ផងខ្លួនទៅតាមផ្លូវប្រហាក់ប្រហែលគ្នានោះទៅ?

នៅខែឧសភា ឆ្នាំ១៩៦៣ លីវ ចាវជី ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន បានអញ្ជើញមកធ្វើដំណើរកម្សាន្តនៅប្រទេសកម្ពុជា ។ ចាវជី បានសង្កត់ធ្ងន់ទៅលើគោលការណ៍សមភាពរវាងប្រជាជាតិនានានៅក្នុងកិច្ចការអន្តរជាតិ និងបានយល់ស្របជាមួយនឹងសេចក្តីអំពាវនាវរបស់ សម្តេច សីហនុ សុំឲ្យមានការរៀបចំសន្និសីទទីក្រុងហ្សឺណែវដ៏ពេញលេញមួយដើម្បីធានាបាននូវអព្យាក្រឹតភាពរបស់កម្ពុជា ។ សម្តេច សីហនុ បានរំឭកដល់ដំណើរទស្សនកិច្ចរបស់ លីវ ចាវជី ដោយយកឈ្មោះ ចាវជី ដាក់ឈ្មោះផ្លូវមួយនៅកម្ពុជាផង ។ ដំណើរទស្សនកិច្ចរបស់ ចាវជី ធ្វើឡើងនៅចំពេលដែល សម្តេច សីហនុ កំពុងតែរឹតបន្តឹងការធ្វើទុក្ខបុកម្នេញសមាជិកខ្មែរក្រហម (ជនកុម្មុយនិស្ត) ដែលត្រូវបានបង្ខំឲ្យដកថយទៅជនបទ ។ ដោយមានការចូលខ្លួនរបស់អាមេរិកនៅក្នុងបញ្ហាវៀតណាមខាងត្បូងកាន់តែខ្លាំងឡើងៗ ទីក្រុងប៉េកាំង និងទីក្រុងហាណូយ បាននាំគ្នាបញ្ចុះបញ្ចូលសម្តេច សីហនុ ឲ្យពិនិត្យមើលការពង្រីកសង្គ្រាមតាម

រយៈកម្ពុជា ។ វៀតណាមខាងជើងទទួលស្គាល់សិទ្ធិកម្មសិទ្ធិរបស់កម្ពុជាទៅលើកោះនានានៅក្នុងឈូងសមុទ្រថៃ ដែលអះអាងដោយរដ្ឋាភិបាលទីក្រុងសៃហ្គន ថា ជាកម្មសិទ្ធិរបស់ខ្លួន។ រដ្ឋកុម្មុយនិស្តចិននិងវៀតណាមខាងជើងកាន់តែមានការចាប់អារម្មណ៍ក្នុងការទុកសម្តេច សីហនុ ជាមិត្តជាជាងគាំទ្រការបះបោររបស់ក្រុមកុម្មុយនិស្តខ្មែរដែលប្រឆាំងនឹងអំណាចរបស់ព្រះអង្គ ។

ចិនបន្តគាំទ្រការអំពាវនាវរបស់សម្តេច សីហនុ ចង់ឲ្យមានសន្និសីទទីក្រុងហ្សឺណែវដើម្បីធានានូវអព្យាក្រឹតភាពរបស់កម្ពុជានៅឆ្នាំ១៩៦៤។ នៅក្នុងការជួបប្រជុំជាមួយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិននៅថ្ងៃទី៧ ខែកុម្ភៈ ឧបនាយករដ្ឋមន្ត្រី តេង ស៊ាវភីង បានកោតសរសើរសម្តេច សីហនុ ដែលបានអនុម័តលើនយោបាយការបរទេសឯករាជ្យ ហើយបានសរសើរ សម្តេចដែលប្រឆាំងនឹងសម្ពាធរបស់អាមេរិកាំង។ តេង ស៊ាវភីង បានបញ្ជាក់សាជាថ្មីនូវការយល់ស្របរបស់ចិនចំពោះសេចក្តីអំពាវនាវរបស់សម្តេចសុំឲ្យមានសន្និសីទអន្តរជាតិស្តីអំពីបញ្ហាកម្ពុជា ។

សម្តេច សីហនុ បានឆ្លើយតបទៅនឹងសុឆន្ទៈនិងការគាំទ្ររបស់ចិន ដោយទ្រង់បានលើកឡើងម្តងហើយម្តងទៀតអំពីទីក្រុងប៉េកាំងដែលមានតួនាទីនៅក្នុងបញ្ហាអន្តរជាតិ។ នៅខែសីហា ឆ្នាំ១៩៦៣ សម្តេចបានគាំទ្រដល់ជំហររបស់ក្រុងប៉េកាំង ស្តីពីការទាក់ទងនឹងសន្ធិសញ្ញាហាមឃាត់ការសាកល្បងអាវុធនុយក្លេអ៊ែរភាគខ្លះ ហើយបានយល់ស្របចំពោះការអំពាវនាវរបស់ចិនសុំឲ្យមានការហាមឃាត់ និងកម្ទេចចោលទាំងស្រុងនូវអាវុធនុយក្លេអ៊ែរ។ ជូ អេន ឡាយ បានសម្តែងនូវការកោតសរសើរចំពោះការគាំទ្ររបស់សម្តេច សីហនុ ជាច្រើនលើកច្រើនគ្រា ។

នៅឆ្នាំ១៩៦៥ មេដឹកនាំចិនមានចំណាប់អារម្មណ៍កាន់តែតិចក្នុងការគាំទ្រផែនការរបស់សម្តេច សីហនុ ដែលចង់ឲ្យមានសន្និសីទនៅទីក្រុងហ្សឺណែវស្តីអំពីបញ្ហាកម្ពុជា ដោយហេតុថា ចិនមានការព្រួយបារម្ភខ្លាចក្រែងសហរដ្ឋអាមេរិកនិងសហភាពសូវៀតយកកិច្ចប្រជុំនេះទៅពិភាក្សាអំពីដំណោះស្រាយដែលចរចានៅវៀតណាមរួចហើយ ។ នៅខែមេសា សម្តេច សីហនុ គោរពចំពោះការឲ្យយោបល់របស់ចិន ដោយទ្រង់ឈប់សុំឲ្យមានសន្និសីទទីក្រុងហ្សឺណែវស្តីអំពីបញ្ហាកម្ពុជាទៀតហើយ ។ នៅពេលដែលសម្តេច សីហនុ ផ្តាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិកនៅខែឧសភា ជូ អេន ឡាយ បានផ្ញើទូរលេខថ្វាយព្រះអង្គ ស្វាគមន៍ចំពោះការសម្រេចចិត្តរបស់ទ្រង់ ហើយសន្យាថា ប្រសិនបើសហរដ្ឋអាមេរិកធ្វើឲ្យសង្គ្រាមរាលដាលដល់កម្ពុជា "ចិននឹងមិនឈរស្ងៀមឱបដៃឡើយ" ។ នៅក្នុងកិច្ចសន្ទនាជាមួយសម្តេច សីហនុ នៅទីក្រុងប៉េកាំងនាថ្ងៃទី២៩ ខែកញ្ញា ម៉ៅ សេទុង បានសម្តែងការកោតសរសើរចំពោះនយោបាយរបស់កម្ពុជាក្នុងការប្រឈមមុខយ៉ាងក្លាហានទល់នឹងសហរដ្ឋអាមេរិក ថៃ និងវៀតណាមខាងត្បូង។ ម៉ៅ សេទុង បានហៅមាគ៌ាអន្តរជាតិរបស់សម្តេច សីហនុ ថា ជានយោបាយ "មានប្រជាប្រិយភាព" ។

នៅពេលដែលកុប្បកម្មក្រុមកុម្មុយនិស្តមានសភាពកាន់តែខ្លាំងឡើងៗនៅវៀតណាមខាងត្បូង សម្តេច សីហនុ បានអនុញ្ញាតឲ្យចិនប្រើប្រាស់ផ្លូវមួយខ្សែឆ្លងកាត់តាមផ្ទៃប្រទេសកម្ពុជាដើម្បីដឹកជញ្ជូនអាវុធយុទ្ធភ័ណ្ឌ គ្រាប់រំសេវ ស្បៀងអាហារនិងថ្នាំពេទ្យផ្តល់ឲ្យរណសិរ្សរំដោះជាតិនៅវៀតណាមខាងត្បូង។ នៅក្នុងចន្លោះឆ្នាំ១៩៦៥-១៩៦៧ អាវុធយុទ្ធភ័ណ្ឌរបស់ចិនសម្រាប់ផ្គត់ផ្គង់កងទ័ពចំនួន៥ម៉ឺននាក់ បានដឹកមកតាមកប៉ាល់កាត់តាមច្រកកំពង់ផែក្រុងព្រះសីហនុ។ អាវុធយុទ្ធភ័ណ្ឌមួយចំនួនត្រូវបានបំពាក់ដល់កងទ័ពកម្ពុជា ។

ក៏ប៉ុន្តែបដិវត្តន៍វប្បធម៌របស់ ម៉ៅ សេទុង ពិតជាធ្វើឲ្យមានមហន្តរាយយ៉ាងដំណំដល់ទំនាក់ទំនងរវាងចិននិងកម្ពុជា។ នៅទីក្រុងភ្នំពេញ ដោយមានការជំរុញពីភាពវឹកវរកាន់តែរីករាលដាលយ៉ាងឆាប់រហ័ស ជនជាតិចិនដែលមករស់នៅលើទឹកដីកម្ពុជាបានប្រកាសថា ខ្លួនមានភក្តីភាពចំពោះ ម៉ៅ សេទុង។ នៅដើមឆ្នាំ១៩៦៧ កូនខ្មែរកាត់ចិនបានដើរក្បួនបាតុកម្មនៅខាងក្រៅស្ថានទូតសហភាពសូវៀត។ គ្រូបង្រៀនដែលជាជនជាតិចិនធ្វើការជាមួយកងទ័ពកម្ពុជា បានចែកផ្ទាកសញ្ញារូប ម៉ៅ សេទុង ដល់កងទ័ពកម្ពុជា។ ក្រុមឆ្វេងនិយមខ្មែរបានយល់ព្រមជាចំហ

ដល់សមាគមមិត្តភាពកម្ពុជា-ចិន ដែលលើកសរសើរ ម៉ៅ សេទុង យ៉ាងសកម្មនៅតាមសាលា រៀនភាសាចិន។

សម្តេច សីហនុ មានការរំខានយ៉ាងខ្លាំងដោយសារឥទ្ធិពលនៃបដិវត្តន៍វប្បធម៌ចិន។ ទ្រង់បានសម្តែងព្រះទ័យភ័យខ្លាចប្រាប់នាយករដ្ឋមន្ត្រីអូស្ត្រាលី ហារ៉ូល ហុល នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់លោកលើកទីពីរមកកាន់ប្រទេសកម្ពុជា នាខែមីនា-មេសា ឆ្នាំ១៩៦៧។ សម្តេចមានព្រះបន្ទូលប្រាប់ ហារ៉ូល ហុល ថា ព្រះអង្គមិនយល់អំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងប្រទេសចិនទេ ហើយព្រះអង្គសម្តែងនូវការធុញថប់ចំពោះប្រទេសចិនដែលមេដឹកនាំ ម៉ៅ សេទុង ហាក់ដូចជាកាន់តែវង្វេងវង្វាន់ ខណៈដែលកិរិយារបស់លោកកំពុងតែចេញមុខជាមេដឹកនាំពិតប្រាកដ។ នៅខែសីហា សម្តេច សីហនុ បានបញ្ជូនព្រះអង្គម្ចាស់ នរោត្តម ភូរិស្សរ៉ា រដ្ឋមន្ត្រីការបរទេស ទៅកាន់ទីក្រុងប៉េកាំង ដើម្បីធ្វើឲ្យបានដឹងប្រាកដអំពីជំហរជាផ្លូវការរបស់ចិន។ ភូរិស្សរ៉ា បានយាងមកដល់ប្រទេសចិននៅចំពេលដែលឥទ្ធិពលពួកឆ្វេងនិយមជ្រុលនៅក្នុងក្រសួងការបរទេសឡើងដល់កំពូល។ ក្រសួងការបរទេសដែលគ្រប់គ្រងដោយពួកឆ្វេងនិយមជ្រុល ធ្វើមិនអើពើចំពោះ ជូ អេន ឡាយ។ សមត្ថភាពរបស់នាយករដ្ឋមន្ត្រីក្នុងការចាត់ចែងគោលនយោបាយការបរទេសចិនត្រូវកាត់បន្ថយយ៉ាងច្រើនអស់មួយរយៈ។ នៅថ្ងៃទី១៧ និង១៩ ខែសីហា ជូ អេន ឡាយ បានជួបជាមួយ ភូរិស្សរ៉ា។ យោងតាមប្រភពនានាមកពីបស្ចិមប្រទេសបានឲ្យដឹងថា ជូ អេន ឡាយ បានផ្តល់ភាពស្រាកស្រាន្ត ប៉ុន្តែបានអះអាងថា ចិនគួរតែ «ទទួលបានការអនុញ្ញាតឲ្យបង្ហាញនូវមោទកភាពចំពោះបដិវត្តរបស់ខ្លួន និងការស្រលាញ់ចំពោះលោកប្រធានម៉ៅ»។

សម្តេច សីហនុ ទ្រង់ព្រះពិរោធ ហើយមានប្រតិកម្មតាមរយៈការសម្រេចបិទសមាគមមិត្តភាពកម្ពុជា-ចិន បិទកាសែតជាភាសាចិនចំនួន៩ ព្រមទាំងប្រកាសដកទូតខ្មែរប្រចាំនៅទីក្រុងប៉េកាំងទៀតផង។ ដោយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការដើរថយក្រោយនៃទំនាក់ទំនងរវាងចិននិងកម្ពុជា ក៏ដូចជាការឆាឆៅបង្អាក់ដល់នយោបាយការបរទេសចិន ដែលជាទូទៅកើតឡើងដោយសារតែក្រសួងការបរទេសទទួលឥទ្ធិពលពីពួកឆ្វេងនិយមជ្រុលនៃក្រសួងការបរទេស នៅចុងខែសីហា ជូ អេន ឡាយ បានចាត់វិធានការកម្រិតឥទ្ធិពលឆ្វេងនិយមជ្រុលមកលើនយោបាយការបរទេស និងការពារសាជាថ្មីដល់ការគ្រប់គ្រងរបស់លោកទៅលើក្រសួងការបរទេស។ មុនដំបូង ជូ អេន ឡាយ បានថ្កោលទោសពួកឆ្វេងនិយមជ្រុលដែលធ្វើសេចក្តីសម្រេចទៅលើនយោបាយការបរទេសដោយគ្មានការពិគ្រោះពិភាក្សាជាមួយនឹងលោក។ បន្ទាប់មក ជូ អេន ឡាយ ឲ្យ យ៉ាង ឆេងវូ នាយរងសេនាធិការកងទ័ពរំដោះប្រជាជនចិន ជិះយន្តហោះទៅទីក្រុងសៀងហៃដើម្បីជួបលោកប្រធានម៉ៅ ព្រមទាំងបញ្ជាក់ប្រាប់លោកអំពីផលវិបាកជាអវិជ្ជមាននៃឥទ្ធិពលរបស់ពួកឆ្វេងនិយមជ្រុលនៅក្នុងក្រសួងការបរទេស។ ដើម្បីចូលរួមក្នុងការព្រួយបារម្ភរបស់ ជូ អេន ឡាយ នៅថ្ងៃទី២៦ ខែសីហា ប្រធាន ម៉ៅ បានចេញបញ្ជាឲ្យចាប់តំណាងនានារបស់ក្រុមឆ្វេងនិយមជ្រុលនៅក្នុងក្រសួងការបរទេស។ អន្តរាគមន៍របស់ ម៉ៅ បានបញ្ចប់នូវការគ្រប់គ្រងដ៏ទូលំទូលាយនិងឆាប់រហ័សទៅលើនយោបាយការបរទេសរបស់ចិន។ នៅថ្ងៃទី១៤ ខែសីហា និងថ្ងៃទី២៦ ខែតុលា ជូ អេន ឡាយ បានជួបប្រជុំជាមួយឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសចិនចំនួនពីរលើក ដោយសុំអភ័យទោសចំពោះឯកអគ្គរាជទូតខ្មែរអំពីនយោបាយរបស់ទីក្រុងប៉េកាំង។ ក្រោយពី ជូ អេន ឡាយ សម្តែងចេញនូវការសុំអភ័យទោសរួចមក សម្តេច សីហនុ បានរំលាយចោលនូវសេចក្តីសម្រេចចិត្តរបស់ព្រះអង្គដែលថា នឹងដកអ្នកការទូតខ្មែរពីប្រទេសចិន។

## ចំណងទាក់ទងរវាងទីក្រុងប៉េកាំងនិងខ្មែរក្រហមនៅឆ្នាំ ១៩៦៥-១៩៧០

យើងមានការយល់ដឹងតិចតួចណាស់អំពីទំនាក់ទំនងរវាងទីក្រុងប៉េកាំងនិងខ្មែរក្រហមនៅមុនឆ្នាំ១៩៧០។ មានឯកសារភ័ស្តុតាងមកពីចិនតិចតួចបំផុតទាក់ទងនឹងប្រធានបទនេះ។ នៅឆ្នាំ១៩៦៥ ប៉ុល ពត បានសម្រេចចិត្តជំរុញឲ្យមានការតស៊ូអាវុធនៅក្នុងប្រទេសកម្ពុជា។ យោងតាមសៀវភៅខ្មៅ និងប្រភពមកពីបស្ចិមប្រទេសបានឲ្យដឹងថា នៅក្នុងរដូវក្តៅឆ្នាំ ១៩៦៥ ប៉ុល ពត បានបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ ដើម្បីជួបប្រជុំជាមួយមេដឹកនាំកុម្មុយនិស្តវៀតណាម ប៉ុន្តែ

មេដឹកនាំកុម្មុយនិស្តវៀតណាមបានបដិសេធសំណើរបស់ ប៉ុល ពត ដែលចង់ធ្វើការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជា ។ ក្រោយពីបំពេញទស្សនកិច្ចនៅទីក្រុងហាណូយរួចមក ប៉ុល ពត បានធ្វើដំណើរទៅប្រទេសចិន ហើយបានស្នាក់នៅទីនោះអស់រយៈពេលជាច្រើនខែ ដែលក្នុងរយៈពេលនោះ ប៉ុល ពត បានធ្វើការជាមួយ តេង ស៊ាវភីង អគ្គលេខាបក្សកុម្មុយនិស្តចិន ។ យោងតាមសំណេររបស់ ដាវីដ ឆេនដល័រ ប៉ុល ពត ស្នាក់នៅប្រទេសចិនក្នុងដំណាក់កាលដំបូងនៃបដិវត្តន៍វប្បធម៌ ហើយជួយទំនុកបម្រុងដោយ កាង សេង ជាមន្ត្រីជាន់ខ្ពស់ចិន ទទួលបន្ទុកនគរបាលសម្ងាត់របស់ម៉ៅ ។ គ្មានភ័ស្តុតាងពីខាងចិនបញ្ជាក់អំពីរបាយការណ៍នៃដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ទៅប្រទេសចិននៅឆ្នាំ១៩៦៦ឡើយ ។ ទំនងជាថា មេដឹកនាំចិន យល់ស្រប



នឹងផែនការរបស់ ប៉ុល ពត ក្នុងការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជាហើយមើលទៅ ។

ភាពតានតឹងនៅក្នុងប្រទេសកម្ពុជាបានកើតឡើងនៅដើមឆ្នាំ១៩៦៧ ដោយការផ្ទុះចេញនូវការបះបោរប្រឆាំងនឹងរដ្ឋាភិបាលនៅម្តុំសំឡូតភាគខាងលិចខេត្តបាត់ដំបង ។ ភាពចលាចលធ្វើឲ្យរំខានយ៉ាងខ្លាំងដល់មេដឹកនាំចិន ដែលយល់ថាខ្លួនស្ថិតនៅក្នុងស្ថានភាពពិបាកក្នុងការសម្រេចចិត្តទៅលើបញ្ហាកម្ពុជា ។ ម៉្យាង មេដឹកនាំចិនពេញចិត្តនឹងនយោបាយអព្យាក្រឹតរបស់សម្តេច សីហនុ ពីព្រោះវាបានបម្រើឲ្យគោលបំណងរបស់ចិនក្នុងការទប់ស្កាត់ការពង្រីកសង្គ្រាមនៅជ្រោយឥណ្ឌូចិននិងកម្រិតឥទ្ធិពលរបស់ក្រុងហាណូយ ។ ការធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ បានរកកលធ្វើឲ្យមានសង្គ្រាមកាន់តែខ្លាំងនិង



*បង្ហាញគម្រោងកាន់តែច្បាស់អំពីការចូលរួមរបស់ក្រុងហាណូយនៅក្នុងចលនាបដិវត្តន៍កម្ពុជា ហើយដោយសារសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើអាវុធយុទ្ធភ័ណ្ឌទំនើបៗមកពីសូវៀតផងនោះ ធ្វើឲ្យឥទ្ធិពលរបស់ក្រុងមូស្គូនៅក្នុងតំបន់កាន់តែកើនឡើង ។ ម្យ៉ាងវិញទៀត មេដឹកនាំចិនយល់ឃើញថា វាជាការលំបាកនិងជាការអាម៉ាស់មុខក្នុងការជំទាស់ការបះបោរនៅសំឡូត ពីព្រោះមេដឹកនាំចិនជឿថា ការបះបោរនេះគឺបក្សកុម្មុយនិស្តកម្ពុជាជាអ្នករៀបចំឡើង ។ (នៅឆ្នាំ១៩៦៦ ប៉ុល ពត បានផ្លាស់ឈ្មោះបក្សរបស់ខ្លួន) ។ ការខកខានមិនបានយល់ស្របចំពោះការបះបោរនេះអាចធ្វើឲ្យខូចដល់មុខមាត់បដិវត្តន៍របស់ចិន ។*

*ដើម្បីដោះស្រាយនូវបញ្ហា "ចុះទឹកក្រពើ ឡើងលើខ្លា" ជូ អេន ឡាយ បានប្រឌិតនូវទ្រឹស្តីមួយគឺ "ធ្វើបដិវត្តន៍ជាដំណាក់ៗ" ក្នុងគោលបំណងបញ្ចុះបញ្ចូលជនកុម្មុយនិស្តខ្មែរកុំឲ្យធ្វើបដិវត្តន៍ប្រឆាំងនឹងសម្តេច សីហនុ ។ យោងតាមរូបមន្តរបស់ ជូ អេន ឡាយ ការតស៊ូប្រឆាំងនឹង ង្វៀន វ៉ាន់ធីវ នៅវៀតណាមខាងត្បូង គួរតែមានអាទិភាពជាងការបង្កើតកម្លាំងបដិវត្តនៅក្នុងប្រទេសកម្ពុជា ។ នាយករដ្ឋមន្ត្រីចិនបានពន្យល់អំពីទ្រឹស្តីនេះទៅ ផាម វ៉ាន់ ដុង និង វូ ង្វៀនយ៉ាប នៅក្នុងពេលសន្ទនាជាមួយគ្នានៅទីក្រុងប៉េកាំងចន្លោះថ្ងៃទី៧ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦៧ ។*

*នៅក្នុងពេលពិភាក្សាគ្នានៅថ្ងៃទី១០ ខែមេសា ជូ អេន ឡាយ បានលើកឡើងនូវបញ្ហាកម្ពុជា ដោយសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការ "ទទួលបាននូវសមានចិត្តរបស់សម្តេច សីហនុ" ពីព្រោះថា សម្តេចមានប្រយោជន៍ដល់ការដឹកជញ្ជូនសម្ភារទៅឲ្យរណសិរ្សរំដោះជាតិ ។ នៅពេលដែល ផាម វ៉ាន់ដុង សួរអំពីទស្សនៈរបស់ចិនចំពោះ លន់ ណុល ជូ អេន ឡាយ បានឆ្លើយថា ឧត្តមសេនីយ៍ខ្មែរ "មិនគួរទុកចិត្តសោះ" ចំណែកឯ ជិន អ៊ី អះអាងថា លន់ ណុល ជាអ្នក"គាំទ្រអាមេរិកាំង" ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជូ អេន ឡាយ ជឿថា លន់ ណុល អាចប្រើប្រាស់បានក្នុងការគាំទ្រសង្គ្រាមនៅវៀតណាមខាងត្បូងៈ "នៅពេល លន់ ណុល មកបំពេញទស្សនកិច្ចនៅចិន គាត់មានចំណាប់អារម្មណ៍មួយចំនួន ។ ប្រសិនបើយើងជះទឹកលុយទៅលើគាត់ យើងអាចប្រើគាត់បាននៅពេលណាមួយ" ។*

*ជូ អេន ឡាយ និយាយបន្តទៀតដោយសង្កត់ធ្ងន់ទៅលើភាពចាំបាច់ក្នុងការធ្វើការជាមួយសម្តេច សីហនុ និង លន់ ណុល នៅក្នុងកិច្ចជួបពិភាក្សាជាមួយ ផាម វ៉ាន់ ដុង នៅថ្ងៃបន្ទាប់ ។ ដោយសម្តែងចេញនូវការមិនយល់ស្របចំពោះការបះបោរនៅសំឡូត ជូ អេន ឡាយ បានបញ្ឆោកសាជាថ្មីអំពីចំណូលចិត្តរបស់ចិនក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើសង្គ្រាមនៅវៀតណាមខាងត្បូង និងស្វះស្វែងរករណសិរ្សរួបរួមមួយជាមួយរដ្ឋាភិបាលកម្ពុជា ។ ជូ អេន ឡាយ បាននិយាយថា "នៅខណៈនេះជ័យជម្នះរបស់វៀតណាមគឺជាអាទិភាពទីមួយ ។ ប្រសិនបើតំបន់នានានៅតាមព្រំដែនត្រូវបិទប្រកមិនឲ្យចេញចូល កងកម្លាំងប្រដាប់អាវុធនៅវៀតណាមខាងត្បូងនឹងជួបការលំបាក ពេលនោះកងកម្លាំងប្រដាប់អាវុធបដិវត្តកម្ពុជានឹងមិនអាចបន្តទៅមុខទៀតបានទេ ។ ការតស៊ូរបស់វៀតណាមគឺជាចំណាប់អារម្មណ៍ទូទៅរបស់ប្រជាជននៅជ្រោយឥណ្ឌូចិននិងភូមិភាគអាស៊ី-អាគ្នេយ៍ ។ ចំណែកឯជោគជ័យនៃការតស៊ូនេះគឺជាកត្តាកំណត់ ។ នៅក្នុងសភាពការណ៍បែបនេះ ការតស៊ូរបស់កម្ពុជា...មានទិសដៅមានកម្រិត...ត្រូវតែដឹងអំពីរបៀបយកប្រយោជន៍រួមជាធំ" ។ ជូ អេន ឡាយ បានជំរុញឲ្យវៀតណាមខាងជើងពន្យល់អំពី"តក្កវិជ្ជា"នេះដល់ជនកុម្មុយនិស្តកម្ពុជា ។ ផាម វ៉ាន់ ដុង និយាយថា ទីក្រុងហាណូយបានណែនាំការិយាល័យមជ្ឈិមរបស់ខ្លួនដែលប្រចាំនៅវៀតណាមខាងត្បូងឲ្យទៅទាក់ទងជាមួយ"ភាគីប្រជាជន"នៅក្នុងប្រទេសកម្ពុជារួចទៅហើយ ។ សេចក្តីកត់សម្គាល់របស់ ជូ អេន ឡាយ បង្ហាញថា ក្រុងប៉េកាំងមិនមានការទាក់ទងដោយផ្ទាល់ជាមួយបក្សកុម្មុយនិស្តកម្ពុជាទេនៅពេលនេះ ។ ការសន្មតជាមុនរបស់ ជូ អេន ឡាយ ដែលថាបក្សកុម្មុយនិស្តកម្ពុជាបានគ្រប់គ្រងសភាពការណ៍នៅបាត់ដំបងនោះ បង្ហាញថា ជូ អេន ឡាយ មិនបានដឹងអំពីសភាពការណ៍ជាក់ស្តែងនៅតាមជនបទកម្ពុជាទេ ។*

*ទីក្រុងហាណូយក៏បានភ្ជាប់សារសំខាន់ជាយុទ្ធសាស្ត្រដ៏ធំជាមួយកម្ពុជានៅពេលដែលសង្គ្រាមបដិវត្តនៅវៀតណាម*

ខាងត្បូងកាន់តែក្តៅឡើងៗ ។ ដោយអបអរជាមួយការយល់ព្រមតាមរបស់សម្តេច សីហនុ ចំពោះការផ្តល់ទីជម្រកនិងសិទ្ធិដឹកជញ្ជូនសព្វាវុធកាត់តាមក្រុងព្រះសីហនុនៃប្រទេសកម្ពុជា មេដឹកនាំបែក្សពលករវៀតណាមបានទទូចឲ្យជនកុម្មុយនិស្តកម្ពុជាមិនឲ្យតស៊ូអាវុធប្រឆាំងនឹងរដ្ឋាភិបាលឡើយ ។ ចាប់ពីឆ្នាំ១៩៦៧មក ការភ័យខ្លាចការចូលលុកលុយរបស់សហរដ្ឋអាមេរិកទៅលើមូលដ្ឋាននានារបស់វៀតណាមខាងជើងនៅកម្ពុជាបានធ្វើឲ្យអ្នកតាក់តែងនយោបាយនៅទីក្រុងហាណូយខ្វាយខ្វល់ ។ សារសំខាន់របស់សម្តេច សីហនុ ចំពោះមេដឹកនាំបក្សពលករវៀតណាមទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការជំទាស់ដែលត្រូវបានផ្សព្វផ្សាយយ៉ាងដោកដាំរបស់ព្រះអង្គ ចំពោះការលុកលុយណាមួយរបស់អាមេរិកចូលក្នុងទឹកដីកម្ពុជា ។ រាល់ការផ្លាស់ប្តូរណាមួយនៃជំហររបស់សម្តេច សីហនុ នឹងក្លាយទៅជាបញ្ហាដ៏ធ្ងន់ធ្ងរប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងធ្វើសង្គ្រាមរបស់ក្រុងហាណូយ ។

ចិននិងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមមានគំនិតស្របគ្នាចំពោះបញ្ហាកម្ពុជា ប៉ុន្តែគោលនយោបាយរបស់ប្រទេសទាំងពីរដែលស្រដៀងគ្នាគឺផ្អែកទៅលើមូលហេតុនិងគោលបំណងផ្សេងៗគ្នា ។ ទីក្រុងប៉េកាំងចង់ជំរុញឲ្យមានការផុសចេញនូវក្រុមរដ្ឋឯករាជ្យមួយក្រុមនៅលើជ្រោយឥណ្ឌូចិន ក្រោយពីសង្គ្រាមផុតរលត់ទៅ និងចង់បង្ការកុំឲ្យមានការគ្របដណ្តប់របស់វៀតណាមនៅក្នុងតំបន់ ។ ទីក្រុងហាណូយបានស្វះស្វែងបង្កើតឲ្យមានការរួបរួមគ្នាជាយុទ្ធសាស្ត្រនៅជ្រោយឥណ្ឌូចិន ដើម្បីប្រឈមមុខនឹងសម្ពាធរបស់អាមេរិកាំង ព្រមទាំងបង្កើតនូវដែនឥទ្ធិពលមួយនៅជ្រោយឥណ្ឌូចិន ដើម្បីធានាសន្តិសុខដល់វៀតណាមពេលសង្គ្រាមផុតរលត់ទៅ ។ ដូចដែលអ្នកសិក្សាស្រាវជ្រាវមួយរូបបានលើកឡើងយ៉ាងត្រឹមត្រូវ ផលប្រយោជន៍រួមគ្នារវាងក្រុងប៉េកាំងនិងក្រុងហាណូយនៅក្នុងសាមគ្គីភាពនៅជ្រោយឥណ្ឌូចិនប្រឆាំងនឹងសហរដ្ឋអាមេរិកគឺ «បិទបាំងនូវការប្រកួតប្រជែងដែលផុសចេញមកពីទស្សនៈមិនស្របគ្នាទៅលើទម្រង់អំណាចក្រោយពេលសង្គ្រាម ដែលអាចទទួលយកបានជាលក្ខណៈតំបន់» ។

បក្សកុម្មុយនិស្តកម្ពុជាសម្រេចចិត្តធ្វើការតស៊ូប្រដាប់អាវុធនៅខែមករា ឆ្នាំ១៩៦៨ ។ ការសម្រេចចិត្តនេះស្របពេលគ្នាជាមួយនឹងការខិតកាន់តែជិតរបស់ក្រុងហាណូយចូលមកភាគបូព៌ាប្រទេសកម្ពុជាដើម្បីបើកយុទ្ធនាការសង្គ្រាមវៀតណាម ។ សម្ពាធដែលចេះតែកើនឡើងជាលំដាប់របស់ក្រុមកុម្មុយនិស្តបានធ្វើឲ្យសម្តេច សីហនុ មានប្រតិកម្មយ៉ាងខ្លាំង ។ នៅចុងខែមករា រដ្ឋាភិបាលកម្ពុជាបានចាប់ខ្លួនជនកុម្មុយនិស្តវ័យក្មេងនៅទីក្រុងភ្នំពេញជាច្រើននាក់ដែលបោះពុម្ពខិតប័ណ្ណរិះគន់ប្រមុខរដ្ឋយូហ្គោស្លាវី ហ្សូសេប ប្រូស ទីតូ ដែលគ្រោងមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានាពេលឆាប់ៗខាងមុខ ។ នៅខែមីនា សម្តេច សីហនុ បានបញ្ជូនកងទ័ពអាកាសទៅបើកការវាយប្រហារទៅលើតំបន់នានាទូទាំងប្រទេសដែលសង្ស័យថា មានក្រុមកុម្មុយនិស្តកម្ពុជា ។

ភាពមិនស្រណុកក្នុងចិត្តរបស់មេដឹកនាំចិនទៅលើការវិវត្តន៍នៅក្នុងប្រទេសកម្ពុជា គឺសបញ្ជាក់ឲ្យឃើញតាមរយៈការជួបប្រជុំគ្នារវាង ជូ អេន ឡាយ ជាមួយនឹង ផាម ហុង លេខាការិយាល័យកណ្តាលប្រចាំនៅវៀតណាមខាងត្បូងដែលប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៦៨ ។ ក្រោយពីលើកឡើងអំពីប្រតិបត្តិការសឹករបស់បក្សកុម្មុយនិស្តកម្ពុជានៅភាគបូព៌ានៃប្រទេសកម្ពុជា ជូ អេន ឡាយ បានសួរទៅហុង ថា តើកងទ័ពវៀតណាមខាងជើងនៅក្នុងប្រទេសកម្ពុជាបានចែកចាយអាវុធយុទ្ធភ័ណ្ឌដល់ក្រុមកុម្មុយនិស្តកម្ពុជាដែរឬទេ? (ប្រតិចារឹកមិនមាននិយាយអំពីការឆ្លើយតបរបស់ ហុង ឡើយ) ។ ដោយទទូចថា ចិនមិនបានរក្សាទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជានោះ ជូ អេន ឡាយ និយាយថា ក្រុងប៉េកាំងមិនចង់ឲ្យស្ថានទូតរបស់ខ្លួនប្រចាំនៅកម្ពុជាបង្កើតនូវទំនាក់ទំនងជាមួយក្រុមកុម្មុយនិស្តកម្ពុជាទេ ដោយសារស្ថានការណ៍ស្មុគស្មាញនៅក្នុងប្រទេសនេះ ។ ជូ អេន ឡាយ ក៏បានលើកឡើងនូវភាពសាទររបស់វៀតណាមចំពោះប្រជាជនកម្ពុជាដែរ ។ ដោយយោងទៅលើរបាយការណ៍អំពី «អាកប្បកិរិយាមិនសមរម្យរបស់កម្មាភិបាលវៀតណាមខាងជើងចំពោះកម្មាភិបាលខ្មែរ» ជូ អេន ឡាយ បានសុំឲ្យ ហុង ជំរុញមន្ត្រីថ្នាក់ក្រោមរបស់ខ្លួន

នៅតាមមូលដ្ឋានឲ្យ "បង្ហាញនូវអាកប្បកិរិយាស្មើមុខ" ចំពោះជនកុម្មុយនិស្តកម្ពុជា ។

បន្ទាប់មក ជូ អេន ឡាយ សង្កត់ធ្ងន់សាជាថ្មី ទៅលើសារប្រយោជន៍នៃការផ្តោតជាសំខាន់ទៅលើបរាជ័យរបស់សហរដ្ឋអាមេរិកនៅវៀតណាមមុនពេលបង្កើតបដិវត្តន៍នៅកម្ពុជាៈ "កម្មាភិបាលកម្ពុជាចង់បង្កើតការតស៊ូប្រដាប់អាវុធ ។ សម្តេច សីហនុ បង្ក្រាបកម្មាភិបាល ដូច្នេះសមមិត្តលែងអាចចេញចូលប្រទេសកម្ពុជាបានទៀតហើយ... ។ ប្រសិនបើឥណ្ឌូចិនទាំងមូលចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងដេញអាមេរិកឲ្យអស់ពីវៀតណាម ពេលនោះបដិវត្តន៍ឡាវនិងកម្ពុជានឹងទទួលបានជោគជ័យ បើទោះជាមិនឆាប់ដូចដែលបានរំពឹងទុកក៏ដោយ" ។ ជូ អេន ឡាយ បានសុំឲ្យ ហុង ពិភាក្សាជាមួយជនកុម្មុយនិស្តខ្មែរ "អំពីរបៀបចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងវាយប្រយុទ្ធជាមួយនឹងជនជាតិអាមេរិកាំងជាមុន រួចហើយវាយប្រឆាំងនឹងពួកប្រតិកិរិយានៅក្នុងប្រទេសកម្ពុជា" ។ ទាក់ទងនឹងកងទ័ពវៀតណាមខាងជើងនៅប្រទេសកម្ពុជា ជូ អេន ឡាយ បានជំរុញឲ្យ ហុង រំឭកពួកគេអំពី "បរិបទរួម"នៃការតស៊ូនៅជ្រោយឥណ្ឌូចិនថាៈ "សមមិត្តគួរតែពន្យល់ឲ្យគេយល់អំពីរបៀបដោះស្រាយជាអន្តរជាតិ និងយល់ថាមនុស្សម្នាក់មិនអាចទៅវាយជាមួយខ្មាំងច្រើននាក់ក្នុងពេលតែមួយបានទេ" ។ នៅពេលហៀបនឹងបញ្ចប់កិច្ចសន្ទនា ជូ អេន ឡាយ បានសួរទៅ ហុង អំពីសាវតាររបស់ ប៉ុល ពត ថាៈ "ខ្ញុំឮសមមិត្ត ផាម វ៉ាន់ ដុង និយាយថា អគ្គលេខាបក្សកុម្មុយនិស្តខ្មែរទទួលសញ្ញាប័ត្រពីប្រទេសបារាំង ហើយធ្លាប់ធ្វើដំណើរទៅក្រុងហាណូយ?" ។ សំណួរបែបនេះបង្ហាញថា ចិនស្គាល់ ប៉ុល ពត តិចតួចណាស់ ។

ការបះបោររបស់ពួកកុម្មុយនិស្តនៅប្រទេសកម្ពុជានៅអំឡុងឆ្នាំ១៩៦៨-១៩៦៩ បានជំរុញឲ្យសម្តេច សីហនុ ងាកទៅរកនយោបាយស្តាំនិយម ។ នៅខែធ្នូ ឆ្នាំ១៩៦៨ សម្តេចបានចេញបញ្ជាឲ្យកងទ័ពរបស់ព្រះអង្គពង្រឹងការកាន់កាប់គ្រប់គ្រងទៅលើជនកុម្មុយនិស្តវៀតណាមដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ហើយនៅដើមឆ្នាំ១៩៦៩ ព្រះអង្គបានចាប់ផ្តើមការចរចាឡើងវិញជាមួយទីក្រុងវ៉ាស៊ីនតោន ។ នៅខែមេសា រដ្ឋការនិចសុនយល់ព្រមគោរព "អធិបតេយ្យភាព និង អព្យាក្រឹតភាព" របស់កម្ពុជា ។ នៅថ្ងៃទី១១ ខែមិថុនា ទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិកនិងកម្ពុជាត្រូវបានបើកឡើងវិញ ។ មិនត្រឹមតែស្នើឲ្យមានទំនាក់ទំនងការទូតសាកល្បងប៉ុណ្ណោះទេ សម្តេច សីហនុ ថែមទាំងបានចាប់ផ្តើមប្រតិបត្តិការស្ថានបេសកកម្មពាណិជ្ជកម្មរបស់រណសិរ្សរំដោះជាតិ (វៀតណាមខាងត្បូង) ប្រចាំនៅទីក្រុងភ្នំពេញ ឡើងដល់ឋានៈជាស្ថានទូត ។ ការបោះជំហានទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញនូវទង្វើប្រកបដោយតុល្យភាពពិសេសរបស់ព្រះអង្គ ។ សម្តេច សីហនុ ដែលនៅតែធ្វើឲ្យប្រទេសរបស់ព្រះអង្គចាកផុតពីសង្គ្រាមនោះ បានប្រកាសនៅខែមេសា ឆ្នាំ១៩៦៩ ថា ព្រះអង្គនឹងផ្លាស់ប្តូរជំហរជាមួយវៀតណាមតែនៅពេលណាសម្ពាធរបស់ជនកុម្មុយនិស្ត កាន់តែមានលក្ខណៈខ្លាំងពេកប៉ុណ្ណោះ ទើបកងទ័ពកម្ពុជាត្រូវតែទប់ទល់ ។

ការបង្កើនទំនាក់ទំនងរបស់សម្តេច សីហនុ ជាមួយសហរដ្ឋអាមេរិក ធ្វើឲ្យរំខានដល់មេដឹកនាំចិន ។ នៅក្នុងកិច្ចប្រជុំជាមួយ ផាម វ៉ាន់ ដុង នៅទីក្រុងប៉េកាំងនាថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦៩ ជូ អេន ឡាយ បានវាយតម្លៃប្រកបដោយទុទិដ្ឋិនិយមអំពីសភាពការណ៍នៅកម្ពុជា ។ ដោយកត់សម្គាល់ទៅលើការទទួលស្គាល់របស់រដ្ឋការ និចសុន ចំពោះព្រំដែនកម្ពុជា លោកនាយករដ្ឋមន្ត្រីចិននិយាយថា នយោបាយរបស់ និចសុន ចំពោះកម្ពុជា "មានលក្ខណៈឆ្លាតវៃជាង" នយោបាយរបស់និចសុន ។ ជូ អេន ឡាយ បានសម្តែងឲ្យឃើញនូវការមិនទុកចិត្តចំពោះសម្តេច សីហនុ ដោយហៅនយោបាយរបស់មេដឹកនាំកម្ពុជាថា ជា "ការបោកប្រាស់" និង "លម្អៀងទៅរកស្តាំនិយម" ។

នៅចុងឆ្នាំ១៩៦៩ ប៉ុល ពត បានដឹកនាំគណៈប្រតិភូមួយក្រុមទៅទីក្រុងហាណូយ ដើម្បីពិភាក្សាជាមួយមេដឹកនាំវៀតណាម ។ ដោយប្រមើលឃើញថា លន់ ណុល អាចនឹងទទួលបានអំណាចនៅកម្ពុជាក្រោមការគាំពារពីសហរដ្ឋអាមេរិកនោះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានអះអាងថា ប្រការនេះនឹងអាចបង្កលក្ខណៈងាយស្រួលដល់បដិវត្តន៍កម្ពុជា ពីព្រោះពេលនោះ សម្តេច សីហនុ នឹងចូលរួមខាងជនកុម្មុយនិស្តប្រឆាំងនឹងពួកស្តាំ និងសហរដ្ឋអាមេរិក ។ ដោយមិនទាន់សុខចិត្តឲ្យសម្តេច

សីហនុ ត្រូវផ្តួលរំលំ វៀតណាមបានបន្តចាត់ទុកផលប្រយោជន៍បដិវត្តន៍កម្ពុជាទាបជាងផលប្រយោជន៍បដិវត្តន៍វៀតណាម ។ ឡេ យន់ បានប្រាប់ទៅគណៈប្រតិភូបក្សកុម្មុយនិស្តកម្ពុជាឲ្យជៀសវាងការតស៊ូអាវុធ និង“រង់ចាំលុះដល់វៀតណាមឈ្នះសិន ។ នៅពេលនោះយើងនឹងវាយតែមួយព្រឹបរំដោះឲ្យបានទីក្រុងភ្នំពេញ” ។

ការសម្រេចចិត្តរបស់ ប៉ុល ពត ក្នុងការបន្តការតស៊ូអាវុធនៅក្នុងប្រទេសកម្ពុជា សបញ្ជាក់ឲ្យឃើញថា ប៉ុល ពត មិនមែនជាឧបករណ៍របស់ទីក្រុងហាណូយ ហើយក៏មិនមែនជាឧបករណ៍របស់ទីក្រុងប៉េកាំងដែរ ។ ទស្សនៈយោបល់និងអាទិភាពនានារបស់ខ្មែរក្រហម មានលក្ខណៈផ្ទុយនឹងទស្សនវិស័យនិងការព្រួយបារម្ភជាលក្ខណៈតំបន់របស់វៀតណាមខាងជើងនិងចិន ។ ទស្សនវិស័យមើលទៅមុខមិនវែងឆ្ងាយ និងផលប្រយោជន៍ដែលមានលក្ខណៈតំបន់របស់បក្សកុម្មុយនិស្តកម្ពុជាជួយឲ្យបក្សកុម្មុយនិស្តកម្ពុជាមានលទ្ធភាពរកឃើញនូវការគំរាមកំហែងនិងឱកាសនានា ជាងជនកុម្មុយនិស្តចិននិងវៀតណាម ដែលកម្រិតផលប្រយោជន៍របស់ខ្លួន បន្ទុចបន្ទាក់មិនឲ្យមានការផ្តោតការយកចិត្តទុកដាក់ពេញទំហឹងនិងបានយូរទៅលើបញ្ហាតំបន់ៗ ប៉ុល ពត និងបក្សពួក យល់ថា ព្រឹត្តិការណ៍តំបន់គឺជាមូលដ្ឋានដែលបង្កើតជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនផ្សេងទៀត (តាមដែលអ្នកគាត់តែងនយោបាយទីក្រុងប៉េកាំងនិងហាណូយយល់ឃើញ) ដែលប្រជែងគ្នាទាក់ទាញចង់បានការយកចិត្តទុកដាក់និងធនធាន ។ ខ្មែរក្រហមបានឆ្លៀតយកប្រយោជន៍ពីវត្តមានរបស់ជនកុម្មុយនិស្តវៀតណាមនៅក្នុងប្រទេសដើម្បីជំរុញបុព្វហេតុរបស់ខ្លួន ។

## ប្រតិកម្មរបស់ចិនចំពោះរដ្ឋប្រហារឆ្នាំ១៩៧០

នៅដើមខែមករា ឆ្នាំ១៩៧០ សម្តេច សីហនុ បានធ្វើដំណើរទៅកាន់ទីក្រុងប៉ារីស ដោយមានព្រះបន្ទូលថា ទៅព្យាបាលរោគ ប៉ុន្តែតាមការពិតព្រះអង្គបានប្រើអវត្តមានរបស់ព្រះអង្គដើម្បីឆ្លៀតយកប្រយោជន៍ពីគូបដិបក្ខក្នុងស្រុកគឺ សិរិមតៈ និងប្រើជំនាញការទូតរបស់ព្រះអង្គជាមួយទីក្រុងមូស្គូនិងទីក្រុងប៉េកាំងដែលព្រះអង្គរំពឹងថានឹងយាងទៅបំពេញទស្សនកិច្ចបន្ទាប់ពីយាងត្រឡប់មកពីប៉ារីសវិញ ក្នុងគោលបំណងបន្ធូរសម្ពាធពីវៀតណាមដែលគ្របសង្កត់មកលើប្រទេសរបស់ព្រះអង្គ ។ នៅខណៈដែលព្រះអង្គយាងទៅក្រៅប្រទេស នាយករដ្ឋមន្ត្រី លន់ ណុល បានបង្កើតសកម្មភាពប្រឆាំងនឹងវៀតណាម រួមទាំងការវាយប្រហារមកលើទីតាំងរបស់វៀតណាមខាងជើងនិងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងដែលឈរជើងនៅក្នុងប្រទេសកម្ពុជា ។ នៅថ្ងៃទី១១ ខែមីនា ការតវ៉ាក្នុងទ្រង់ទ្រាយធំបានកើតឡើងនៅក្រៅការិយាល័យក្រុមបេសកកម្មសាធារណរដ្ឋប្រជា-ធិបតេយ្យវៀតណាម និងរណសិរ្សរំដោះជាតិប្រចាំនៅទីក្រុងភ្នំពេញ ។ បាតុករបានបំបែកខ្លួនជាពីរក្រុម ដើរដុតឯកសារ និងបណ្តេញអ្នកការទូតវៀតណាមទាំងកម្រោល ។

មេដឹកនាំចិនបានឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ចំពោះការបត់បែនយ៉ាងគំហុកផងកទៅរកលទ្ធិស្តាំនិយមនៅក្នុងប្រទេសកម្ពុជា ។ ជូ អេន ឡាយ ប្រាប់ទៅឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសចិន ណៃ វ៉ាឡង់តាំង នៅថ្ងៃទី១៨ ខែមីនា ថា “រដ្ឋាភិបាលចិនមានការខ្វាយខ្វល់ចំពោះព្រឹត្តិការណ៍ថ្មីៗដែលកើតឡើងនៅទីក្រុងភ្នំពេញ” ។ ក្រោយពីសម្តែងនូវការសោកស្តាយព្រមជាមួយនឹងការបំផ្លាញអគារការទូតរបស់សាធារ-ណរដ្ឋប្រជាធិបតេយ្យវៀតណាមនិងរណសិរ្សរំដោះជាតិនៅទីក្រុងភ្នំពេញរួចមក នាយករដ្ឋមន្ត្រីចិនបានទាញចំណាប់អារម្មណ៍របស់ឯកអគ្គរាជទូតខ្មែរឲ្យផ្តោតទៅលើការលេចចេញនូវពាក្យស្លោករបស់កុប្បករ និងពាក្យចចាមអារ៉ាមប្រហាក់ប្រហែលគ្នានឹងសកម្មភាពដែលនឹងកើតឡើងប្រឆាំងនឹងស្ថានទូតចិន ។ ជូ អេន ឡាយ ថែមទាំងបានសម្តែងនូវការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់សម្តេច សីហនុ ដែរថាៈ “ពួកគេរាយការណ៍មកថា សម្តេច សីហនុ មានគម្រោងចាកចេញពីទីក្រុងមូស្គូនៅថ្ងៃទី១៦ ហើយមកដល់ទីក្រុងប៉េកាំងនៅថ្ងៃទី១៧ ។ ដូចនេះសំខាន់ជាងអ្វីៗទាំងអស់គឺធ្វើយ៉ាងណាចាត់វិធានការការពារសុវត្ថិភាពរបស់ព្រះអង្គឲ្យបាន ។ យើងគាំទ្រគោលនយោបាយសន្តិភាព អព្យាក្រឹតភាព និងឯករាជ្យភាពរបស់ព្រះអង្គ” ។

ជាការប្រមើលដល់លទ្ធភាពកុប្បកម្មប្រឆាំងនឹងចិនដែលអាចកើតឡើងនៅក្នុងប្រទេសកម្ពុជា ជូ អេន ឡាយ បាន

និយាយទៅកាន់ឯកអគ្គរដ្ឋទូតកូរ៉េខាងជើងប្រចាំនៅប្រទេសចិននៅថ្ងៃទី១៦ ខែមីនា ថា ប្រសិនបើស្ថានទូតចិននៅកម្ពុជាត្រូវបំផ្លិចបំផ្លាញ ហើយការទាក់ទងតាមទូរលេខត្រូវបង្អាក់នោះ ក្រុងប៉េកាំងចង់រក្សានូវទំនាក់ទំនងជាមួយកម្ពុជាតាមរយៈក្រុងព្យុងយ៉ាង ពោលគឺតាមរយៈស្ថានទូតកូរ៉េខាងជើងប្រចាំនៅទីក្រុងភ្នំពេញ ។

សម្តេច សីហនុ បានពន្យារការស្នាក់នៅរបស់ព្រះអង្គនៅទឹកដីសហភាពសូវៀត ដើម្បីជួបពិភាក្សាបន្ថែមទៀតជាមួយមេដឹកនាំសូវៀត ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ព្រះអង្គ សម្តេច សីហនុ បង្ហាញថា វិមានក្រឹមឡាំងបានរៀបចំខ្លួនរួចជាស្រេចក្នុងការផ្តល់ជំនួយផ្នែកយោធាដល់កម្ពុជា ។ នៅថ្ងៃទី១៩ ខែមីនា នៅពេលដែលសម្តេច សីហនុ កំពុងគង់ប្រថាប់នៅទីក្រុងមូស្គូ លន់ ណុល បានធ្វើរដ្ឋប្រហារទម្លាក់ទ្រង់ចេញពីអំណាច ។ របបថ្មីទាមទារឲ្យកងទ័ពបដិវត្តវៀតណាមដកចេញពីកម្ពុជា ។ នៅក្នុងដំណើរយ៉ាងប្រញាប់ប្រញាល់ទៅព្រលានយន្តហោះទីក្រុងមូស្គូ នាយករដ្ឋមន្ត្រីសូវៀត កូហ្ស៊ីហ្គីន បានទូលថ្វាយសម្តេច សីហនុ ថា សម្តេចត្រូវបានសភាជាតិបោះឆ្នោតទម្លាក់ពីតំណែងហើយ ។ សម្តេចបានហៅទង្វើនេះថាជាទង្វើមិនស្របទៅតាមរដ្ឋធម្មនុញ្ញ និងជាទង្វើអសីលធម៌ ដោយអះអាងថា ទ្រង់នឹងប្រយុទ្ធប្រឆាំងនឹងចក្រពត្តិឲ្យអស់ពីព្រះកាយពលរបស់ព្រះអង្គ ។

ជាការបង្ហាញនូវភាពមិនស្រុះស្រួលគ្នារវាងសម្តេច សីហនុ និងចិន កូហ្ស៊ីហ្គីន បានទូលថ្វាយសម្តេច សីហនុ ថា “សម្តេច! សូមសម្តេចជឿជាក់ចុះថា សហភាពសូវៀតនឹងគាំទ្រការតស៊ូរបស់សម្តេច...។ សម្តេចនឹងទតឃើញថាការតស៊ូធ្វើឡើងជាមួយចិននោះវាយ៉ាងដូចម្តេច ។ គេជួយសម្តេចបានតែនៅពេលសម្តេចកាន់អំណាចនៅភ្នំពេញប៉ុណ្ណោះ ប៉ុន្តែដល់ឥឡូវសម្តេចលែងមានអំណាចទៀតហើយនោះ សម្តេចនឹងទតឃើញនូវអ្វីដែលគេនឹងធ្វើចំពោះព្រះអង្គហើយ” ។ ដោយនៅតែជឿជាក់ទៅលើការយល់ព្រមរបស់ចិន ទ្រង់មានព្រះបន្ទូលតបវិញថា “ខ្ញុំនឹងបន្តដំណើរទៅទីក្រុងប៉េកាំង ហើយសុំការគាំទ្រពីមិត្តចាស់របស់ខ្ញុំ គឺ ជូ អេន ឡាយ” ។ ឆន្ទៈរបស់ក្រុងមូស្គូដែលចង់ផ្តល់ជំនួយយោធាដល់កម្ពុជា និងការប៉ុនប៉ងរបស់ កូហ្ស៊ីហ្គីន ចង់ធ្វើឲ្យសម្តេច សីហនុ និងក្រុងប៉េកាំងមិនត្រូវគ្នានោះ សបញ្ជាក់ឲ្យឃើញថា សូវៀតកំពុងតែប្រកួតប្រជែងជាមួយចិនក្នុងការស្វែងរកឥទ្ធិពលលើប្រទេសកម្ពុជា ។

ក្រោយពីទទួលពត៌មានថា លន់ ណុល បានធ្វើរដ្ឋប្រហាររួចមក ជូ អេន ឡាយ បានជួបជាមួយ ម៉ៅ ដើម្បីពិភាក្សាអំពីការឆ្លើយតបរបស់ចិន ។ ដោយបានថ្កោលទោសចំពោះការធ្វើរដ្ឋប្រហារដែលជាការពង្រីកនយោបាយអាមេរិកនៅជ្រោយឥណ្ឌូចិននោះ ម៉ៅ ទទូចថា ចិននឹងមិនទទួលស្គាល់របប លន់ ណុល ទេ ហើយថា ចិននឹងចាត់ទុកសម្តេច សីហនុ ជាប្រមុខរដ្ឋដដែល នៅពេលដែលព្រះអង្គយាងមកដល់ទីក្រុងប៉េកាំង ។ ម៉ៅ បានបញ្ចប់សេចក្តីថា ចិននឹងគាំទ្រការតស៊ូរបស់កម្ពុជាប្រឆាំងនឹងសហរដ្ឋអាមេរិក ។ បន្ទាប់មកចូរពិនិត្យមើលថា តើសម្តេច សីហនុ ប្រកាន់យកជំហរបែបណា ។ ដើម្បីអនុវត្តតាមសេចក្តីណែនាំរបស់ ម៉ៅ ជូ អេន ឡាយ បានជម្រាបទៅក្រសួងការបរទេសឲ្យរៀបចំទទួលសម្តេច សីហនុ ហើយជំរុញឲ្យឯកអគ្គរដ្ឋទូតបរទេសប្រចាំនៅទីក្រុងប៉េកាំង អញ្ជើញទៅព្រលានយន្តហោះដើម្បីស្វាគមន៍ព្រះអង្គ ។

ជូ អេន ឡាយ បានទៅទទួលសម្តេច សីហនុ ដែលមានព្រះកាយញ័រចំប្រប់ នៅព្រលានយន្តហោះទីក្រុងប៉េកាំងនៅថ្ងៃទី១៩ ខែមេសា ។ នៅក្នុងកិច្ចប្រជុំដែលរៀបចំក្រោយពីដំណើរយាងមកដល់របស់សម្តេច សីហនុ ជូ អេន ឡាយ បានទូលថ្វាយទ្រង់ថា ចិននៅតែទទួលស្គាល់ព្រះអង្គថា ជាប្រមុខរដ្ឋដដែល ។ ជូ អេន ឡាយ បន្តទៀតថា “ក្រោយពីមានខបទ្វហេតុនេះរួចមក សម្តេចបានប្រកាសថា ទ្រង់នឹងមិនយាងត្រឡប់ទៅប្រទេសកម្ពុជាភ្លាមឡើយ ។ បន្ទាប់មក ព្រះអង្គមិនបានធ្វើតាមព្រះបន្ទូលរបស់ទ្រង់ទេ ។ យើងមានអារម្មណ៍ថា យកល្អទ្រង់មិនគួរយាងត្រឡប់ទៅវិញទេ” ។ សម្តេច សីហនុ មានព្រះបន្ទូលថា នៅក្នុងសភាពការណ៍ក្នុងពេលនោះ ទ្រង់មិនអាចយាងត្រឡប់ទៅវិញបានទេ ហើយចង់ស្នាក់នៅប្រទេសចិនមួយរយៈសិន ។

ក្រោយពីមានការពិភាក្សាជាមួយសម្តេច សីហនុ ជូ អេន ឡាយ បានបើកកិច្ចប្រជុំគណៈកម្មាធិការនយោបាយដើម្បីពិភាក្សាទៅ

លើសភាពការណ៍នៅកម្ពុជា និងសំណើរបស់សម្តេច សីហនុ ដើម្បីជួបជាមួយអ្នកកាសែត និងចែកចាយសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ។ នៅឯកិច្ចប្រជុំនោះមានការសម្រេចឲ្យជួយសម្តេច សីហនុ នៅក្នុងព្រះរាជសកម្មភាពនានារបស់ព្រះអង្គ នៅទីក្រុងប៉េកាំង និងរៀបចំខ្លួនរង់ចាំឱកាសដែលស្ថានទូតចិនប្រចាំនៅភ្នំពេញត្រូវបំផ្លិចបំផ្លាញ ហើយជនជាតិចិននៅកម្ពុជាត្រូវចាប់ខ្លួន។ នៅថ្ងៃបន្ទាប់ ជូ អេន ឡាយ បានរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូន ម៉ៅ ហើយ ម៉ៅ ក៏យល់ព្រមចំពោះសេចក្តីសម្រេចទាំងនោះ ។ ទន្ទឹមពេលគ្នានេះដែរ ជូ អេន ឡាយ បានចុះហត្ថលេខាលើទូរលេខរបស់ក្រសួងការបរទេស ផ្ញើជូនឯកអគ្គរដ្ឋទូតចិនប្រចាំនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម វ៉ាង យូភីង ជាការណែនាំឲ្យលោកពាំនាំលទ្ធផលនៃកិច្ចប្រជុំជាមួយសម្តេច សីហនុ ទៅជម្រាបជូនថ្នាក់ដឹកនាំវៀតណាម ដើម្បីបញ្ជាក់អំពីការគាំទ្ររបស់ចិនចំពោះសម្តេច សីហនុ ហើយចាំទទួលមតិយោបល់របស់ក្រុងហាណូយអំពីវិបត្តិកម្ពុជាវិញ ។

រដ្ឋប្រហារនៅប្រទេសកម្ពុជាបានធ្វើឲ្យថ្នាក់ដឹកនាំចិនភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ថ្នាក់ដឹកនាំចិនជឿថា ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិកជាអ្នករៀបចំចាត់ចែងឲ្យមានឧបទ្ទវហេតុនេះឡើង ។ ទោះបីជាខ្លួនសម្រេចចិត្តគាំទ្រសម្តេច សីហនុ (ដើម្បីពង្រឹងជំហររបស់ខ្លួនប្រកួតប្រជែងជាមួយសូវៀត និងវៀតណាម) យ៉ាងណាក៏ដោយ ប៉ុន្តែចិនមិនប្រាកដប្រជាអំពីផែនការយូរអង្វែងទៅថ្ងៃមុខរបស់សម្តេច សីហនុ ដែលជាក្សត្រឆាប់ប្រែប្រួលនោះដែរ ។ ទោះជាចិននិយាយថា ខ្លួនមិនគាំទ្ររបប លន់ ណុល ក៏ដោយ ក៏ចិននៅតែមិនអស់សង្ឃឹមទាំងស្រុងទៅលើឧត្តមសេនីយ៍របស់កម្ពុជាដែលធ្វើរដ្ឋប្រហារនេះ ហើយដែលធ្លាប់ទៅបំពេញទស្សនកិច្ចនៅប្រទេសចិនកាលពីឆ្នាំមុន នៅក្នុងឱកាសចូលរួមកិច្ចប្រជុំនាថ្ងៃទី១ ខែតុលា ដើម្បីរំឭកខួបអនុស្សាវរីយ៍លើកទី២០នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន ។ ភាពជុំយគ្នាខាងផ្លូវគំនិតស្តែងឲ្យឃើញយ៉ាងច្បាស់នៅក្នុងកិច្ចសន្ទនារវាង ជូ អេនឡាយ ជាមួយ ផាម វ៉ាន់ដុង នៅទីក្រុងប៉េកាំងនៅថ្ងៃទី២១ ខែមីនា ។ ក្រោយពីកត់សម្គាល់ចំណាប់អារម្មណ៍របស់ប៉ារាំងទៅលើការបន្តនយោបាយអព្យាក្រឹតរបស់កម្ពុជា និងឥរិយាបថរបស់របបលន់ណុលចំពោះក្រុងមូស្គូនិងក្រុងប៉េកាំងនៅពីរថ្ងៃចុងក្រោយរួចមក ដែលរួមមានចំណាត់វិធានការសន្តិសុខដើម្បីការពារស្ថានទូតចិននិងសូវៀតប្រចាំនៅទីក្រុងភ្នំពេញ ជូ អេន ឡាយ បានប្រាប់ទៅ ផាម វ៉ាន់ដុង ថាៈ «យើងគួរតែគាំទ្រសម្តេច សីហនុ នៅពេលនេះ ហើយចាំមើលព្រះរាជសកម្មភាពរបស់ព្រះអង្គ ។ យើងនឹងគាំទ្រ ព្រះអង្គ ពីព្រោះព្រះអង្គគាំទ្រការតស៊ូប្រឆាំងអាមេរិកនៅក្នុងប្រទេសវៀតណាម... ។ យើងនឹងមើលទៅទៀតថា តើសម្តេចពិតជាចង់បង្កើតរណសិរ្សរួបរួមជាតិដើម្បីប្រឆាំងអាមេរិកដែរឬទេ មុននឹងយើងគាំទ្រព្រះអង្គ ។ ប៉ុន្តែដោយសារកាលៈទេសៈ ទ្រង់អាចផ្លាស់ប្តូរជំហរ ។ តែទោះជាយ៉ាងណា ទទួលបាននូវសមានចិត្តពីព្រះអង្គច្រើនកាលណា កាន់តែល្អកាលនោះ» ។

នាយករដ្ឋមន្ត្រីចិនបានសួរទៅសមភាគីខាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម អំពីមតិយោបល់ទៅលើការចរចាជាមួយរបប លន់ ណុល សិរិមតៈ ។ ផាម វ៉ាន់ដុង ឆ្លើយតបទៅវិញថា មុនពេលធ្វើដំណើរមកបំពេញទស្សនកិច្ចនៅទីក្រុងប៉េកាំង ថ្នាក់ដឹកនាំក្រុងហាណូយបានពិភាក្សារួចស្រេចទៅហើយអំពីបញ្ហានេះ ហើយបានសម្រេចថា «ការចរចានឹងមិនអាចនាំមកនូវលទ្ធផលឡើយ ពីព្រោះគេអាចនឹងវាយយើងដោយចៃដន្យ» ។ ជាការច្បាស់ណាស់ វៀតណាមខាងជើងមិនយល់ច្រឡំទៅលើ លន់ ណុល សិរិមតៈទេ ។ ការសន្ទនារវាង ជូ អេន ឡាយ និង ផាម វ៉ាន់ដុង បង្ហាញនូវការឯកភាពយោបល់គ្នារវាងភាគីទាំងពីរនៅក្នុងការប្រព្រឹត្តមកលើរបប លន់ ណុល ។

យោងតាមសម្តីរបស់ ណៃ វ៉ាឡង់តាំង បានឲ្យដឹងថា ផាម វ៉ាន់ដុង បានធានាចំពោះអ្នកម្នាង ម៉ូនិក ដែលជាព្រះមហេសីសម្តេច សីហនុ ថា កងទ័ពវៀតណាមខាងជើងអាចជួយសម្តេច សីហនុ កាន់អំណាចឡើងវិញក្នុងរយៈពេល២៤ម៉ោង ។ សម្តេច សីហនុ ផ្ទាល់ព្រះអង្គ បានរំឭកនាពេលក្រោយមកថា ផាម វ៉ាន់ដុង ស្នើចង់ជួបព្រះអង្គនៅទីក្រុងប៉េកាំង ។ នៅពេលជួបពិភាក្សាគ្នានៅព្រឹកថ្ងៃទី២២ ខែមីនា សម្តេច សីហនុ អះអាងថា សម្តេច បានកំណត់លក្ខខណ្ឌសហប្រតិបត្តិការ

ក្នុងនោះមានជំនួយចិនចំពោះក្រុមតស៊ូខ្មែរ មហាសន្និបាតប្រជាជននៅជ្រោយឥណ្ឌូចិន និងការហ៊ឹកហ៊ឺនយោធានៅក្នុងប្រទេសវៀតណាម ។ ជាការច្បាស់ណាស់ថា សម្តេច សីហនុ មិនប្រាថ្នាចង់ពឹងផ្អែកតែទៅលើជំនួយរបស់ក្រុងហាណូយទេ ។

នៅថ្ងៃរសៀលនោះដែរ ជូ អេនឡាយ បានជួបជាមួយ ផាម វ៉ាន់ដុង ដើម្បីស្តាប់របាយការណ៍របស់ ផាម វ៉ាន់ដុង ទាក់ទងនឹងការចរចាជាមួយសម្តេច សីហនុ ។ នៅល្ងាចថ្ងៃដដែលនោះ ជូ អេនឡាយ បានរៀបចំការពិភាក្សាគ្នាជាមួយសម្តេច សីហនុ ដោយបញ្ជាក់សាជាថ្មីនូវការគាំទ្ររបស់ចិនចំពោះចលនាតស៊ូរបស់ព្រះអង្គ ។ ជាការសង្កេតទៅលើសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ ដែលទ្រង់រៀបចំសម្រាប់ថ្ងៃបន្ទាប់ នាយករដ្ឋមន្ត្រីចិនបានកត់សម្គាល់ថា សេចក្តីថ្លែងការណ៍នេះនឹងទាក់ទាញចិត្តប្រជាជនកម្ពុជាមិនតិចទេ ។

ដោយដឹងថាសម្តេច សីហនុ ខ្វះខាតកម្លាំងទ័ពដើម្បីប្រយុទ្ធនឹងសហរដ្ឋអាមេរិក មន្ត្រីចិនបានពុះពារអស់ពីលទ្ធភាពដែលខ្លួនមាន ក្នុងការបញ្ចុះបញ្ចូលឲ្យខ្មែរក្រហមធ្វើសហប្រតិបត្តិការជាមួយព្រះអង្គ ។ នៅពេលដែលសម្តេច សីហនុ ត្រូវបានផ្តួលរំលំ ប៉ុល ពត កំពុងតែធ្វើទស្សនកិច្ចជាសម្ងាត់នៅប្រទេសចិន ។ ថ្នាក់ដឹកនាំចិនបានជួបប្រជុំជាមួយ ប៉ុល ពត ជាច្រើនលើក ដោយជំរុញឲ្យ ប៉ុល ពត ទុកកំហឹងនឹងសម្តេច សីហនុ មួយឡែកសិន ហើយបែរមកបង្កើតរណសិរ្សរួបរួមជាតិជាមួយព្រះអង្គ ដើម្បីរួមគ្នាវាយខ្ទាំងទាំងអស់គ្នា គឺសហរដ្ឋអាមេរិកនេះឯង ។ ប៉ុល ពត ក៏យល់ព្រមសហការជាមួយសម្តេច សីហនុ ។

នៅថ្ងៃទី២៣ ខែមីនា សម្តេចចេញសេចក្តីប្រកាសលើកដំបូងនូវ«សារជូនជនរួមជាតិ» ដោយអំពាវនាវឲ្យកូនចៅរបស់ព្រះអង្គលើកអាវុធឡើងប្រឆាំងនឹងរបប លន់ ណុល ហើយជំរុញឲ្យប្រជាជនកម្ពុជាឈប់ស្តាប់បញ្ជារដ្ឋាភិបាលក្រុងភ្នំពេញ ។ សម្តេច សីហនុ បានស្នើបង្កើតរដ្ឋាភិបាលរួបរួមជាតិមួយ កងទ័ពរំដោះជាតិមួយ និងរណសិរ្សរួបរួមជាតិកម្ពុជាដែលនឹងគ្រប់គ្រងប្រទេសកម្ពុជាដោយយោងទៅតាមគោលការណ៍«យុត្តិធម៌សង្គម ភាពស្មើគ្នា និង ភាតរភាព» ។ សេចក្តីសម្រេចចិត្តរបស់សម្តេច សីហនុ បានភ្ជាប់សម្ព័ន្ធភាពជាមួយខ្មែរក្រហមដែលកេងយកប្រយោជន៍ពីការអំពាវនាវនិងប្រជាប្រិយភាពរបស់ព្រះអង្គចំពោះប្រជាកសិករ ដើម្បីបម្រើឲ្យផលប្រយោជន៍របស់ខ្លួន ។ មូលដ្ឋានគ្រឹះដើម្បីសម្រេចបានជ័យជម្នះ ត្រូវបានរៀបចំរួចជាស្រេច ។

ភាពផ្ទុយគ្នារវាងប្រតិកម្មរបស់ក្រុងហាណូយនិងប៉េកាំងទៅនឹងសភាពការណ៍កម្ពុជានៅក្រោយពេលការដួលរលំរបស់សម្តេច សីហនុ កំពុងតែលាតត្រដាងឲ្យឃើញច្បាស់ ។ នៅរវាងថ្ងៃទី ២៥ -២៧ ខែមីនា ក្រុងហាណូយបានចេញសេចក្តីប្រកាសជាផ្លូវការគាំទ្រសម្តេច សីហនុ និងបានដកអ្នកការទូតរបស់ខ្លួនចេញពីទីក្រុងភ្នំពេញ ។ នៅក្នុងខណៈដែលគ្រាន់តែផ្សព្វផ្សាយសេចក្តីប្រកាសរបស់សម្តេច សីហនុ ជាសាធារណៈ ប្រព័ន្ធឃោសនាចិនក៏ដូចជាមន្ត្រីចិននៅទីក្រុងប៉េកាំង ទប់មិនបញ្ចេញយោបល់ទៅលើបញ្ហាកម្ពុជាទេ ។ ឯកអគ្គរដ្ឋទូតចិន កាង ម៉ៅចាវ នៅតែស្នាក់នៅទីក្រុងភ្នំពេញនៅឡើយ ក្រោយពេលតំណាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនិងរណសិរ្សរំដោះជាតិបានចាកចេញអស់ទៅហើយនោះ ។ ចិនមិនបានចេញមុខចោទប្រកាន់ក្រុងវ៉ាស៊ីនតោនថាជាអ្នករៀបចំផែនការផ្តួលរំលំសម្តេច សីហនុ ឲ្យបានខ្លាំងក្លាដូចសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនិងប៉ាថេតឡាវឡើយ ។ លុះដល់ថ្ងៃទី៥ ខែមេសា ទើប ជូ អេនឡាយ និយាយជាចំហប្រឆាំងនឹងសហរដ្ឋអាមេរិកថាបានរៀបចំផែនការទម្លាក់សម្តេច សីហនុ ។

នៅអំឡុងខែមេសា ឯកអគ្គរដ្ឋទូត កាង ម៉ៅចាវ បានជម្រាបទៅ លន់ ណុល ថា ប្រសិនបើ លន់ ណុល អនុញ្ញាតឲ្យមានការដឹកជញ្ជូនអាវុធយុទ្ធភ័ណ្ឌកាត់តាមទឹកដីកម្ពុជា រក្សាទុកទីជម្រកសម្រាប់កងទ័ពកុម្មុយនិស្តវៀតណាម និងជួយពួកគេនៅក្នុងសង្គ្រាមចិត្តសាស្ត្រនោះ ចិននឹងទទួលស្គាល់រដ្ឋាភិបាលរបស់ លន់ ណុល ។ លន់ ណុល បានបដិសេធសំណើរបស់ក្រុងប៉េកាំង ។ នៅថ្ងៃទី៥ ខែឧសភា រដ្ឋាភិបាលចិនក៏សម្រេចចិត្តកាត់ផ្តាច់ទំនាក់ទំនងជាមួយរបប លន់ ណុល ហើយដកអ្នកការទូតទាំងអស់របស់ខ្លួនពីភ្នំពេញ ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រុងប៉េកាំងក្នុងការស្តារឡើងវិញនូវស្ថានការណ៍ស្រុកទេស

កម្ពុជា ទោះជាក្រោមការដឹកនាំរបស់សម្តេច សីហនុ ឬអ្នកណាផ្សេងនោះ គឺត្រូវបរាជ័យ ។

ថ្នាក់ដឹកនាំចិនគួរតែដឹងថា ព្រឹត្តិការណ៍នៅប្រទេសកម្ពុជាទាក់ទងជាមួយនឹងសង្គ្រាមថ្មីៗដែលចេះតែមានកម្រិតខ្លាំងឡើងនៅប្រទេសឡាវ ។ ដោយចាប់ផ្តើមនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧០ កម្លាំងចម្រុះរបស់កងទ័ពប្រជាជនវៀតណាមនិងប៉ាថេតឡាវ បានបើកការវាយបណ្តេញកងទ័ពរដ្ឋាភិបាលចេញពីវាលទំនាប ចារ ។ កម្លាំងទ័ពជំនួយវៀតណាមខាងជើងចំនួន ១៣ ០០០នាក់ត្រូវបានដាក់ពង្រាយជាជំនួយបន្ថែមលើកងទ័ពដែលមានស្រាប់ចំនួន៤០ ០០០នាក់ ហើយកងទ័ពទាំងនេះកំពុងតែគំរាមកំហែងទីបញ្ជាការដ្ឋាន វ៉ាងប៉ាវ នៅ ឡុងឈីង ។ តាមសំណើរបស់នាយករដ្ឋមន្ត្រី សុវណ្ណា ភូម៉ា យន្តហោះអាមេរិកទម្លាក់គ្រាប់បែក បេ-៥១ របស់អាមេរិកបានវាយប្រហារទៅលើភាគខាងជើងប្រទេសឡាវជាលើកដំបូងដែលធ្វើឲ្យកម្លាំងកុម្មុយនិស្តមិនអាចទៅមុខបាន ។ ទោះបីជាប្រព័ន្ធឃោសនារបស់ចិនប្រកាសជាផ្លូវការមិនគាំទ្រដល់ទង្វើរបស់អាមេរិកក៏ដោយ ប៉ុន្តែថ្នាក់ដឹកនាំក្រុងប៉េកាំងត្រូវតែទទួលការរំខានចិត្តដោយសារការផ្តួចផ្តើមគំនិតថ្មីសម្រាប់សាកល្បង មើលជាលើកដំបូងរបស់វៀតណាមខាងជើងនៅក្នុងប្រទេសឡាវដែលមិនត្រឹមតែគំរាមកំហែងថានឹងពង្រីកសង្គ្រាម ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីពង្រីកឥទ្ធិពលរបស់ក្រុងមូស្គូ រួមដោយពឹងផ្អែកខាងអាវុធយុទ្ធភ័ណ្ឌរបស់សូវៀតជាមួយឥទ្ធិពលរបស់ក្រុងហាណូយទៀតផង ។ ដោយប្រកាន់យកនូវទស្សនវិស័យថាអាមេរិកនឹងដកថយពីវៀតណាមនោះ អ្នកគាត់តែងនយោបាយរបស់ចិនកំពុងតែគិតដល់ការកាន់កាប់របស់វៀតណាមដោយមានសម្ព័ន្ធភាពជាមួយសហភាពសូវៀតនៅពេលក្រោយសង្គ្រាមនៅលើជ្រោយឥណ្ឌូចិន ។

ក្នុងគោលបំណងប្រកួតប្រជែងជាមួយសហភាពសូវៀត និងវៀតណាមខាងជើងដើម្បីទទួលបានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា ក្រុងប៉េកាំងបានប្រកាន់យកនូវទ្រឹស្តីមុខពីរនៅអំឡុងពេលប៉ុន្មានសប្តាហ៍ក្រោយពីមានរដ្ឋប្រហារភ្លាម ។ ទីមួយគឺគាំទ្រសម្តេច សីហនុ ទីពីររិះរកលទ្ធភាពធ្វើប្រតិបត្តិការជាមួយរបប លន់ ណុល ។ ក្រុងប៉េកាំងព្យាយាមរក្សាជម្រើសរបស់ខ្លួនជាចំហ ហើយរិះរកមធ្យោបាយធ្វើឲ្យសម្តេច សីហនុ និងក្រុងមូស្គូមានទំនាស់នឹងគ្នា ។ នៅពេលសម្តេច សីហនុ ជួបពិភាក្សាជាមួយ ជូ អេន ឡាយ នៅថ្ងៃទី២៨ ខែមីនា ជាពេលដែលព្រះអង្គសម្តែងនូវការព្រួយបារម្ភថា សហភាពសូវៀតមានការប្រយ័ត្នប្រយែងក្នុងការប្រព្រឹត្តិមកលើព្រះអង្គ ហើយថាប្រទេសសង្គមនិយមផ្សេងៗទៀតនៅអឺរ៉ុបកំពុងតែដើរតាមគំរូរបស់សូវៀតនោះ នាយករដ្ឋមន្ត្រីចិនមិនបានឲ្យខកឱកាសក្នុងការបន្ទុចកិត្តិយសរបស់វិមានក្រឹមឡាំងឡើយ ។ ជូ អេន ឡាយ អះអាងថា រុស្ស៊ីតែងតែបានធ្វើដូច្នេះ «គេមិនត្រឹមតែប្រព្រឹត្តដូច្នេះមកលើកម្ពុជាទេ តែថែមទាំងប្រព្រឹត្តមកលើសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមស្រដៀងគ្នានេះដែរ» ។ នៅពេលដែលរដ្ឋនៅជ្រោយឥណ្ឌូចិនចេញសេចក្តីថ្លែងការណ៍ក្រោយមក ជូ អេន ឡាយ បន្តទៀតថា សហភាពសូវៀត«នឹងត្រូវអាម៉ាស់មុខ» ។

ក្រុងមូស្គូដែលត្រូវជំរុញពីក្រោយដោយការប្រជែងជាមួយក្រុងប៉េកាំង មិនធ្លាប់មានឆន្ទៈចង់កាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយរបប លន់ ណុល ទេ ។ ដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួននៅកម្ពុជា សហភាពសូវៀតបានផ្តល់ជាយោបល់នៅថ្ងៃទី១៧ ខែមេសា ឲ្យរៀបចំសន្និសីទមួយទៀតនៅក្រុងហ្សឺណែវ ប៉ុន្តែកិច្ចប្រជុំកំពូលនៃបណ្តាប្រជាជាតិនៅជ្រោយឥណ្ឌូចិនដែលរាប់រងដោយប្រទេសចិននៅចុងខែមេសា បានរារាំងជំហររបស់សូវៀត ។ ក្រុងប៉េកាំងបានប្រកាសជាផ្លូវការ មិនយល់ព្រមចំពោះសំណើរបស់សូវៀតនៅថ្ងៃកិច្ចប្រជុំកំពូលចាប់ផ្តើម ។

កិច្ចប្រជុំកំពូលបានរៀបចំធ្វើឡើងនៅ កុងហ៊ឺរ ជាកន្លែងកម្សាន្តនិទាឃរដូវស្ថិតនៅទីក្រុង ក្វាងចូវ នៅថ្ងៃទី២៤-២៥ ខែមេសា ។ មានព្រះវត្តមាននិងវត្តមាននាឱកាសនោះ មាន សម្តេច សីហនុ, សុផានុវង្ស នៃប្រទេសឡាវ, ផាម វ៉ាន់ដុង នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និង ង្វៀន ហ៊ូថូ នៃរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង ។ (ក្នុងនាមជាទូតបណ្តោះអាសន្នរបស់រណសិរ្សរំដោះជាតិ រដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នត្រូវបានបង្កើតឡើង

ដោយក្រុងហាណូយនៅខែមិថុនា ឆ្នាំ១៩៦៩ ក្នុងគោលបំណងបង្ហាញជូនជម្រើសជាផ្លូវការសម្រាប់របប ង្វៀន វ៉ាន់ ធីវ)។ នៅឯកិច្ចប្រជុំនោះ ប្រតិភូនានាបានបង្កើតឡើងនូវជម្លោះ។ នៅរសៀលថ្ងៃទី២៤ ខែមេសា ជូ អេន ឡាយ បានជិះយន្តហោះទៅក្រុងក្វាងចូវ ដើម្បីធ្វើឲ្យកិច្ចប្រជុំឆ្ពោះទៅមុខ ព្រមទាំងរៀបចំជាលម្អិតឲ្យមានសេចក្តីថ្លែងការណ៍រួមមួយ។

នៅថ្ងៃទី២៥ ខែមេសា កិច្ចប្រជុំកំពូលបានបញ្ចប់ទៅដោយមានការប្រកាសសេចក្តីថ្លែងការណ៍រួមដែលអំពាវនាវដល់ប្រជាជាតិនៅជ្រោយឥណ្ឌូចិន ចូលរួមចលនាតស៊ូរួមគ្នាប្រឆាំងនឹងសហរដ្ឋអាមេរិកនិងបរិវារ។ ចិនបានសន្យាឧបត្ថម្ភ “សមរភូមិក្រោយ” និង “ការគាំទ្រក្រោយខ្នង” សម្រាប់ចលនាតស៊ូប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក។ សម្តេច សីហនុ ក៏បានចេញសេចក្តីប្រកាសមួយ ដោយថ្កោលទោសសហរដ្ឋអាមេរិក និងសន្យាផ្តល់ឲ្យក្រុងហាណូយនិងរណសិរ្សរំដោះជាតិនូវការអនុញ្ញាតជាផ្លូវការឲ្យប្រើប្រាស់ទឹកដីកម្ពុជា។

ជូ អេន ឡាយ បានរៀបចំពិធីជប់លៀងមួយជាកិត្តិយសដល់គណៈប្រតិភូឥណ្ឌូចិនៗ ដោយអំណរសាទរចំពោះគណៈប្រតិភូដែលបានសម្រេចជោគជ័យនៅកិច្ចប្រជុំនោះ នាយករដ្ឋមន្ត្រីចិនបានប្រកាសអំពីការដាក់ឲ្យប្រើប្រាស់ប្រកបដោយជោគជ័យនូវផ្កាយរណបដំបូងរបស់ចិននៅថ្ងៃមុនៗ។ ជាការច្បាស់ណាស់ ជូ អេន ឡាយ ចង់ទាក់ទាញអារម្មណ៍អ្នកស្តាប់ឲ្យផ្តោតទៅលើសមិទ្ធផលចុងក្រោយរបស់ចិន។ តាមរយៈការផ្តល់ជម្រកដល់សម្តេច សីហនុ និងរ៉ាប់រងនូវកិច្ចប្រជុំកំពូលនេះ ក្រុងប៉េកាំងបានលួចការបង្ហាញជូនជាលក្ខណៈការទូតពីសហភាពសូវៀត។ ឥទ្ធិពលរបស់ចិននៅជ្រោយឥណ្ឌូចិនត្រូវបានបញ្ជាក់ឲ្យឃើញសាជាថ្មីនៅពេលនោះតែម្តង។

ការសម្រេចចិត្តរបស់ និចសុន ក្នុងការចូលមកលុកលុយប្រទេសកម្ពុជានៅដើមខែឧសភា បណ្តាលឲ្យមានប្រតិកម្មយ៉ាងខ្លាំងពីប្រទេសចិន។ នៅថ្ងៃទី១១ ខែឧសភា ម៉ៅ បានជួបប្រជុំជាមួយ ឡេ យន់ នៅទីក្រុងប៉េកាំង។ តាមសម្តីរបស់ លីហ្វួយសៀង ដែលជាអ្នកធ្វើកំណត់ហេតុនៅក្នុងកិច្ចសន្ទនារវាង ម៉ៅ សេទុង និង ឡេ យន់ ប្រធានបក្សកុម្មុយនិស្តចិននិយាយថា ទំនោរដ៏សំខាន់របស់ពិភពលោកគឺបដិវត្ត ហើយនិយាយថា ប្រទេសតូចៗទាំងនោះមិនគួរខ្លាចរអែងចក្រពត្តិអាមេរិកទេ។ នៅថ្ងៃទី១៨ ខែឧសភា រដ្ឋាភិបាលចិនបានប្រកាសលុបចោលការចរចានៅទីក្រុងវ៉ាសូវីដែលគ្រោងនឹងរៀបចំឡើងពីរថ្ងៃក្រោយ។ ថ្លែងទៅកាន់មហាជននៅទីលានធានអានម៉េននៅថ្ងៃទី ២០ ខែឧសភា ម៉ៅ សេទុង បានប្រកាសជាឱឡារិកសម្តែងនូវការគាំទ្រសម្តេច សីហនុ និងប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក។ គួរកត់សម្គាល់ថា សេចក្តីថ្លែងការណ៍របស់ ម៉ៅ



សេទុង ទោះជាស្តាប់ទៅគួរឲ្យចូលត្រចៀកក៏ពិតមែន ប៉ុន្តែខ្វះនូវធាតុពិតជាក់ស្តែង ។ សេចក្តីថ្លែងការណ៍នេះមិនបានបង្ហាញឲ្យបានច្បាស់លាស់អំពីការតស៊ូនៅលើជ្រោយឥណ្ឌូចិនឡើយ ។ វាគឺជាការឃោសនាដែលរៀបចំឡើងដើម្បីគោលបំណងបីយ៉ាង ។



គោលបំណងទីមួយគឺដើម្បីរំឭកដល់ប្រទេសគតិយ លោកថា ចិននៅតែរក្សាជាមិត្តដដែល ។ គោលបំណងទីពីរដើម្បីធ្វើឲ្យរុស្ស៊ីអាម៉ាស់មុខ ដោយលើកឡើងថា មានប្រទេសជិតម្ភៃបានទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដឹកនាំដោយសម្តេច សីហនុ ដែលសហភាពសូវៀតមិនទាន់បានទទួលស្គាល់ ។ គោលបំណងទីបីគឺដើម្បីផ្ញើសារទៅ និចសុន ថា ការផ្សារភ្ជាប់ទំនាក់ទំនងជាសុខដុមឡើងវិញរវាងចិននិងសហរដ្ឋអាមេរិកត្រូវតែផ្អែកលើការកាត់បន្ថយការចូលដៃចូលជើងរបស់អាមេរិកនៅលើជ្រោយឥណ្ឌូចិន ។

នៅពេលដែល ម៉ៅ សេទុង ថ្លែងសុន្ទរកថា ឆៃ ឆេងវិន អនុប្រធានគណៈប្រតិភូចិនសម្រាប់ការចរចាចិន-សូវៀត និង វ៉ាស៊ីលី គូសណេតសូវ ប្រធានគណៈប្រតិភូសូវៀតសម្រាប់ការចរចាចិន-សូវៀត ក៏ស្ថិតក្នុងជិហរសើរីដែរ ។ ឆៃ និយាយកំប្លែងយ៉ាងមុតជាក់អ្នកការទូតសូវៀតថា «លោកតែងតែនិយាយអំពីសកម្មភាពរួម ។ លោកមិនគិតថា សហភាពសូវៀតធ្វើមិនបានដល់កម្រិតទេឬ ក្នុងការគាំទ្រសម្តេច សីហនុ?» ។ ឆៃ និយាយយោងដល់សំណើរបស់សូវៀតកាលពីមុន ដែលចង់ចូលរួមសកម្មភាពគាំទ្រដល់វៀតណាមខាងជើង ។ ជាការច្បាស់ណាស់ ឆៃ មានអារម្មណ៍ថា ចិនពិតជាធ្វើបានល្អជាងសូវៀតខាងផ្នែកការទូតស្តីអំពីបញ្ហាកម្ពុជា ។

វិបត្តិនៅកម្ពុជាបង្ហាញទាំងគ្រោះថ្នាក់និងឱកាសដល់ក្រុងប៉េកាំង ។ ម្យ៉ាងគឺការលុកលុយរបស់អាមេរិកលើទឹកដីកម្ពុជាហាក់ដូចជាប្រាប់ទៅថ្នាក់ដឹកនាំចិននូវការប្រែក្រឡាប់នៃលទ្ធិរបស់និចសុន ។ នៅគ្រាដំបូងក្នុងជម្លោះវៀតណាម ក្រុងវ៉ាស៊ីនតោនបានប្រើកងទ័ពថ្មើរជើងនៅវៀតណាមខាងត្បូង ។ ដំណើរស្មាក់ស្មើរចង់សម្របខ្លួនទៅតាមទំនោរចិនផង អាមេរិកផង បានបញ្ចប់ទាំងកំបុតកំបុយក្រោយពីការលុកលុយ ។ ម្យ៉ាងវិញទៀតតាមរយៈការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលនៃបណ្តាប្រជាជាតិនៅជ្រោយឥណ្ឌូចិន និងតាមរយៈការសម្របសម្រួលដល់ការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក្រុងប៉េកាំងកាន់តែមានឥទ្ធិពលមកលើជ្រោយឥណ្ឌូចិន ។

ថ្នាក់ដឹកនាំចិនចាត់ទុកសម្តេច សីហនុ ជាឧបករណ៍ដ៏សំខាន់សម្រាប់បង្កើតឥទ្ធិពលរបស់ចិននៅកម្ពុជា ។ ថ្នាក់ដឹកនាំចិនបានប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីរៀបចំទទួលសម្តេច សីហនុ ដែលគង់ប្រថាប់នៅប្រទេសចិន និងសម្របសម្រួលដល់ការធ្វើដំណើររបស់ព្រះអង្គទៅបរទេសទៀត ។ ថ្នាក់ដឹកនាំចិនចង់រក្សានិង

ជំរុញឲ្យសម្តេច សីហនុ នៅតែជាថ្នាក់ដឹកនាំស្របច្បាប់របស់កម្ពុជា ។ ក្រោយពីមានរដ្ឋប្រហារនៅកម្ពុជា ក្រសួងការបរទេសចិនបានបង្កើតនូវការិយាល័យមួយដែលទទួលបន្ទុកកិច្ចការកម្ពុជាដើម្បីសម្របសម្រួលព្រះរាជសកម្មភាពរបស់ សម្តេច សីហនុ នៅប្រទេសចិន ។ ក្រោយពីការយាងវិលត្រឡប់របស់ព្រះអង្គមកកាន់ក្រុងប៉េកាំងនៅខែឧសភា ឆ្នាំ១៩៧០ កាង ម៉ៅចាវ បានក្លាយជានាយកការិយាល័យនេះដែលមានបុគ្គលិកបម្រើការប្រហែល១២នាក់ ។ រដ្ឋាភិបាលចិន បានថ្វាយសម្តេច សីហនុ នូវអតីតស្ថានទូតបារាំង ឲ្យធ្វើជាព្រះរាជដំណាក់ និងរៀបចំអាងហែលទឹកមួយសម្រាប់ព្រះអង្គ ។ តុរបស់ព្រះអង្គគឺជាតុដ៏ប្រណិតបំផុតនៅក្នុងទីក្រុង ដែលមានចម្លាក់រូបផ្ទៃស្គួបីរនិងសត្វហ្គីនៀហ្វូលដែលថ្វាយដោយ គីម អ៊ីលស៊ុង នៃកូរ៉េខាងជើង ។

នៅចន្លោះខែឧសភាដល់ខែកក្កដា ឆ្នាំ១៩៧០ សម្តេច សីហនុ បានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមខាងជើងនិងកូរ៉េខាងជើង ។ នៅឱកាសទាំងពីរនោះ ជូ អេន ឡាយ បានធ្វើដំណើរទៅព្រលានយន្តហោះក្រុងប៉េកាំងនិងទៅស្ថានីយ៍រថភ្លើង ដើម្បីជូនដំណើរនិងទទួលព្រះអង្គយាងត្រឡប់មកវិញ ។ នៅថ្ងៃទី៥ ខែកក្កដា ជូ អេន ឡាយ បានធ្វើជាម្ចាស់ផ្ទះរៀបចំពិធីជប់លៀងជាផ្លូវការមួយនៅឯវិមានប្រជាជន ដើម្បីអបអរដល់ការធ្វើដំណើរប្រកបដោយជោគជ័យរបស់សម្តេច សីហនុ ។ តំណាងមកពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រណសិរ្សរំដោះជាតិ ប៉ាថេតឡាវ និងកូរ៉េខាងជើង ក៏បានចូលរួមពិធីលាងសាយភោជន៍នេះដែរ ។ ជូ អេន ឡាយ ចង់បញ្ជាក់ច្បាស់អំពីសាមគ្គីភាពនៅក្នុងតំបន់នៅពីក្រោយសម្តេច សីហនុ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវកិត្យានុភាពរបស់ព្រះអង្គលើឆាកអន្តរជាតិ ។ ក្រៅពីដំណើរយាងទៅក្រៅប្រទេសរបស់ សម្តេច សីហនុ រដ្ឋាភិបាលចិនក៏បានរៀបចំដំណើរទេសចរណ៍ជាញឹកញាប់ ដើម្បីឲ្យព្រះអង្គយាងទតផ្នែកផ្សេងៗនៃទឹកដីចិន ។ ចិនបានប្រើប្រាស់ប្រព័ន្ធឃោសនាដើម្បីផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយថែមទៀតស្តីអំពីដំណើរយាងទតរបស់ព្រះអង្គ ដើម្បីបង្ហាញឲ្យឃើញថា សម្តេច សីហនុ តែងតែត្រូវបានទទួលការរាក់ទាក់យ៉ាងកក់ក្តៅក្នុងព្រះបរមនាមជាព្រះប្រមុខរដ្ឋ ។

នៅក្នុងពេលជួបជាមួយសម្តេច សីហនុ ថ្នាក់ដឹកនាំចិនមានបំណងចង់ឲ្យព្រះអង្គទទួលយកនូវគំនិតរបស់ខ្លួនទាក់ទងនឹងកិច្ចការអន្តរជាតិ ។ នៅក្នុងកិច្ចសន្ទនាមួយជាមួយសម្តេច សីហនុ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧០ ជូ អេន ឡាយ បានពន្យល់ទ្រឹស្តីរបស់ ម៉ៅ សេទុង អំពីតំបន់មជ្ឈមពីរ ។ យោងតាមគំនិតរបស់ ម៉ៅ សេទុង តំបន់មជ្ឈមពីរមាននៅរវាងប្រទេសមហាអំណាចពីរ ។ តំបន់ទីមួយរួមមានប្រទេសកំពុងអភិវឌ្ឍនៅទ្វីបអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន ចំណែកឯតំបន់ទីពីរគឺរដ្ឋនានាដែលមានការអភិវឌ្ឍន៍នៅទ្វីបអឺរ៉ុប ប្រទេសកាណាដា និងជប៉ុន ។ ម៉ៅ សេទុង ជឿថា ប្រទេសទាំងឡាយនៅក្នុងតំបន់ទាំងពីរនេះមានទំនាស់ជាមួយសហរដ្ឋអាមេរិកនិងសហភាពសូវៀត ហើយអ្នកដែលប្រឆាំងនឹងអនុត្តរភាពរបស់មហាអំណាច គួរតែរួបរួមគ្នាជាមួយប្រទេសទាំងនេះដើម្បីបង្កើតជារណសិរ្សរួបរួមអន្តរជាតិមួយ ។ មិនប្រាកដថា សម្តេច សីហនុ បានយល់ស្របចំពោះទ្រឹស្តីរបស់ ម៉ៅ សេទុង ឬយ៉ាងណានោះទេ ។ ប៉ុន្តែអ្វីដែលច្បាស់គឺ សម្តេចងឿងឆ្ងល់និងមិនរីករាយព្រះទ័យចំពោះការផ្លាស់ប្តូរនយោបាយរបស់ចិនចំពោះសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៧១-១៩៧២ ។

នៅខែកក្កដា ឆ្នាំ១៩៧១ ឃីសស៊ីងជឺរ បានធ្វើដំណើរស្ងាត់ៗទៅទីក្រុងប៉េកាំង ដើម្បីរៀបចំសម្រាប់ដំណើរអញ្ជើញមករបស់លោកប្រធានាធិបតី និចសុន ។ ឃីសស៊ីងជឺរ បានពិភាក្សាយ៉ាងយូរជាមួយ ជូ អេន ឡាយ អំពីបញ្ហាអន្តរជាតិជាច្រើន ។ នាយករដ្ឋមន្ត្រីចិនបានបន្ទោសអាមេរិកាំងដែលបានពង្រីកសង្គ្រាមវៀតណាមនៅកម្ពុជានិងឡាវ ។ ឃីសស៊ីងជឺរ បានធានាចំពោះ ជូ អេន ឡាយ ថា សហរដ្ឋអាមេរិក “មិនបានចាត់ចែងបង្កបង្កើត ឬជំរុញឲ្យមាន” រដ្ឋប្រហារទម្លាក់សម្តេច សីហនុ ទេ ។ ឃីសស៊ីងជឺរ ពន្យល់ថា សហរដ្ឋអាមេរិកកំពុងតែចរចាជាមួយវៀតណាមខាងជើង នៅពេលសម្តេច សីហនុ ត្រូវបានផ្តួលរំលំ ហើយរដ្ឋប្រហារនេះ “បានបំផ្លាញការចរចាដែលយើងកំពុងតែធ្វើ ហើយដែលយើងចង់បានជោគជ័យ” ។ នៅពេលដែល ជូ អេន ឡាយ សួរថា តើបារាំងជាអ្នកនៅពីក្រោយរដ្ឋប្រហារនោះ ឃីស៊ីងជឺរ បានឆ្លើយតបទៅវិញថា “អាចយល់

បានថាអ្នកណានៅពីក្រោយខ្នង ប៉ុន្តែមិនមែនយើងជាអ្នកធ្វើទេ» ។

នៅអំឡុងពេលកិច្ចប្រជុំជាប្រវត្តិសាស្ត្រជាមួយ និចសុន នៅក្រុងប៉េកាំងនៅខែកុម្ភៈ ឆ្នាំ១៩៧២ ជូ អេន ឡាយ បានកោតសរសើរចំពោះសម្តេច សីហនុ។ ជូ អេន ឡាយ បានជម្រាបប្រធានាធិបតីអាមេរិកថា ទោះបីជាសម្តេច សីហនុ ជាអ្នកកាន់ព្រះពុទ្ធសាសនា មិនមែនជាជនកុម្មុយនិស្តក៏ដោយចុះ ប៉ុន្តែចិនគោរពព្រះអង្គ។ ជូ អេន ឡាយ អះអាងថា សម្តេច សីហនុ ខុសពី លន់ ណុល សិរិមតៈ និង សឺង ង៉ុកថាញ់ ។ ចិនគាំទ្រសម្តេច សីហនុ ពីព្រោះព្រះអង្គជាជនស្នេហាជាតិ ។ ជូ អេន ឡាយ បានជម្រាប និចសុន ថា រដ្ឋាភិបាលរបស់លោកបានអនុញ្ញាតឲ្យសម្តេច សីហនុ ចុះផ្សាយសារជូនជនរួមជាតិរបស់ព្រះអង្គនៅលើទំព័រកាសែត «ប្រជាជនចិន» ។

ប៉ុន្តែសម្តេច សីហនុ មិនអាចយល់ថាហេតុអ្វីបានជាក្រុងប៉េកាំងសម្រេចអញ្ជើញប្រធានាធិបតី និចសុន មកបំពេញទស្សនកិច្ចនៅប្រទេសចិន នៅពេលដែលកងទ័ពអាមេរិកនៅតែឈរជើងប្រចាំការនៅតៃវ៉ាន់ឡើយ ។ ដោយមានព្រះទ័យមិនចង់ស្នាក់នៅទីក្រុងជាមួយ និចសុន សម្តេច សីហនុ ទ្រង់យាងចាកចេញពីក្រុងប៉េកាំងទៅកាន់ក្រុងហាណូយមុនការមកដល់របស់ប្រធានាធិបតីអាមេរិក គឺនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧២ រហូតដល់ និចសុន ចាកចេញពីប៉េកាំង ទើបព្រះអង្គយាងត្រឡប់មកវិញ ។

## ការផុសចេញសាមគ្គីភាពរវាងចិននិងខ្មែរក្រហម

ការប្រកួតប្រជែងគ្នារវាងក្រុងប៉េកាំងនិងក្រុងហាណូយនៅក្នុងប្រទេសកម្ពុជា បានស្តែងចេញឲ្យឃើញជាក់ច្បាស់នៅក្នុងចលនាតស៊ូ ។ ការកាត់ផ្តាច់ដោយលក្ខណៈភូមិសាស្ត្របានរារាំងមិនឲ្យចិនមានលទ្ធភាពធ្វើការជាមួយរណសិរ្សរួបរួមជាតិកម្ពុជាឡើយ ។ ជាលទ្ធផល ក្រុងប៉េកាំងបានផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទៅលើសម្តេច សីហនុ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាវិញ ។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសម្តេច សីហនុ ប្រទេសចិនសង្ឃឹមថា នឹងរក្សាបានអានុភាពមួយចំនួនទៅលើក្រុងហាណូយស្តីអំពីបញ្ហាកម្ពុជា ។ ក្រុងប៉េកាំងមិនបានបង្កើតទំនាក់ទំនងជាមួយចលនាតស៊ូឡើយ រហូតដល់ចុងឆ្នាំ១៩៧១ ពេលដែលអៀង សារី ធ្វើដំណើរទៅរដ្ឋធានីចិនក្នុងនាមជាអ្នកទាក់ទងពិសេស ។ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមពឹងផ្អែកទៅលើវត្តមានយោធារបស់ខ្លួននៅកម្ពុជា ដើម្បីរក្សាមិត្តភាពឲ្យកាន់តែជិតស្និទ្ធជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដោយសង្ឃឹមថាខ្មែរដែលត្រឡប់មកពីរៀនសូត្រនៅក្រុងហាណូយនឹងគ្រប់គ្រងលើចលនាតស៊ូមិនខាន ។ នៅចន្លោះឆ្នាំ១៩៧០-១៩៧២ កងទ័ពរបស់ហាណូយទទួលបន្ទុកធំបន្ទាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ព លន់ ណុល ។

ការព្រួយបារម្ភរបស់ចិនទៅលើទំនោររបស់ក្រុងហាណូយដើម្បីដឹងឥទ្ធិពលមកលើព្រឹត្តិការណ៍នានានៅកម្ពុជា បានឆ្លុះបញ្ចាំងឲ្យឃើញអំពីប្រតិកម្មរបស់ខ្លួនមកលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៧៣ ។ នៅក្នុងអំឡុងពេលចរចារវាងអាមេរិកនិងវៀតណាមខាងជើងនៅទីក្រុងប៉ារីស ភាគីទាំងពីរបានព្រមព្រៀងនឹងគ្នាថា ដំណោះស្រាយគួរតែរួមទាំងការរៀបចំបទឈប់បាញ់គ្នានៅកម្ពុជានិងឡាវ ។ ដោយមានភាពប្រាកដក្នុងចិត្តអំពីការលម្អៀងរបស់ក្រុងហាណូយទៅលើប៉ាថេតឡាវនោះ ឡេ ឌឹកថូ អ្នកចរចាវៀតណាមខាងជើង បានសន្យាថានឹងនាំមកនូវការឈប់បាញ់គ្នានៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ៣០ថ្ងៃក្រោយពីមានបទឈប់បាញ់គ្នានៅវៀតណាម ។ ចំពោះកម្ពុជាវិញ អ្នកការទូតហាណូយមិនសូវប្រាកដក្នុងចិត្តប៉ុន្មានទេ ដោយអះអាងថា វៀតណាមខាងជើងមានឥទ្ធិពលតិចតួចទៅលើខ្មែរក្រហម ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកនិងវៀតណាមខាងជើងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ ក្រុងប៉េកាំងបានដាក់ "ខ" បម្រុងមួយចំនួនទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ជាពិសេសទាក់ទងនឹងប្រព្រឹត្តកម្មរបស់ខ្លួនមកលើកម្ពុជានិងឡាវ ។ ថ្នាក់ដឹកនាំចិនបានទទូចថា នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសមានតែបញ្ហាវៀតណាមទេ ដែលគួរតែពិភាក្សា ចំណែកឯបញ្ហាកម្ពុជានិងឡាវមិនគួរបញ្ចូលឡើយ ។ ក៏ប៉ុន្តែថ្នាក់ដឹកនាំចិនខកចិត្តយ៉ាងខ្លាំងនៅពេលដែលចុងបញ្ចប់កិច្ចព្រមព្រៀងនេះមាននិយាយអំពីបញ្ហាកម្ពុជានិងឡាវដែរ ។ នៅក្នុងសុន្ទរកថាក្នុងស្រុកនៅខែមីនាឆ្នាំ១៩៧៣ ជូ អេន ឡាយ

និយាយថា ការនិយាយដល់បញ្ហាកម្ពុជានិងឡាវ នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស“មិនល្អទេ ពីព្រោះយើងមិនអាចដាក់បញ្ហាវៀតណាមទៅលើប្រទេសទាំងពីរនេះទេ” ។ ជាការច្បាស់ណាស់ ថ្នាក់ដឹកនាំចិនមិនចង់ឃើញក្រុងហាណូយដាក់កំហិតលក្ខខណ្ឌសន្តិភាពសម្រាប់ប្រទេសកម្ពុជានិងឡាវឡើយ ។

ឥទ្ធិពលរបស់ក្រុងហាណូយទៅលើប៉ាថេតឡាវ បានធ្វើឲ្យវៀតណាមមានលទ្ធភាពយ៉ាងលឿនក្នុងការផ្តល់នូវបទឈប់បាញ់ក្នុងប្រទេសឡាវដែលខ្លួនបានសន្យា ។ កិច្ចព្រមព្រៀងយុទ្ធសន្តិភាពឡាវត្រូវបានចុះហត្ថលេខា នៅក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៣ ។ ក៏ប៉ុន្តែ ខ្មែរក្រហមបានជំទាស់ទៅនឹងសំណើបទឈប់បាញ់ ។ ស្ថានការណ៍នៅប្រទេសកម្ពុជានៅតែមានការប្រែប្រួលនៅឡើយ ។ ថ្នាក់ដឹកនាំចិនឃ្លាំមើលការវិវត្តន៍នៅប្រទេសកម្ពុជាដោយអន្ទះសានិងថុញថប់ក្នុងចិត្ត ។ ការភ័យខ្លាចបំផុតរបស់ថ្នាក់ដឹកនាំចិនគឺថា សហភាពសូវៀតអាចទាញយកផលប្រយោជន៍ពីសភាពការណ៍មិនប្រាកដប្រជានៅកម្ពុជា ដើម្បីបង្កើតវត្តមានរបស់សូវៀតនៅកម្ពុជា ។ ថ្នាក់ដឹកនាំចិនចេះតែបន្តជំទាស់ លន់ ណុល និងគាំទ្រការរួបរួមគ្នា រវាងសម្តេច សីហនុ និងខ្មែរក្រហម ។ ទោះបីជាថ្នាក់ដឹកនាំចិននៅតែបន្តពឹងផ្អែកទៅលើ សម្តេច សីហនុ ថាជាឧបករណ៍សំខាន់សម្រាប់រក្សាឥទ្ធិពលរបស់ចិននៅកម្ពុជាក៏ដោយ ក៏ថ្នាក់ដឹកនាំចិន នៅតែមន្ទិលសង្ស័យចំពោះការទទួលខុសត្រូវរបស់សម្តេច សម្រាប់រយៈលេយូរអង្វែងដែរ ។

ការមានអារម្មណ៍មិនប្រាកដប្រជារបស់ថ្នាក់ដឹកនាំចិន និងការយល់ឃើញមកលើកម្ពុជា បានឆ្លុះបញ្ចាំងឲ្យឃើញច្បាស់នៅក្នុងកិច្ចប្រជុំនានារបស់ ដូ អេន ឡាយ ជាមួយ ឃីសស៊ីងជឺរ ដែលជាទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានាធិបតី និចសុន នៅក្រុងប៉េកាំងនាថ្ងៃទី១៦-១៨ ខែកុម្ភៈ ឆ្នាំ១៩៧៣ ។ នៅក្នុងកិច្ចពិភាក្សាគ្នានោះ ដូ អេន ឡាយ បានពាំនាំយកការភ័យខ្លាចរបស់ចិនអំពីការពង្រីកខ្លួនរបស់សូវៀតនៅលើជ្រោយឥណ្ឌូចិន ការមិនទុកចិត្តចំពោះ លន់ ណុល និងភាពមិនប្រាកដប្រជារបស់ចិនចំពោះទិសដៅខាងមុខរបស់សម្តេច សីហនុ។ ដូ អេនឡាយ បានបើកកិច្ចប្រជុំនៅថ្ងៃទី១៦ ខែកុម្ភៈ ដោយកត់សម្គាល់ទៅលើការវិលត្រឡប់របស់ឯកអគ្គរដ្ឋទូតសូវៀតទៅក្រុងភ្នំពេញវិញ ។ រួចហើយ ដូ អេន ឡាយ សួរទៅ ឃីសស៊ីងជឺរ ថា ហេតុអ្វីបានជាបដិសេធការចរចាជាមួយសម្តេច សីហនុ។ ឃីសស៊ីងជឺរ ឆ្លើយតបវិញថា សហរដ្ឋអាមេរិក មិនអាចចូលរួមចរចាដោយផ្ទាល់ជាមួយសម្តេច សីហនុ បានទេ ក្នុងខណៈដែលខ្លួនកំពុងទទួលស្គាល់រដ្ឋាភិបាល លន់ ណុល ។ ឃីសស៊ីងជឺរ ប្រាប់ទៅ ដូ អេន ឡាយ ថា លន់ ណុល “ពិតជាអន្ទះសាចង់បង្កើតទំនាក់ទំនងជាមួយលោក” ។ នាយករដ្ឋមន្ត្រីចិនឆ្លើយទៅវិញថា “យើងមិនចង់ធ្វើដូច្នោះជាមួយមនុស្សបែបនេះទេ ។ លោកក៏មិនគួរដោះស្រាយវែកញែកចំពោះមនុស្សដែលធ្វើសកម្មភាពវិទ្ធង្សនាប្រឆាំងនឹងសម្តេច សីហនុ ដែរ” ។ ដោយដឹងថាក្រុងប៉េកាំងនិងសម្តេច សីហនុ មិនអាចទទួលយក លន់ ណុល បាន ឃីសស៊ីងជឺរ ក៏បានស្នើឡើងនូវជម្រើសបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ននៅកម្ពុជាដែលមានមាសភាពមកពីក្រុមរបស់សម្តេច សីហនុ និងក្រុមរបស់ លន់ ណុល ។ ឃីសស៊ីងជឺរ បន្តទៀតថា សហរដ្ឋអាមេរិករៀបចំខ្លួនទទួលយកនូវរដ្ឋាភិបាលមួយដោយគ្មាន លន់ ណុល ប៉ុន្តែរដ្ឋាភិបាលនោះគួរតែរួមបញ្ចូលកងកម្លាំងរបស់ លន់ណុល ។ ដូ អេន ឡាយ អះអាងថា ទាំងសម្តេច សីហនុ ទាំងខ្មែរក្រហមសុទ្ធតែមិនអាចទទួលយកនូវការចរចាបែបនេះទេ ។

នៅក្នុងការពិភាក្សានាថ្ងៃទី១៧ ខែកុម្ភៈ ឃីសស៊ីងជឺរ ធានាចំពោះមុខ ដូ អេន ឡាយ ថា នៅពេលចិនបានពិគ្រោះជាមួយសម្តេច សីហនុ សហរដ្ឋអាមេរិកបានរៀបចំខ្លួនរួចជាស្រេច ដើម្បីពិភាក្សាជាមួយចិនទៅលើបញ្ហាថា “តើអ្នកណាអាចជាតួអង្គចរចាដែលអាចទទួលយកបានសម្រាប់ភាគីទាំងសងខាង និងគោលការណ៍អ្វីខ្លះដែលអាចទទួលបាននៅក្នុងរដ្ឋាភិបាលបណ្តោះអាសន្ន” ។ ចំណុចត្រង់នេះគឺចង់សំដៅស្វែងរកដំណោះស្រាយដែល“ស្របគ្នាជាមួយភាពថ្លៃថ្នូររបស់ភាគីទាំងអស់” ទាំងខាងក្រុម លន់ ណុល និងគូដិបក្ខ ។ ក្រោយមក ឃីសស៊ីងជឺរ បានសរសេរនៅក្នុងកំណត់ហេតុរបស់ខ្លួនថា ដូ អេន ឡាយ ចង់ទទួលយកនូវការស្នើបង្កើតរដ្ឋាភិបាលចម្រុះសម្រាប់ប្រជាជនកម្ពុជា ។

ដូ អេន ឡាយ ងាកមកនិយាយអំពីបញ្ហានយោបាយសូវៀតចំពោះអាស៊ី-អាគ្នេយ៍ នៅក្នុងកិច្ចប្រជុំនាថ្ងៃទី១៨ ខែកុម្ភៈ ។ ដូ អេន ឡាយ បានទាញអារម្មណ៍យកចិត្តទុកដាក់របស់ ឃីសស៊ីងជឺរ ទៅលើចេតនារបស់ក្រុងមូស្គូចំពោះកម្ពុជា "សហភាពសូវៀត...កំពុងតែប៉ុនប៉ងបង្កើតនូវខ្មែរក្រហមរបស់ខ្លួនផ្ទាល់ ប៉ុន្តែគេមិនអាចរកមនុស្សបានច្រើនទេ ។ ប៉ុន្តែរឿងនេះអាចកើតឡើងនៅពេលអនាគត ។ ដូច្នេះនៅថ្ងៃអនាគត ប្រសិនបើមានពត៌មានណាដែលលោកចង់ផ្តល់ឲ្យយើងទាក់ទងនឹងបញ្ហានេះ យើងក៏អាចផ្តល់ឲ្យលោកវិញដែរ" ។ តាមរយៈការសម្តែងចេញនូវការគាំទ្ររបស់ចិនចំពោះទិសដៅចុងក្រោយរបស់កម្ពុជា ចង់បានសន្តិភាព ឯករាជ្យភាព ឯកភាពជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី ដូ អេន ឡាយ និយាយថា "ឲ្យក្លាយទៅជាក្រហមឆ្អៅឥឡូវតែម្តងមិនអាចទៅរួចទេ ។ ប្រសិនបើប៉ុនប៉ងធ្វើដូច្នេះមែន លទ្ធផលគឺនាំឲ្យមានបញ្ហាកាន់តែខ្លាំង" ។ ចិនចង់បានអាស៊ី-អាគ្នេយ៍ដែលមានឯករាជ្យ ចៀសផុតពីការគ្របសង្កត់របស់សូវៀត ។ ដូ អេន ឡាយ បន្តទៀតថា "ប្រសិនបើយើងចង់ឃើញអាស៊ី-អាគ្នេយ៍មានការអភិវឌ្ឍន៍លូតលាស់ទៅមុខតាមមាគ៌ាសន្តិភាពនិងអព្យាក្រឹតភាព និងមិនដើរតាមប្រព័ន្ធសន្តិសុខសូវៀត-អាស៊ី ពេលនោះកម្ពុជានឹងជាប្រទេសគំរូមួយ" ។ ជាការច្បាស់ណាស់ថា ដូ អេន ឡាយ ភ័យខ្លាចក្រែងថា ប្រសិនបើកម្ពុជាចូលខាងកុម្មុយនិស្តនៅពេលនេះ ក្រុងហាណូយនឹងមានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា ហើយលទ្ធផលនឹងនាំដល់ការគ្របសង្កត់របស់សូវៀត ដោយសារថា ក្រុងហាណូយមានទំនាក់ទំនងមិត្តភាពយ៉ាងជិតស្និទ្ធជាមួយក្រុងមូស្គូ ។ ឃីស៊ីងជឺរ ក៏មានការព្រួយបារម្ភដូចជា ដូ អេន ឡាយ ដែរ អំពីមហិច្ឆតារបស់សូវៀតនៅកម្ពុជា ។ ឃីសស៊ីងជឺរ បានជម្រាបទៅនាយករដ្ឋមន្ត្រីចិនថា សហរដ្ឋអាមេរិករៀបចំខ្លួនក្នុងការផ្លាស់ប្តូរពត៌មានទាក់ទងនឹងសកម្មភាពរបស់សូវៀតនៅក្នុងតំបន់ ។

ក្រោយពីមានការផ្លាស់ប្តូរមតិយោបល់ជាមួយគ្នាស្តីអំពីការបង្ការការជ្រៀតជ្រែកចូលកិច្ចការរបស់កម្ពុជា កិច្ចសន្ទនាក៏ផ្តោតការយកចិត្តទុកដាក់ទៅលើការវាយតម្លៃសម្តេច សីហនុវិញម្តង ។ ដូ អេន ឡាយ និយាយថា "ទោះបីជាសម្តេច សីហនុ បានសរសេរកំណាព្យយ៉ាងល្អអំពីចិនដែលជាមាតុភូមិទីពីររបស់ព្រះអង្គក៏ដោយ ក៏យើងត្រូវតែរៀបចំសម្រាប់ថ្ងៃដែលសម្តេចនិយាយថា អាហ្នឹងគេមិនគិតទេ! តែទោះជាយ៉ាងណា កំណាព្យនេះសរសេរដោយព្រះអង្គទាំងអស់ ។ វាគ្មានអ្វីទាក់ទងដល់យើងទេ ។ ពិតណាស់ថា ឥឡូវនេះសម្តេចនិយាយថា ខ្ញុំគឺជាមិត្តភក្តិដ៏ល្អម្នាក់របស់ព្រះអង្គ...វាមិនមានបញ្ហាអ្វីទេ ។ នោះគ្រាន់តែជាទំនាក់ទំនងផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ សម្តេចនៅតែជាព្រះប្រមុខរដ្ឋកម្ពុជាដែលកាន់ព្រះពុទ្ធសាសនាដដែល" ។ ទោះបីជាចិនយល់ស្របចំពោះទិសដៅសន្តិភាព ឯកភាព និងឯករាជ្យភាពក៏ដោយ ក៏ ដូ អេន ឡាយ បានសន្និដ្ឋានថា "យើងនឹងនៅតែចាំមើលតើគោលដៅទាំងនេះត្រូវបានយល់ច្បាស់ដោយរបៀបណា" ។ ឃីសស៊ីងជឺរ និយាយថា សហរដ្ឋអាមេរិក"យល់ស្របទាំងស្រុងទៅនឹង"គោលដៅឯករាជ្យភាពរបស់កម្ពុជា ហើយថា "យើងមានការពិបាកដូចគ្នាក្នុងការសម្រេចថា តើត្រូវប្រើឥទ្ធិពលរបស់យើងតាមផ្លូវណា" ។ ជាការច្បាស់ណាស់ ឃីសស៊ីងជឺរ មានការខកចិត្តដូចជា ដូ អេន ឡាយ ដែរទៅលើភាពមិនអាចទស្សន៍ទាយបាននៃនយោបាយរបស់កម្ពុជា ។ អ្នកទាំងពីរមានអារម្មណ៍ថា ប្រទេសរបស់ដងខ្លួនមានអំណាចតិចតួចណាស់ក្នុងការកំណត់អំពីព្រឹត្តិការណ៍នៅប្រទេសកម្ពុជា ។

កិច្ចពិភាក្សារវាង ដូ អេន ឡាយ និង ឃីសស៊ីងជឺរ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ ។ អ្នកទាំងពីរសុទ្ធតែបានលើកឡើងទាំងចំណុចរួមគ្នានិងចំណុចខ្វែងគំនិតគ្នានៃនយោបាយចិននិងអាមេរិកទៅលើប្រទេសកម្ពុជា ។ ការគន់គូរខាងនយោបាយរបស់ក្រុងប៉េកាំងនិងវ៉ាស៊ីនតោនទាក់ទងនឹងបញ្ហាកម្ពុជា គឺមានលក្ខណៈស្របគ្នាច្បាស់ក្រឡែត ។ ភាគីទាំងពីរមានការព្រួយបារម្ភអំពីតួនាទីរបស់ក្រុងមូស្គូនៅក្នុងភូមិភាគអាស៊ី-អាគ្នេយ៍ ហើយភាគីទាំងពីរមានឆន្ទៈចង់ធ្វើសហប្រតិបត្តិការជាមួយគ្នាក្នុងគោលបំណងបញ្ឈប់រុស្ស៊ី ។ របាំងរួមគ្នារបស់ចិននិងអាមេរិកចំពោះសហភាពសូវៀតនៅលើទឹកដីឥណ្ឌូចិន កំពុងតែដំណើរការ ។

**ឈាំង ថៃ**

***(នៅមានត)***

# សុក្រឹតភាពគឺជាសត្រូវនៃយុត្តិធម៌៖

## ការឆ្លើយតបទៅនឹងការរិះគន់របស់អង្គការលើកលែងទោសអន្តរជាតិ នៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ នៅទីក្រុងភ្នំពេញ លោក ហែន កូរែល អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ និងឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ ប្រជាជនកម្ពុជា ១លាន៧សែននាក់ បានស្លាប់នៅក្រោមការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ។

ខ្មែរក្រហមត្រូវបានផ្តួលរំលំចេញពីអំណាចនៅឆ្នាំ១៩៧៩ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយពីនោះ សហរដ្ឋអាមេរិកនិងប្រទេសដទៃទៀតបានបោះឆ្នោតផ្តល់អាសនៈដល់ខ្មែរក្រហមឲ្យអង្គុយនៅអង្គការសហប្រជាជាតិ ហើយបានជំទាស់ទៅនឹងកិច្ចខិតខំប្រឹងប្រែងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ ចាប់តាំងពីឆ្នាំ១៩៨១ មក កម្មវិធីសិក្សាអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សាកលវិទ្យាល័យយែល និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមែប្រមូលភ័ស្តុតាងពីសាក្សីនានា ប្រមែប្រមូលឯកសាររាប់សែនសន្លឹកនិងធ្វើផែនទីរណ្តៅសាកសពរាប់ពាន់រណ្តៅ ។ នៅឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពកម្ពុជាត្រូវបានចុះហត្ថលេខា ហើយនៅឆ្នាំ១៩៩៤ ច្បាប់ស្តីអំពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលរ៉ាប់រងដោយសមាជិកព្រឹទ្ធសភា ឆាល រ៉ុប បានធ្វើឲ្យក្លាយទៅជានយោបាយរបស់អាមេរិកក្នុងការដាក់សម្ពាធឲ្យមានការបង្កើតតុលាការអន្តរជាតិសម្រាប់វិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ នៅឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គតុលាការបែបនេះ ។ ក្រុមអ្នកជំនាញការដែលតែងតាំងដោយអង្គការសហប្រជាជាតិបានមកធ្វើការសិក្សាវាយតម្លៃតាមផ្លូវច្បាប់ ហើយនៅឆ្នាំ១៩៩៩ អ្នកច្បាប់ទាំងនេះបានស្នើឲ្យមានការបង្កើតអង្គតុលាការមួយ ។

បន្ទាប់មកមានការចរចាជាច្រើនឆ្នាំ អង្គការសហប្រជាជាតិព្យាយាមចង់ឲ្យមានតុលាការដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិសុទ្ធសាធ ។ ចំណែកកម្ពុជាទទូចថា តុលាការនេះគួរតែមានជនជាតិខ្មែរភាគច្រើន ប្រព្រឹត្តទៅក្រោមច្បាប់កម្ពុជា ។ កិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើងនៅឆ្នាំ២០០១ ស្តីអំពីការបង្កើតឲ្យមានតុលាការចម្រុះដោយមានជនជាតិខ្មែរច្រើនជាង ប៉ុន្តែតម្រូវឲ្យមានការព្រមព្រៀងគ្នាមួយទៀតស្តីអំពីមតិភាគច្រើនលើសលប់សម្រាប់ចៅក្រមអន្តរជាតិនៅរាល់ពេលធ្វើការសម្រេចចិត្ត ។ ការគ្រប់គ្រងរដ្ឋបាល ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ចូលរួមដោយមន្ត្រីខ្មែរនិងមន្ត្រីមកពីអង្គការសហប្រជាជាតិ ។ ទោសបញ្ញត្តិអតិបរមាត្រឹមដាក់ពន្ធនាគារអស់មួយជីវិត ។ សភាជាតិកម្ពុជាបានអនុម័តច្បាប់នេះដើម្បីបង្កើតអង្គតុលាការមួយដោយផ្អែកលើលក្ខខណ្ឌទាំងអស់នេះ ។

មនុស្សអាក្រក់ដែលបាននិងកំពុងតែគាំពារមេដឹកនាំខ្មែរក្រហមអស់រយៈពេល២៤ឆ្នាំ និងដែលមានអ្នកច្បាប់ការពារយ៉ាងត្រឹមត្រូវនោះ បានផុសចេញជាថ្មីម្តងទៀតកាន់តែច្បាស់ ។ នៅខែកុម្ភៈ ឆ្នាំ២០០២ អ្នកចរចាមកពីអង្គការសហប្រជាជាតិសម្រេចចិត្តដកខ្លួនថយឈប់ចរចា ហើយមានតែសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិនៅខែធ្នូទេ ដែលធ្វើឲ្យអ្នកចរចាវិលត្រឡប់មកសាជាថ្មី ។ អង្គការលើកលែងទោសអន្តរជាតិនិងអង្គការឃ្លាំមើលសិទ្ធិមនុស្សបានជំទាស់ទៅនឹងសេចក្តីសម្រេចនេះ ពីព្រោះសេចក្តីសម្រេចបញ្ជាឲ្យអង្គការសហប្រជាជាតិផ្អែកកិច្ចព្រមព្រៀងនេះទៅលើច្បាប់កម្ពុជាដែលខ្លួនយល់ថាមានភាពខ្វះចន្លោះ ។

រដ្ឋាភិបាលកម្ពុជាបានធ្វើតាមការទាមទារសំខាន់ៗបីរបស់អង្គការសហប្រជាជាតិ ។ រដ្ឋាភិបាលកម្ពុជាព្រមព្រៀងថា នឹងធ្វើវិសោធនកម្មលើច្បាប់កម្ពុជាដើម្បីធ្វើឲ្យដំណើរការប្តឹងឧទ្ធរណ៍មានលក្ខណៈងាយស្រួលជាងមុន បញ្ចូលសិទ្ធិរបស់ជនជាប់ចោទដូចដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ព្រមទាំងបញ្ជាក់ថា អនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាហាមមិនឲ្យប្រើច្បាប់ជាតិដើម្បីគេចពីកាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិបានទេ ។

អង្គការលើកលែងទោសអន្តរជាតិ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស គឺជាអង្គការសិទ្ធិមនុស្សដ៏ឆ្នើម ។ ប៉ុន្តែសម្រាប់កម្ពុជា អង្គការទាំងពីរនេះទទូចចង់បានតុលាការមួយផ្សេងពីនេះពោល គឺមិនមែនតុលាការដែលប្រជាជនកម្ពុជានឹងទទួលស្គាល់ថា ជាតុលាការរបស់ខ្លួននោះឡើយ ។ ចំណុចខ្វះខាតមួយក្នុងចំណោមចំណុចខ្វះខាតនានារបស់តុលាការនៅយូហ្គោស្លាវី និងរ៉្វាន់ដា គឺកង្វះទំនាក់ទំនងជាមួយប្រព័ន្ធច្បាប់ជាតិ ។ តាំងពីដើមដល់ចប់នៃការរិះគន់របស់អង្គការលើកលែងទោសអន្តរជាតិ គឺអង្គការនេះធ្វើមិនអើពើទៅលើការពិតថាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា គឺបំពេញឲ្យគ្នាទៅវិញទៅមកចំពោះច្បាប់កម្ពុជាអនុម័តឆ្នាំ២០០១ ។ អង្គការលើកលែងទោសអន្តរជាតិថែមទាំងមិនបានបន្ថែមអត្ថបទច្បាប់កម្ពុជាភ្ជាប់ទៅនឹងរបាយការណ៍របស់ខ្លួនទៀតផង ដែលមានកិច្ចព្រមព្រៀងនិងរបាយការណ៍របស់លោកអគ្គលេខាជូនមហាសន្និបាតអង្គការសហប្រជាជាតិ ។

អង្គការលើកលែងទោសអន្តរជាតិ មិនពេញចិត្តត្រង់ថាកិច្ចព្រមព្រៀងនេះមិនបានលើកឡើងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ពាក់ព័ន្ធដល់ការចាប់ខ្លួននិងការជម្រះក្តីឲ្យបានឆាប់រហ័ស ។ ប៉ុន្តែកម្ពុជាមានកាតព្វកិច្ចតាមផ្លូវច្បាប់រួចទៅហើយ ជាភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ហើយកម្ពុជាបានលើកឡើងជាថ្មីម្តងទៀតនូវសិទ្ធិទាំងនេះនៅក្នុងមាត្រា ៣៥ នៃច្បាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលខ្លួនបានអនុម័តរួចហើយ ។

អង្គការលើកលែងទោសអន្តរជាតិនិយាយថា "ចៅក្រមចម្រុះរវាងខ្មែរនិងអន្តរជាតិ និងដំណើរការធ្វើការសម្រេចចិត្តដ៏ស្មុគស្មាញមិនដែលមានពីមុនទៅនៅក្នុងប្រវត្តិតុលាការក្នុងស្រុកឬអន្តរជាតិ" ដោយធ្វើជាមិនដឹងមិនឮចំពោះតុលាការនៅសេរ៉ាឡេអូន និងតុលាការនៅទីម័រខាងកើត និងកូសូវ៉ូ ដែលក៏ជាតុលាការចម្រុះដែរ ។

អង្គការលើកលែងទោសអន្តរជាតិនិយាយថា "គ្មានប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ការពារឲ្យជនជាប់ចោទអាចប្តឹងទាមទារប្រកបដោយជោគជ័យនូវអ្វីដែលខ្លួនធ្វើតាមបញ្ជាថ្នាក់លើនោះទេ" ដែលចំណុចនេះគេភ្លេចមើលនៅក្នុងមាត្រា ២៩ នៃច្បាប់កម្ពុជា ដែលនិយាយថា "ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពីឧក្រិដ្ឋកម្មទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយឲ្យជនសង្ស័យនេះរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ" ។

អង្គការលើកលែងទោសអន្តរជាតិ សម្តែងការមិនពេញចិត្តតទៅទៀតថា "មិនមានការចែងឲ្យគ្រប់គ្រាន់អំពីការការពារដល់ជនរងគ្រោះនិងសាក្សី" ត្រង់ចំណុចនេះគេភ្លេចគិតដល់មាត្រា២៣ នៃកិច្ចព្រមព្រៀង និងមាត្រា៣៣ នៃច្បាប់កម្ពុជាដែលមាត្រាទាំងពីរនេះចែងថា "តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារដល់អត្តសញ្ញាណរបស់ជនរងគ្រោះឡើយ" ។ អង្គការលើកលែងទោសអន្តរជាតិផ្តល់ជាអនុសាសន៍ថា "ភាពខ្វះចន្លោះទាំងនេះ" គួរតែជួសជុលដោយឯកសារក្រោយមួយទៀតដែលជាចម្លើយពេញលេញចំពោះការរិះគន់របស់អង្គការនេះ ។

អង្គការលើកលែងទោសអន្តរជាតិ រិះគន់ចំពោះកិច្ចព្រមព្រៀងនេះ ពីព្រោះកិច្ចព្រមព្រៀងនេះមិនបានបញ្ចូលបទបញ្ញត្តិនានាអំពីសំណងការខូចខាត ដោយហៅថា "នេះគឺជាការខុសប្លែកយ៉ាងច្រើនពីច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម" ទោះបីជាបទបញ្ញត្តិទាំងនេះមិនមែនជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌នៃច្បាប់ ខំមិនឡាភាគច្រើនក៏ដោយ ។ តុលាការកម្ពុជានឹងវិនិច្ឆ័យទោសតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះ ។ បុរសវ័យ

ចំណាស់ចំនួន១០រូបមិនអាចមានមធ្យោបាយគ្រប់គ្រាន់នឹងបេញសំណងខូចខាតឬសំណងជំងឺចិត្តដល់ជនរងគ្រោះ១លាន៧សែននាក់នោះទេ ។ មូលនិធិអាណាព្យាបាលភាពរបស់អង្គការសហប្រជាជាតិសម្រាប់តុលាការនេះមិនអាចទទួលជោគជ័យក្នុងការស្វែងរកថវិកាសម្រាប់បម្រើគោលបំណងនេះបានទេ ។ អង្គការលើកលែងទោសអន្តរជាតិ ចង់បាន "ការស្តារនីតិសម្បទាការបំពេញចិត្ត និងការធានាមិនឲ្យមានអំពើទាំងនេះកើតឡើងសាជាថ្មី" ។ ជាការពិតណាស់ មានការបំពេញចិត្តនិងការធានាមិនឲ្យមនុស្សឃាតក្នុងទ្រង់ទ្រាយធំដែលតុលាការអាចផ្តល់ឲ្យបានមានតែការជំនុំជម្រះក្តីនិងការដាក់ទណ្ឌកម្មចារីប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ ។

ចុងក្រោយ អង្គការលើកលែងទោសអន្តរជាតិ សង្ឃឹមថាតុលាការនេះនឹងជួយស្ថាបនាឡើងវិញនូវប្រព័ន្ធយុត្តិធម៌ទាំងមូលនៅកម្ពុជា ។ ដោយការបង្កើតជាគំរូនៃការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ នៅក្នុងតុលាការមួយដែលរៀបចំបានត្រឹមត្រូវនោះ វាច្បាស់ជាសម្រេចបាននូវគោលដៅនេះមិនខាន ។ នេះក៏ជាហេតុផលមួយដែរសម្រាប់បង្កើតតុលាការពិសេសនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ និងស្ថិតនៅទីក្រុងភ្នំពេញ ។ ប៉ុន្តែការបដិសេធទៅលើសេចក្តីព្រាងច្បាប់ដោយមូលហេតុថាតុលាការមិនអាចធ្វើអ្វីៗបាន គឺមានន័យស្មើនឹងការពោលពាក្យថា ដោយមូលហេតុអ្នកល្មើសច្បាប់ទាំងអស់មិនអាចត្រូវចាប់ខ្លួននិងយកមកវិនិច្ឆ័យទោសអ៊ីចឹងដែរ ។ ប្រការនេះមិនគួរធ្វើទៅរួចទេ ។

ប្រការដែលថាធ្វើតាមផ្លូវនេះរួចឬមិនរួចសម្រាប់ផ្តល់យុត្តិធម៌នៅកម្ពុជា គឺជាអត្តចរិតរបស់ក្រុមសិទ្ធិមនុស្សតាំងពីមុនដំបូងមកម៉្លេះ ។ នៅឆ្នាំ១៩៨១ នៅពេលដែលខ្ញុំសំណូមពរឲ្យគណៈកម្មការអ្នកច្បាប់អន្តរជាតិស៊ើបអង្កេតទៅលើករណីអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហមនោះ ប្រធាននៃក្រុមប្រឹក្សាភិបាលបានបដិសេធដោយឲ្យហេតុផលថា ប្រសិនបើគេមិនអាចស៊ើបអង្កេតទៅលើការរំលោភរបស់រដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមដែលផ្តួលខ្មែរក្រហមចេញពីអំណាចនោះទេ គេក៏មិនអាចស៊ើបអង្កេតទៅលើមនុស្សឃាតទ្រង់ទ្រាយធំប្រព្រឹត្តឡើងដោយខ្មែរក្រហមបានដែរ ។ គ្រប់គំរូនៃគំនិតថា "កើតឬមិនកើត" គឺទទួលការបរាជ័យដោយខ្លួនឯង ។ សុក្រឹតភាពគឺជាសត្រូវនៃយុត្តិធម៌ ។

ប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌អស់២៤ឆ្នាំហើយ ។ របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ សុំឲ្យមានការចរចាបន្តទៀត ។ មេដឹកនាំខ្មែរក្រហមដែលនៅរស់មានវ័យកាន់តែចាស់ រស់នៅដោយសុខស្រួល ។ មហាសន្និបាតអង្គការសហប្រជាជាតិគួរតែអនុម័តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកវិនិច្ឆ័យទោសឲ្យខាងតែបាន ។

**ហ្គ្រេហ្គោរី ស្តេនតុន**

## ទស្សនៈនិងការព្រួយបារម្ភរបស់អង្គការលើកលែងទោសអន្តរជាតិ

ក្រោយពីមានការចរចាពីរលើកនៅទីក្រុងញូវយ៉កនិងក្រុងភ្នំពេញមក សេចក្តីព្រាង កិច្ចព្រមព្រៀងមួយត្រូវបានសម្រេចរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ។

អង្គការលើកលែងទោសអន្តរជាតិបានស្វាគមន៍ចំពោះរាល់ជំហានឆ្ពោះទៅមុខដែលធ្វើឲ្យប្រាកដថា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតទៅលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរត្រូវនាំមកវិនិច្ឆ័យទោសទៅតាមច្បាប់ដែលមានគំរូបទដ្ឋានអន្តរជាតិ ។

អង្គការនេះស្វាគមន៍ចំពោះបទបញ្ញត្តិមួយចំនួនដែលចែងនៅក្នុងសេចក្តីព្រាងច្បាប់ក្នុងនោះ រួមមានការមិនរាប់បញ្ចូលចំពោះការលើកលែងទោស និងការអនុគ្រោះទោសចំពោះជនណាដែលត្រូវបានស៊ើបអង្កេត និងជាប់ចោទពីបទឧក្រិដ្ឋដែលចែងនៅក្នុងកិច្ចព្រមព្រៀង ។ ប៉ុន្តែអង្គការលើកលែងទោសអន្តរជាតិ សម្តែងនូវការព្រួយបារម្ភទៅលើចំណុច

(តទៅទំព័រ៤២)

# អង្គការសហប្រជាជាតិព្រមព្រៀងជាមួយកម្ពុជា ក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម

ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីព្រាងក្នុងការបង្កើតតុលាការពិសេសសម្រាប់វិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។

មហាសន្និបាតអង្គការសហប្រជាជាតិដែលមានសមាជិកចំនួន១៩១រូប បានអនុម័តជាឯកច្ឆ័នទៅលើសេចក្តីសម្រេចអំពីសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការពិភពលោកនិងកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា ទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មហាសន្និបាតក៏បានសម្រេចធ្វើហិរញ្ញប្បទានដល់អង្គជំនុំជម្រះតាមរយៈវិភាគទានដោយស្ម័គ្រចិត្ត មិនមែនតាមរយៈថវិកានិយ័តរបស់អង្គការសហប្រជាជាតិទេ ។

សេចក្តីព្រាងច្បាប់ដែលមាន៣២មាត្រានឹងបង្កើតនូវ "អង្គជំនុំជម្រះវិសាមញ្ញ" ដែលមានសាលាដំបូងនិងតុលាការកំពូល នៅក្នុងរចនាសម្ព័ន្ធតុលាការជាតិរបស់កម្ពុជាដែលមានស្រាប់ និងមានចៅក្រមចម្រុះអន្តរជាតិនិងខ្មែរ ។ តាមគម្រោងដែលសង្កត់ធ្ងន់ទៅលើភាពមិនលម្អៀងនិងឯករាជភាពរបស់អ្នកច្បាប់ដែលនឹងចូលមកកាន់តំណែងរៀងៗខ្លួននោះ សេចក្តីសម្រេចនៅក្នុងអង្គជំនុំជម្រះទាំងពីរថ្នាក់នេះនឹងធ្វើឡើងដោយមតិភាគច្រើននៃចៅក្រមបួនរូបនៅសាលាដំបូង និងប្រាំរូបនៅតុលាការកំពូល ។

គម្រោងនេះក៏ចែងអំពីតួនាទីរបស់ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត វិធាននៃនីតិវិធី សិទ្ធិរបស់ចុងចោទ និងនីតិវិធីគ្រប់គ្រងសាក្សីនិងកសិណសាក្សី កោសល្យវិច័យ ។ ទាក់ទងនឹងការលើកលែងទោស គម្រោងនេះចែងថា "រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យមានការលើកលែងទោសឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេតឬនឹងផ្តន្ទាទោស អំពីឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ" ។

សេចក្តីសម្រេចដែលត្រូវបានអនុម័តនៅថ្ងៃនេះ ជំរុញឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ និងរាជរដ្ឋាភិបាលកម្ពុជា "ចាត់វាល់វិធានការដែលខ្លួនមានដើម្បីឲ្យកិច្ចព្រមព្រៀងនេះចូលជាធរមាននិងប្រតិបត្តិឲ្យបានពេញលេញ" ។ មហាសន្និបាតក៏បានអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់នូវជំនួយរួមទាំងការគាំទ្រខាងហិរញ្ញវត្ថុនិងបុគ្គលិកដល់អង្គជំនុំជម្រះវិសាមញ្ញ ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានព្រមាននៅក្នុងរបាយការណ៍ថា "ឱកាសក្នុងការនាំយកជនទាំងឡាយដែលទទួលខុសត្រូវមកតុលាការអាចត្រូវខកខាន" ប្រសិនបើតុលាការទទួលហិរញ្ញប្បទានតាមរយៈវិភាគទានស្ម័គ្រចិត្តមិនមែនប្រើថវិកានិយ័ត ។ ក្នុងខណៈដែលអ្នកការទូតអបអរសាទរនៅដើមខែនេះដល់មតិឯកច្ឆ័នដែលអនុម័តដោយគណៈកម្មាធិការទទួលបន្ទុកសង្គមកិច្ច មនុស្សធម៌ និងវប្បធម៌ របស់អង្គការសហប្រជាជាតិដែលធ្វើការរឿងសិទ្ធិមនុស្ស អ្នកការទូតទាំងនោះក៏បាននិយាយរំពឹកថា យុត្តិធម៌អាចត្រូវបរាជ័យប្រសិនបើរដ្ឋាភិបាលនានាខកខានមិនបានចូលរួមវិភាគទានដោយសប្បុរសដល់ដំណើរការរបស់អង្គតុលាការនោះទេ ។

***សេចក្តីប្រកាសពត៌មាន***

**GA/១០១៣៥**

មហាសន្និបាតពេញអង្គលើកទី៥៧

សម័យប្រជុំលើកទី៨៥

នាព្រឹកនេះមហាសន្និបាតបានអនុម័តជាឯកច្ឆ័នទៅលើអត្ថបទព្រាងកិច្ចព្រមព្រៀងដែលមាន៣២មាត្រា រវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាស្តីអំពីបញ្ហាខ្មែរក្រហម ។

តាមរយៈការអនុម័តនូវសេចក្តីសម្រេចព្រៀងដែលលើកឡើងនៅក្នុងរបាយការណ៍របស់គណៈកម្មាធិការទីបី (សង្គមកិច្ច មនុស្សធម៌ និងវប្បធម៌) ទាក់ទងនឹង"ការកាត់សេចក្តីក្រោមច្បាប់កម្ពុជាទៅលើឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យ” មហាសន្និបាតក៏បានសម្រេចថា ចំណាយចេញពីអង្គការសហប្រជាជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ នឹងចេញពីវិភាគទានស្ម័គ្រចិត្តរបស់សហគមន៍អន្តរជាតិ ។ មហាសន្និបាតអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់នូវជំនួយរួមទាំងការគាំទ្រខាងហិរញ្ញវត្ថុនិងបុគ្គលិកដល់អង្គជំនុំជម្រះវិសាមញ្ញ ។

នៅក្នុងការពន្យល់នៅពេលបោះឆ្នោត តំណាងមកពីសហរដ្ឋអាមេរិកបាននិយាយថា ប្រទេសរបស់ខ្លួនគាំទ្រខ្លឹមសារសេចក្តីសម្រេចថ្មីនេះ ប៉ុន្តែមិនបានចូលរួមនៅក្នុងការសម្តែងមតិឯកច្ឆ័ន្ទទេ ដោយសារមានបញ្ហាទៅលើការកំណត់ពេលវេលា ។ វាគួរតែល្អក្នុងការពន្យារពេលការពិចារណាទៅលើអត្ថបទនេះរហូតដល់ក្រោយពេលបោះឆ្នោតជ្រើសតាំងសភាកម្ពុជា នៅខែកក្កដា ។

តំណាងមកពីប្រទេសជប៉ុនដែលជាអ្នកសហការរ៉ាប់រងនូវសេចក្តីសម្រេចនេះ ក៏បានពន្យល់ដែរថា កិច្ចព្រមព្រៀងដែលអនុម័តរួចហើយនេះបាននាំមកនូវយុត្តិធម៌ចំពោះបទឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅសតវត្សរ៍ទី២០ នេះមួយជំហានរួចទៅហើយ ។ ម្យ៉ាងវិញទៀត កិច្ចព្រមព្រៀងនេះនឹងធ្វើឲ្យសន្តិសុខតំបន់កាន់តែប្រសើរឡើង ។ លោកសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញដែលជួយជ្រោមជ្រែងដោយអង្គការសហប្រជាជាតិ នឹងពង្រឹងប្រព័ន្ធច្បាប់កម្ពុជា និងនាំមកនូវការបញ្ចប់និទណ្ឌភាព ។ ដោយអំពាវនាវជាថ្មីម្តងទៀតចំពោះសហគមន៍អន្តរជាតិឲ្យផ្តល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញ លោកតំណាងប្រទេសជប៉ុនក៏បានអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាធ្វើកិច្ចសហប្រតិបត្តិការរួមទាំងការផ្តល់សច្ចាប័នដល់សេចក្តីព្រាងកិច្ចព្រមព្រៀងឲ្យបានឆាប់ៗ ។

របាយការណ៍ដែលមានរួមជាមួយអត្ថបទព្រាងកិច្ចព្រមព្រៀងឯកសារលេខ A/៥៧/៨០៦ ផ្តល់ជូនដោយ អ្នកសាណាបូអ៊ីកូ (ជនជាតិអ៊ុយក្រែន) ជាអ្នកធ្វើរបាយការណ៍ពិសេសនៃគណៈកម្មាធិការទីបី ។

# សម្រង់កិច្ចសម្ភាសន៍ជាមួយលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅសាកលវិទ្យាល័យយែល សហរដ្ឋអាមេរិក ថ្ងៃពុធ ទី២ ខែតុលា ឆ្នាំ២០០២

**សំណួរៈ** សូមលោកអគ្គលេខាជួយផ្តល់យោបល់ទៅលើជំហររបស់សហរដ្ឋអាមេរិកចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

**លោក កូហ្វី អាណាន់ៈ** សាកលវិទ្យាល័យយែលមាននិស្សិតឆ្នើមៗជាច្រើនរូប ។ ចំពោះរឿងតុលាការនេះកាលពីដើមឆ្នាំយើងបានបើកការពិភាក្សាដ៏ធំមួយនៅឯស្នាក់ការអង្គការសហប្រជាជាតិ នៅពេលដែលសហរដ្ឋអាមេរិកស្នើសុំឲ្យមានការលើកលែងពិសេសសម្រាប់ទាហាននិងពលរដ្ឋអាមេរិក ។ ទង្វើនេះពិតជាធ្វើឲ្យមានការរំខានដល់ប្រទេសជាសមាជិកពិសេសប្រទេសដែលបានផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ហើយព្រួយបារម្ភថា វាអាចជាឧបសគ្គដល់តុលាការនេះមុនពេលដែលវាចាប់ដំណើរការទៅទៀត ។ ប្រទេសទាំងនេះមានជំនឿយ៉ាងមុតមាំថានឹងមិនធ្វើអ្វីដែលផ្ទុយនឹងលក្ខន្តិកៈនៃតុលាការនេះទេ ។ សហរដ្ឋអាមេរិកបានបញ្ជាក់ថា ខ្លួននឹងព្យាយាមបង្កើតនូវកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងរដ្ឋាភិបាលទាំងនេះ ដើម្បីផ្តល់ឲ្យពលរដ្ឋអាមេរិកនូវសិទ្ធិពិសេសដែលខ្លួនបានស្នើសុំ ។ ខ្ញុំយល់ថា កិច្ចព្រមព្រៀងជាច្រើនត្រូវបានចុះហត្ថលេខារួចជាស្រេចទៅហើយ ។ សហភាពអឺរ៉ុបបានពិនិត្យសាឡើងវិញទៅលើបញ្ហានេះ ហើយទំនងជាជឿជាក់ថាខ្លួនបានរកឃើញនូវការសម្របសម្រួលមួយដែលសម្រេចថា សហភាពអឺរ៉ុបនឹងមិនតាមចាប់ខ្លួនពលរដ្ឋអាមេរិកទេ ប្រសិនបើពលរដ្ឋអាមេរិកត្រូវបាននាំឡើងតុលាការអាមេរិក ។

មធ្យោបាយនេះ បើមើលទៅក៏ជាអ្វីដែលមានចែងនៅក្នុង

លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមដែរ ។ លក្ខន្តិកៈបានចែងយ៉ាងច្បាស់ថា ប្រទេសណាដែលមានប្រព័ន្ធច្បាប់ត្រឹមត្រូវ ហើយរដ្ឋាភិបាលនៃប្រទេសនោះរៀបចំជាស្រេចដើម្បីនាំជនជាប់ចោទទៅតុលាការដើម្បីកាត់ទោស តុលាការព្រហ្មទណ្ឌអន្តរជាតិគ្មានកាតព្វកិច្ចទេ លើកលែងតែនៅក្នុងករណីដែលរដ្ឋាភិបាលប្រទេសនោះមិនអាច ឬគ្មានឆន្ទៈក្នុងការកាត់ទោស ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិលូកដៃចូល ហើយចាត់វិធានការបាន ។ ដូច្នេះ ប្រសិនបើប្រទេសទាំងនេះអាចរកដំណោះស្រាយដែលសមស្របទៅតាមលក្ខន្តិកៈច្បាប់ ខ្ញុំដូចជាពុំឃើញមានបញ្ហាអ្វីធំដុំទេ ។ ប៉ុន្តែប្រសិនបើរឿងរ៉ាវវែងឆ្ងាយជាងនេះទៀត ហើយដំណោះស្រាយដែលលើកឡើងធ្វើតុលាការព្រហ្មទណ្ឌអន្តរជាតិបាត់បង់អំណាច នោះវានឹងបង្កើតឲ្យមានបញ្ហាច្រើនគួរសមដែរ ។ ទោះបីជាសហរដ្ឋអាមេរិកមិនបានផ្តល់សច្ចានុម័តសម្រាប់លក្ខន្តិកៈច្បាប់នេះក៏ដោយ ក៏អាមេរិកបានចុះហត្ថលេខា ហើយបញ្ជាក់ថា ខ្លួននឹងមិនផ្តល់សច្ចានុម័តទេ ។ អ្នកខ្លះថា សហរដ្ឋអាមេរិកបានសុំលុបហត្ថលេខាវិញ ។ ខ្ញុំពុំគិតថា មនុស្សម្នាក់អាចលុបហត្ថលេខានៅលើឯកសារដែលខ្លួនបានស៊ីញ៉េនោះទេ ។ នេះជាការពិតជាប្រវត្តិសាស្ត្រ ។ ប៉ុន្តែអ្នកនោះអាចសម្រេចចិត្តថាមិនផ្តល់សច្ចានុម័តបាន ។

ប៉ុន្តែបើតុលាការព្រហ្មទណ្ឌអន្តរជាតិចាប់ដំណើរការសម្រេចការងារបានជោគជ័យ តែងតាំងព្រះរាជអាជ្ញានិងចៅក្រមចំណាន១ ហើយធ្វើការងារបានល្អដែលនាំឲ្យមានការជឿទុកចិត្ត ខ្ញុំនឹងមិនភ្ញាក់ផ្អើលទេបើឃើញសហរដ្ឋអាមេរិកងាកមករកតុលាការនេះ ហើយសហរដ្ឋអាមេរិកប្រហែលជាត្រូវការតុលាការនេះច្រើនជាងប្រទេសដទៃ ពីព្រោះអាមេរិកមានទំនាក់ទំនងអន្តរជាតិច្រើនជាងប្រទេសណា១ទាំងអស់ ។ ហើយប្រហែលជាអាចមានស្ថានភាពខ្លះដែលអាមេរិកត្រូវការតុលាការនេះដើម្បីដោះស្រាយបញ្ហា ។

មុនពេលការបង្កើតតុលាការនេះឡើង យើងត្រូវបង្កើតនូវតុលាការពិសេស ។ យើងបានបង្កើតតុលាការពិសេសមួយសម្រាប់ប្រទេសប៊ូស្នី មួយសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ហើយកំពុងបង្កើតមួយទៀតសម្រាប់ប្រទេសសេរ៉ាឡេអូន ។ កន្លងមកខ្ញុំបានចរចាជាមួយលោក ហ៊ុន សែន នៅប្រទេសកម្ពុជាក្នុងគោលបំណងបង្កើតតុលាការចម្រុះមួយសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ តើនៅមានតុលាការពិសេសបៀបនេះប៉ុន្មានទៀតដែលយើងនឹងត្រូវបង្កើត? តាមពិតតុលាការទាំងនេះក៏ត្រូវបានសង្កេតឃើញថា ជាការផ្តល់យុត្តិធម៌ទៅឲ្យជនរងគ្រោះដែរ ។ ខ្ញុំចង់និយាយថា ប្រសិនបើយើងទៅនិយាយជាមួយលោក ស្លូបូដាន់ មីឡូសើវិក ថ្ងៃនេះ គាត់ពិតជានិយាយថា បើគាត់ឈ្នះ គាត់ប្រាកដជាមិនត្រូវនាំឡើងតុលាការទេ ។ អ៊ីចឹង យើងមានស្ថានភាពបែបនេះឯង ។ ប្រសិនបើយើងមានតុលាការព្រហ្មទណ្ឌអន្តរជាតិ ខ្ញុំគិតថាយើងនឹងអាចចៀសផុតពីការចោទប្រកាន់និងភាពគានតឹងទាំងនេះបាន ហើយខ្ញុំក៏ជឿជាក់ដែរថា នៅទីបំផុត យើងកំពុងតែដាក់បំពេញនូវកង្វះចន្លោះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះថារហូតដល់ពេលដែលតុលាការពិសេសទាំងនោះបានបង្កើតឡើង វាជាការងាយក្នុងការនាំខ្លួនបុរសម្នាក់មកតុលាការបើគាត់បានសម្លាប់មនុស្សពីរបីនាក់ ប៉ុន្តែបើគាត់សម្លាប់មនុស្សរាប់រយនាក់ ហើយទទួលខុសត្រូវចំពោះការសម្លាប់រង្គាលទៅលើជាតិពន្ធុណាមួយ យើងគ្មានមធ្យោបាយកាត់ទោសគាត់ទេ ។ ជាទូទៅបុរសនេះច្រើនតែជាប្រធានាធិបតីឬឧត្តមសេនីយ៍ ហើយរស់នៅដោយសុខស្រួល ។ ពេលនេះ២០ឆ្នាំក្រោយមក យើងកំពុងតែពិចារណាអំពីអ្វីដែលយើងអាចធ្វើចំពោះខ្មែរក្រហម ហើយយើងត្រូវបង្កើតតុលាការពិសេសមួយតាមវិធីណាដើម្បីកាត់ទោសជនដែលបានសម្លាប់មនុស្សរាប់លាននាក់ទាំងនោះ ។ ឥឡូវនេះយើងមានតុលាការមួយ ហើយខ្ញុំសង្ឃឹមថាវានឹងរំឭកដល់ជនដែលគេងយកប្រយោជន៍ពីវប្បធម៌នៃការរួចទោសថា ពួកគេមិនអាចគេចផុតបានឡើយ ។ ជនទាំងនោះនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើ ហើយមានតុលាការមួយកំពុងតែរង់ចាំទទួល ។ ចំពោះសហរដ្ឋអាមេរិកដែលជាប្រទេសប្រជាធិបតេយ្យ ជឿជាក់ទៅលើច្បាប់ ខ្ញុំសង្ឃឹមថា នៅថ្ងៃអនាគតនឹងវិលមកគាំទ្រតុលាការព្រហ្មទណ្ឌអន្តរជាតិជាមិនខាន ។ មិនមែនថ្ងៃនេះឬថ្ងៃស្អែកទេ ប៉ុន្តែខ្ញុំគិតថាគោលជំហរនេះមិនឋិតថេរជារៀងរហូតទេ ហើយសហរដ្ឋអាមេរិកនឹងឡើងជិះទូកជាមួយគ្នា ។

***Yale Global Online Magazine***

# ជនរងគ្រោះនៃរបបខ្មែរក្រហមៈ ជនរងគ្រោះជាសម្ពហភាពនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

អំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលធ្វើឲ្យមនុស្សស្លាប់ប្រមាណ១លាន៧សែននាក់ (១២ភាគរយនៃចំនួនប្រជាជនកម្ពុជាសរុប) គឺជាសោកនាដកម្មមួយក្នុងចំណោមសោកនាដកម្មនានានៅសតវត្សរ៍ទី២០នេះ ។ ដូចជានៅក្នុងប្រទេសអាល្លឺម៉ង់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកណាហ្ស៊ីដែរ និងជាពិសេសនាពេលថ្មីៗនេះ នៅទីម័រខាងកើត ហ្គាតេម៉ាឡា យូហ្គោស្លាវី និងរ៉្វាន់ដា របបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានបញ្ចូលគ្នារវាងមនោគមវិជ្ជាជ្រុលនិយមជាមួយនឹងសម្អប់ជនជាតិភាគតិច និងការមើលងាយមើលថោកចំពោះជីវិតមនុស្ស បំប្លែងទៅជាការបង្ក្រាបមិនរើសមុខ បន្ទុកទុក្ខវេទនា និងឃាតកម្មក្នុងទ្រង់ទ្រាយធំ ។ នៅក្នុងអំឡុងពេលនៃរបបប្រល័យពូជសាសន៍នេះ មានប្រជាជនរហូតដល់ជិតពាក់កណ្តាលក្លាយទៅជាជនរងគ្រោះដោយសារការសម្លាប់ក្រៅផ្លូវតុលាការជាទូទៅច្រើនតែក្នុងស្ថានភាពឃោរឃៅ ។

ជាការចែករំលែកឯកសារអំពីអ្នកបាត់ខ្លួនដើម្បីចូលរួមដល់ការផ្សះផ្សារបួសអំពើប្រល័យពូជសាសន៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមែប្រមូលឯកសារជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ ដើម្បីផ្តល់ជូនគ្រួសារនិងមិត្តភក្តិរបស់ជនរងគ្រោះឲ្យដឹងអំពីជោគវាសនានៃជនបាត់ខ្លួនទាំងនោះទាំងនោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតឡើងដើម្បីរក្សានូវការចងចាំនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលប្រព្រឹត្តឡើងចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ តាមរយៈប្រព័ន្ធស្វែងរកគ្រួសារ ។ នៅពេលដែលក្រុមគ្រួសារនិងមិត្តភក្តិប្រមូលបាននូវព័ត៌មានដ៏មានតម្លៃនេះហើយ អ្នកទាំងនោះអាចនឹងមានអារម្មណ៍ឈប់គិតខ្វល់ខ្វាយ ។ សេវាកម្មនេះធ្វើឡើងដើម្បីជំរុញឲ្យប្រជាជនកម្ពុជាដោះស្រាយអតីតកាលនៃប្រទេសរបស់ខ្លួន ដោយសង្ឃឹមថាទង្វើនេះនឹងនាំឲ្យខ្លួនជាសះស្បើយពីដំណើរប៉ះទង្គិចផ្លូវចិត្តនៃរបបប្រល័យពូជសាសន៍ ។ ទន្ទឹមពេលនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏កំពុងតែស្វែងរកភ័ស្តុតាងតាមផ្លូវច្បាប់ ដែលអាចយកមកប្រើប្រាស់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការដើម្បីនាំយកយុត្តិធម៌ដល់ប្រជាជនកម្ពុជាថែមទៀត ។

អត្ថបទរបស់ខ្ញុំដែលផ្តោតលើ *"ជនរងគ្រោះខ្មែរក្រហមៈ ជនរងគ្រោះជាសម្ពហភាពនៃអំពើប្រល័យពូជសាសន៍"* បញ្ជាក់ច្បាស់ថា ជនរងគ្រោះក្រោមរបបខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺជាជនរងគ្រោះជាសម្ពហភាពនៃអំពើប្រល័យពូជសាសន៍ ប្រយោជន៍ដើម្បីផ្តល់នូវបទពិសោធន៍ផ្ទាល់ខ្លួនទៅក្នុងការពិភាក្សាជាមួយនិស្សិតដទៃៗទៀត និងមិត្តរួមជំនាន់នៅក្នុងវគ្គ "ការចងចាំរួមគ្នានៅក្នុងសង្គមបែកបាក់" ដែលរៀបចំឡើងនៅសាកលវិទ្យាល័យខែបថោន ប្រទេសអាហ្វ្រិកខាងត្បូង ។

ជាងនេះទៅទៀត អត្ថបទនេះនឹងជួយចែករំលែកគំនិតជាមួយសង្គមស៊ីវិល សកម្មជនសិទ្ធិមនុស្ស អ្នកតាក់តែងនយោបាយ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដើម្បីកំណត់ឲ្យច្បាស់អំពីបទល្មើសប្រព្រឹត្តឡើងដោយខ្មែរក្រហម ក្នុងគោលបំណងកាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលមានតុលាការប្រល័យពូជសាសន៍នៅកម្ពុជា ។ ទោះបីជាតុលាការនេះមានលក្ខណៈត្រឹមត្រូវទៅតាមបទដ្ឋានអន្តរជាតិ ឬក៏អត់ អត្ថបទរបស់ខ្ញុំនឹងបញ្ជាក់ច្បាស់អំពីកត្តាកំណត់ និងដំណើរការនានាទាក់ទងដល់តួនាទីរបស់ជនរងគ្រោះខ្មែរក្រហមនៅក្នុងការបង្រួបបង្រួមផ្សះផ្សានៅកម្ពុជា ។

ខ្ញុំជ្រើសរើសប្រធានបទនេះមកសរសេរដោយសារថាជម្លោះហិង្សាបង្កើតឲ្យមានជនរងគ្រោះគ្រប់ប្រភេទ ពោលគឺអ្នក

ដែលត្រូវបានសម្លាប់និងធ្វើទារុណកម្ម អ្នកដែលនិរាសព្រាត់ប្រាសគ្រួសារ និងក្លាយជាជនពិការ អ្នកដែលត្រូវបំពារបំពានលើរូបរាងកាយ អ្នករងរបួសដោយសារមីននៅក្នុងសមរភូមិ អ្នកដែលត្រូវចាប់ពង្រត់និងឃុំឃាំង អ្នកគ្មានផ្ទះសម្បែង អ្នកដែលទទួលរងការបំភិតបំភ័យនិងធ្វើឲ្យអាម៉ាស់មុខ ។

នៅក្នុងអត្ថបទនេះ ខ្ញុំនឹងធ្វើការពិភាក្សាទៅលើបីចំណុច ។ ចំណុចទីមួយ ខ្ញុំនឹងបញ្ជាក់អំពីពាក្យថា "ជនរងគ្រោះ" និងចាត់ជនរងគ្រោះជាក្រុមផ្សេងគ្នា ។ ចំណុចទីពីរ ខ្ញុំនឹងពិនិត្យទៅលើទស្សនៈមតិប្រឆាំងទៅលើប្រការថា តើមេដឹកនាំខ្មែរក្រហមនឹងត្រូវកាត់ទោសពីបទប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបញ្ជាក់ត្រង់ចំណុចនេះដោយផ្អែកជាសំខាន់ទៅលើអនុសញ្ញាប្រល័យពូជសាសន៍ ព្រមទាំងបង្ហាញនូវលទ្ធផលសំខាន់ៗមួយចំនួនដែលបានមកពីការសិក្សាស្រាវជ្រាវលើបញ្ហានេះ ។ ចំណុចចុងក្រោយ ខ្ញុំវិភាគទៅលើតួនាទីជាវិជ្ជមាននៃជនរងគ្រោះនៅក្នុងការបង្រួបបង្រួមផ្សះផ្សា ទោះជាមានឬគ្មានបទដ្ឋានយុត្តិធម៌អន្តរជាតិចេញពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខនេះក៏ដោយ ។

## អត្ថសញ្ញាណកម្មនៃ "ជនរងគ្រោះ"

បើនិយាយទៅតាមសង្គមវិទ្យា ការក្លាយទៅជាជនរងគ្រោះគឺជាដំណើរការដែលពាក់ព័ន្ធយន្តការជាច្រើន ។ អង្គហេតុបញ្ជាក់អំពីផលប៉ះពាល់លើផ្លូវកាយ ផ្លូវចិត្ត ឬសេដ្ឋកិច្ច គឺជាការចាំបាច់ ប៉ុន្តែមិនទាន់ជាធាតុផ្សំដែលមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ។ កត្តាផ្សេងៗទៀតក៏ដើរតួនាទីសំខាន់ដែរ ។ បទដ្ឋានសង្គមនិងទំនៀមទម្លាប់ដែលវិវត្តនៅក្នុងនយោបាយ ច្បាប់ និងវប្បធម៌ គឺជាផ្នែកមួយក្នុងការកំណត់អំពីឋានៈជនរងគ្រោះ ។ គ្មានរដ្ឋណាមួយក្រោយពីមានជម្លោះ អាចធ្វើឲ្យជនរងគ្រោះគ្រប់ៗរូបចូលរួមនៅក្នុងដំណើរការផ្សះផ្សារ៉ាយរ៉ាប់ការពិត ការជំនុំជម្រះក្តី និងវិធានការសំណងជួសជុលការខូចខាតឡើយ ។ ប្រភពសម្ភារធនធាននិងហត្ថពលករមិនសម្បូរទាល់តែសោះ ។

## ការឲ្យនិយមន័យលើពាក្យ"ជនរងគ្រោះ"

ឥទ្ធិពលសង្គមនៅក្នុងដំណើរការឲ្យនិយមន័យថាអ្នកណាជាជនរងគ្រោះ គឺចេញមកពីប្រភពបី ÷

- កត្តាសង្គម-នយោបាយ
- ការឲ្យនិយមន័យតាមផ្លូវច្បាប់ និង
- ឥទ្ធិពលវប្បធម៌ទៅលើនិយមន័យ

សំខាន់ដូចគ្នានេះដែរ គឺគំនិតរបស់បុគ្គលម្នាក់ដែលរងគ្រោះ ។ តើគាត់ដឹងអំពីការរងគ្រោះមកលើរូបគាត់ដែរឬទេ? តើគាត់ប្រាថ្នាចង់បានឋានៈជាជនរងគ្រោះ ឬក៏មានចិត្តចង់បដិសេធនូវការចាត់ចូលក្នុងមនុស្សជំពូកនេះ?

## ការឲ្យនិយមន័យជាផ្លូវការទៅលើពាក្យ"ជនរងគ្រោះ"

១) យោងតាមសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទល្មើស និងការរំលោភអំណាច សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤០/៣៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨៥ បានឲ្យនិយមន័យថា នៅក្នុងករណីរំលោភអំណាច "ជនរងគ្រោះ" មានន័យថា "បុគ្គលដែលបានទទួលផលប៉ះពាល់មកលើរូបខ្លួនឯងផ្ទាល់ ឬដោយសមូហភាពនូវការខូចខាតខាងរាងកាយឬផ្លូវចិត្ត ការឈឺចាប់ក្នុងអារម្មណ៍ ការខូចប្រយោជន៍ខាងសេដ្ឋកិច្ច ឬខូចខាតសិទ្ធិជាសារវន្តតាមរយៈអំពើឬការខកខានដែលមិនទាន់ក្លាយជាការរំលោភទៅលើច្បាប់ព្រហ្មទណ្ឌជាតិ ប៉ុន្តែរំលោភទៅលើបទដ្ឋានដែលទទួលស្គាល់ដោយអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស" ។

២) នៅក្នុងគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សិទ្ធិទាមទារបដិទាន ការសងជំងឺចិត្ត និងការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងសេរីភាពជាសារវន្តៈ របាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេស លោក បាស៊ីអូនី ដោយយោងទៅតាមសេចក្តីសម្រេចរបស់គណៈកម្មការលេខ ១៩៩៩/៣៣" ឯកសាររបស់អង្គការសហប្រជាជាតិលេខ E/CN.៤/២០០០/៦២ សរសេរថា "ជនម្នាក់ជាជនរងគ្រោះ នៅពេលដែលជននោះទទួលនូវផលប៉ះពាល់ជាបុគ្គលក្តី ជាសមូហភាពក្តី រួមទាំងការខូចខាតខាងរាងកាយ ខាងផ្លូវចិត្ត និងការឈឺចាប់នៅក្នុងអារម្មណ៍ ការខូច

ប្រយោជន៍ខាងសេដ្ឋកិច្ច ឬការខូចខាតសិទ្ធិជាសារវន្តតាមផ្លូវច្បាប់ ដែលជាលទ្ធផលនៃអំពើ ឬការខកខានដែលបង្កើតបានជាការរំលោភទៅលើសិទ្ធិមនុស្សអន្តរជាតិ ឬបទដ្ឋានមនុស្សធម៌នានា ។ "ជនរងគ្រោះ" ក៏អាចជាអ្នកដែលនៅក្រោមឱវាទ ឬជាក្រុមគ្រួសារផ្ទាល់នៃជនរងគ្រោះផ្ទាល់ ក៏ដូចជាជនដែលបានទទួលរងនូវការប៉ះពាល់លើរូបរាងកាយ ផ្លូវអារម្មណ៍ ឬផ្លូវសេដ្ឋកិច្ច ដែលជននោះធ្វើអន្តរាគមន៍ជួយដល់ជនរងគ្រោះ ឬរារាំងមិនឲ្យកើតឡើងនូវការរំលោភបន្តទៅទៀត ។ (សេចក្តីប្រកាសស្តីអំពីសិទ្ធិក្នុងការទាមទារបដិទានរបស់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរឆ្នាំ១៩៩៩) ។

៣) នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ "ពាក្យប្រើសម្រាប់ច្បាប់លក្ខន្តិកៈ និងវិធាននៃនីតិវិធីនិងភស្តុតាង" ជាអត្ថបទចុងក្រោយអនុម័តដោយគណៈកម្មការរៀបចំកិច្ចប្រជុំលើកទី២៣ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០ ឯកសារលេខ PCNICC/២០០០/១/add.1): (ក) "ជនរងគ្រោះ" មានន័យថា ជារូបវន្តបុគ្គលដែលបានទទួលផលប៉ះពាល់ជាលទ្ធផលនៃការប្រព្រឹត្តិរាល់បទល្មើសនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការ ខ) ជនរងគ្រោះអាចរួមបញ្ចូលទាំងអង្គការចាត់តាំងស្ថាប័នដែលបានទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ និងជានិរន្តរ៍ទៅលើទ្រព្យសម្បត្តិដែលបម្រើឲ្យផលប្រយោជន៍សាសនា ការអប់រំ សិល្បៈ ឬវិទ្យាសាស្ត្រ ឬបម្រើឲ្យបំណងសប្បុរស និងវិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និងកន្លែងផ្សេងៗទៀត ព្រមទាំងវត្ថុនានាដែលបម្រើឲ្យផលប្រយោជន៍មនុស្សធម៌ ។

៤) នៅក្នុងរបាយការណ៍របស់គណៈកម្មការស្វែងរកការពិតនិងបង្រួបបង្រួមផ្សះផ្សានៃប្រទេសអាហ្វ្រិកខាងត្បូង គណៈកម្មាធិការជួសជុលការខូចខាតនិងស្តារនីតិសម្បទា កំណត់សាច់ញាតិនិងជនស្ថិតនៅក្នុងបន្ទុកគ្រួសារនៃជនរងគ្រោះដូចតទៅៈ ក) ឪពុកម្តាយ (ឬអ្នកដែលបានធ្វើសកម្មភាព ឬធ្វើសកម្មភាពជំនួសឲ្យឪពុកម្តាយ) ។ ខ) ប្តីប្រពន្ធ (យោងតាមច្បាប់ទំនៀមទម្លាប់ ច្បាប់ឥតមានលាយលក្ខណ៍អក្សរ ឬច្បាប់អន្តោគ្រាម) ។ គ) កុមារាកុមារី (ទោះជាកូនបង្កើតឬកូនចិញ្ចឹម) ។ ឃ) ជនណាដែលជនរងគ្រោះមានកាតព្វកិច្ចជាទំនៀមទម្លាប់ឬកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការគាំទ្រទំនុកបម្រុង ។

**ចំណាត់ថ្នាក់ "ជនរងគ្រោះ"**

ជនរងគ្រោះមានច្រើនប្រភេទណាស់ ។ គេចែកជនរងគ្រោះជាប្រាំប្រភេទ ។ ១) ជនរងគ្រោះជាបុគ្គល និង ជនរងគ្រោះជាសមូហភាព ២) ជនរងគ្រោះផ្ទាល់និងប្រយោល ៣) ជនរងគ្រោះជំនាន់ទីមួយនិងជំនាន់ទីពីរ ៤) ជនរងគ្រោះដោយសារភេទ និង ៥) ជនរងគ្រោះជាកុមារ ។ ច្បាស់ជាមានការពិភាក្សាគ្នាយ៉ាងទូលំទូលាយទៅលើបញ្ហាថា តើបុគ្គលនិងសហគមន៍ណាខ្លះដែលគួរតែត្រូវគេទទួលស្គាល់ថាជាជនរងគ្រោះ ។ ជនរងគ្រោះអាចត្រូវបានចាត់ថ្នាក់ដោយផ្អែកទៅលើភាពខុសគ្នាទូលាយបី ។ ភាពខុសគ្នាពីរក្នុងចំណោមភាពខុសគ្នាទាំងនេះ (ពោលគឺជនរងគ្រោះជាបុគ្គលឬជាសមូហភាព និង ដោយផ្ទាល់ឬប្រយោល) គឺជាចំណែកដ៏សំខាន់នៃការឲ្យនិយមន័យផ្សេងៗគ្នាទៅលើពាក្យថា ជនរងគ្រោះ ដែលចេញដោយអង្គការសហប្រជាជាតិ ។ ចំណុចខុសគ្នាទីបីរវាងជនរងគ្រោះជំនាន់ទី១ និងជំនាន់ទី២ គឺផ្អែកទៅលើទំហំនៃពេលវេលា ។ ប៉ុន្តែនៅក្នុងចំណោមភាពខុសប្លែកគ្នាទាំងបី ខ្ញុំសូមសង្កត់ធ្ងន់តែទៅលើផ្នែកសំខាន់ប៉ុណ្ណោះ គឺជាបុគ្គលឬសមូហភាព និង ដោយផ្ទាល់ឬប្រយោល ។

**ជនរងគ្រោះជាបុគ្គល និង ជាសមូហភាព**

រាល់ជម្លោះឃោរឃៅបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បុគ្គលទាំងបុរសទាំងស្ត្រី ប៉ុន្តែភាគច្រើនក៏បង្កឲ្យមានជនរងគ្រោះជាសមូហភាពដែរនៅក្នុងករណីមានអំពើប្រល័យពូជសាសន៍និងសង្គ្រាមស៊ីវិល ។ ជនរងគ្រោះជាសមូហភាពត្រូវបានបង្កើតឡើងនៅពេលដែលអំពើឃោរឃៅត្រូវគេសំដៅទៅលើប្រជាជនណាមួយ ឧទាហរណ៍ ក្រុមជាតិពន្ធុ ក្រុមប្រកាន់មនោគមវិជ្ជា ឬក្រុមសាសនា ។ នៅក្នុងករណីបែបនេះ បុគ្គលទាំងនោះបានក្លាយជាមុខសញ្ញាដោយសារតែការទាក់ទងជាមួយនឹងសមូហភាពដែលអាចកំណត់បាន ។ និយាយរួម ឥទ្ធិពលនេះតែងតែប៉ះពាល់ដល់សង្គមទូទៅ ។

**ជនរងគ្រោះផ្ទាល់ និង ជនរងគ្រោះប្រយោល**

ជនរងគ្រោះផ្ទាល់ គឺជាអ្នកដែលបានទទួលផលប៉ះពាល់នៃអំពើឃោរឃៅដោយផ្ទាល់ ។ ជនរងគ្រោះទាំងនោះត្រូវបាន

សម្លាប់ ឬរំលោភលើរូបរាងកាយឬផ្លូវចិត្ត យកទៅឃុំឃាំង រើសអើង ឬក៏សកម្មភាពផ្សេងៗទៀត ។ ចំណែកឯជនរងគ្រោះប្រយោលគឺជាជនទាំងឡាយណាដែលមានទំនាក់ទំនងជាមួយជនរងគ្រោះផ្ទាល់ នៅក្នុងន័យថា ខ្លួនឯងក៏ទទួលរងគ្រោះដែរតាមរយៈទំនាក់ទំនងដែលខ្លួនមានជាមួយជនរងគ្រោះផ្ទាល់ ។

យោងតាមសេចក្តីប្រកាសរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ជនរងគ្រោះប្រយោលគឺជាសមាជិកគ្រួសាររបស់ជនរងគ្រោះផ្ទាល់ ។ ជាញឹកញយ សាច់ញាតិតែងតែងទទួលនូវការលំបាកនិងឈឺចាប់យ៉ាងខ្លាំងដោយសារការឈឺចាប់របស់សមាជិកគ្រួសារ ឬក៏ត្រូវផ្តន្ទាទោសដោយសារការមានទំនាក់ទំនងជាមួយនឹងបុគ្គលនោះតាមរយៈកង្វះខាតខាងសេដ្ឋកិច្ចសង្គម ការនិរាសព្រាត់ប្រាស ការបាត់បង់អ្នករកស៊ីចិញ្ចឹមគ្រួសារ ខកខានឱកាសទទួលការអប់រំ បែកបាក់គ្រួសារ ការបំភិតបំភ័យដោយនគរបាល ឬទទួលរងការអាម៉ាស់មុខ ។

សេចក្តីប្រកាសក៏និយាយអំពីអ្នកដែលទទួលរងនូវផលប៉ះពាល់ដោយសារលទ្ធផលនៃការធ្វើអន្តរាគមន៍ជួយដល់ជនរងគ្រោះ ឬទប់ស្កាត់ការរំលោភបន្ថែមទៀត ។ អ្នកសង្កេតការណ៍មួយចំនួនឲ្យនិយមន័យកាន់តែទូលំទូលាយថែមទៀតចំពោះជនរងគ្រោះប្រយោល ដែលរួមបន្ថែមទាំងអ្នកជិតខាង មិត្តភក្តិនិងអ្នកដែលស្ថិតនៅជិតកន្លែងកើតហេតុរបស់ជនរងគ្រោះផ្ទាល់ ពោលគឺអ្នកដែលអាចត្រូវប៉ះទង្គិចផ្លូវអារម្មណ៍ដោយសារអ្វីដែលខ្លួនបានឃើញ ។ អ្នកផ្សេងទៀតថែមទាំងបានចោទជាសំណួរអំពីអត្ថប្រយោជន៍នៃការបែងចែករវាងជនរងគ្រោះផ្ទាល់និងជនរងគ្រោះប្រយោលតាមការជាក់ស្តែងៈ ការរកឃើញមួយរបស់គណៈកម្មការស្វែងរកការពិតនិងបង្រួបបង្រួមផ្សះផ្សារបស់អាហ្វ្រិកខាងត្បូងគឺថា វាជាការលំបាកក្នុងការបែងចែកឲ្យមានន័យរវាងការប៉ះពាល់ដល់រាងកាយនិងផ្លូវចិត្តដែលទទួលរងដោយជនរងគ្រោះផ្ទាល់ និងការឈឺចាប់របស់អ្នកដែលជាទីស្រលាញ់របស់ជនរងគ្រោះផ្ទាល់ ។ ការពង្រីកនិយមន័យជនរងគ្រោះក្នុងកម្រិតទូលំទូលាយបែបនេះគឺជាការសំខាន់ណាស់ ។ វាបានពង្រីកនូវទំហំនៃភាពជាជនរងគ្រោះ ហើយបង្កើននូវចំនួនមនុស្សដែលសុំឲ្យមានការទទួលស្គាល់និងការសងជំងឺចិត្តចំពោះការឈឺចាប់របស់ខ្លួន ។

**មតិផ្ទុយៈ ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ?**

ឆ្លើយទៅនឹងសំណួរថា *«តើបទល្មើសប្រព្រឹត្តឡើងដោយខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ជាអំពើប្រល័យពូជសាសន៍ឬ?»* លោក វីល្លៀម ស្កាបាស សាស្ត្រាចារ្យផ្នែកច្បាប់សិទ្ធិមនុស្សនៃសាកលវិទ្យាល័យជាតិអៀរឡង់ និងជានាយកមជ្ឈមណ្ឌលសិទ្ធិមនុស្ស បានអះអាងថា «ទាក់ទងនឹងទស្សនវិស័យនៃការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមមួយចំនួនដែលឃើញពន្លឺច្បាស់ហើយនោះ វាជាការសំខាន់ណាស់ក្នុងការសម្រេចថា តើវាសមស្របទៅតាមផ្លូវច្បាប់ដែរឬទេក្នុងការប្រើពាក្យ ប្រល័យពូជសាសន៍» ។ លោកក៏បាននិយាយបន្ថែមទៅលើនិយមន័យដែលចែងនៅក្នុងមាត្រា II នៃអនុសញ្ញាឆ្នាំ១៩៤៨ ស្តីអំពីការទប់ស្កាត់និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មុនពេលបញ្ចប់សេចក្តីថា «...អំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍ទេ» ។

ជារួម លោក ស្កាបាស បានទទួលស្គាល់ថា និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺបានមកពីមាត្រា VI នៃធម្មនុញ្ញតុលាការនូរិមប៊ឺកដែលចែងថា *«...ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលប្រព្រឹត្តមកលើជនស៊ីវិលមុនពេលឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយឬសាសនា»* ។ យោងតាមនិយមន័យនេះ លោកផ្តល់ជាយោបល់ថា *«ប្រសិនបើពាក្យថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រឹមត្រូវជាង ហេតុអ្វីក៏យើងមានចេតនាចង់ហៅអំពីឃោរឃៅទាំងនេះថាជាអំពើប្រល័យពូជសាសន៍ទៅវិញ»* ។ បន្ថែមពីលើនេះទៀត លោកបង្ហាញហេតុផលពីរ ។ ទីមួយ អំពើប្រល័យពូជសាសន៍មានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ លោកក៏និយាយទៀតថា *«ទោះបីជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិធ្វើឲ្យមានស្នាមទុយ៍សដ៏គួរឲ្យព្រឺព្រួចយ៉ាងណាក៏ដោយក៏ប៉ុន្តែ ការហៅថា វាជាអំពើប្រល័យពូជសាសន៍កាន់តែអាក្រក់*

ជាងនេះទៅទៀត» ។ ទីពីរ អត្ថិភាពនៃអនុសញ្ញាប្រល័យពូជសាសន៍ដែលកម្ពុជាជាភាគីមួយគ្រប់ពេលដែលពាក់ព័ន្ធនោះ បានដាក់ជាកាតព្វកិច្ចច្បាប់ជាអន្តរជាតិយ៉ាងច្បាស់លាស់ ។ ដោយហេតុផលនេះ លោកនិយាយថា និយាយយោងដល់ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅឆ្នាំ១៩៩៨ ទាក់ទងដល់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា «អំពើប្រល័យពូជសាសន៍មិនមានបញ្ហាពិបាកខាងផ្លូវច្បាប់ទេ» ។ មាត្រា I នៃអនុសញ្ញាប្រល័យពូជសាសន៍បញ្ជាក់ច្បាស់អំពីឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្ត «នៅពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាម» ។

និយាយដល់ភាពមិនច្បាស់លាស់របស់ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិដែលផ្ដើការស៊ើបអង្កេតទៅលើបញ្ហាវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម លោក ស្កាបាស ក៏បានសន្និដ្ឋានថា «សារសំខាន់នៃការប្រើពាក្យប្រល័យពូជសាសន៍ក្នុងការហៅអំពើឃោរឃៅនៅកម្ពុជា វាស្ថិតនៅត្រង់ក្រុមដែលជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍» ។ ទាក់ទងនឹងការបំផ្លិចបំផ្លាញគ្រឹះស្ថានវប្បធម៌ និងការឲ្យមករស់នៅលាយឡំគ្នាដោយបង្ខំ លោកបញ្ជាក់ដោយលើកជាបញ្ហាថា «...ទាំងនេះមិនមែនជាអំពើប្រល័យពូជសាសន៍ទេបើគិតអំពីវិសាលភាពនៃមាត្រា II នៃអនុសញ្ញានេះ» ។ លោក ស្កាបាស ទាញសេចក្ដីសន្និដ្ឋានចុងក្រោយថា វាជាមធ្យោបាយដ៏ល្អមួយ ប៉ុន្តែការកាត់ឲ្យជាប់ទោសពីបទប្រល័យពូជសាសន៍ (ដែលខុសទៅនឹងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) នឹងមានលទ្ធភាពកាន់តែតិច ។

ឆ្លើយតបទៅនឹងអត្ថបទរបស់លោកសាស្ត្រាចារ្យ វីល្លៀម ស្កាបាស ចេញផ្សាយនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ២២ ខែតុលា ឆ្នាំ២០០១ លោក គ្រីហ្គោរី ស្ដែនតុន ប្រធានអង្គការឃ្លាំមើលអំពើប្រល័យពូជសាសន៍នៃយុទ្ធនាការបញ្ឈប់អំពើប្រល័យពូជសាសន៍ និយាយថា «លោកសាស្ត្រាចារ្យ ស្កាបាស និយាយខុសដែលបាននិយាយថា ខ្មែរក្រហមមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដូចដែលបានចែងនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍ទេ ។ លោកក៏និយាយខុសនៅក្នុងចំណុចដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងនៅក្នុងច្បាប់អន្តរជាតិ ដោយរួមបញ្ចូលទាំងមនុស្សឃាតក្នុងទ្រង់ទ្រាយធំនៅក្នុងស្រុក» ។ មានហេតុផលមួយចំនួនដែលលោកបណ្ឌិតលើកមកជំទាស់ទៅនឹងមតិរបស់លោក ស្កាបាស ។ ទីមួយ លោក គ្រីហ្គោរី បានបង្ហាញឲ្យឃើញតាមរយៈលទ្ធផលនៃការស្ទាបស្ទង់មតិដែលខ្លួនលោកផ្ទាល់និង ប៉ែន ឃៀរនិន ដែលជាអ្នកជំនាញការអំពីបញ្ហា ប៉ុល ពត និងរបបឃោរឃៅនៅកម្ពុជា និងជានាយកកម្មវិធីសិក្សាអំពីការប្រល័យពូជសាសន៍នៅកម្ពុជា បានធ្វើនៅក្នុងភូមិចាមមួយចំនួននៅក្នុងប្រទេសកម្ពុជា ។ ការស្ទាបស្ទង់នេះបង្ហាញថា «អត្រាស្លាប់នៃជនជាតិចាមមានរហូតដល់ជាង ៥០ភាគរយ ពោលគឺមានទំហំពីរដងលើសការស្លាប់របស់ជនជាតិភាគច្រើនដទៃទៀតនៅក្នុងស្រុក» ។ បន្ថែមពីលើនេះទៀត ភ័ស្តុតាងជាខ្សែសង្វាក់នៃមនុស្សឃាតក្នុងទ្រង់ទ្រាយធំដែលមានសារសំខាន់សម្រាប់បង្ហាញអំពីចេតនាប្រល័យពូជសាសន៍និងជាភ័ស្តុតាងយ៉ាងមានទម្ងន់បញ្ជាក់ថា ការកម្ទេចជនជាតិចាមគឺជានយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្ត ក្នុងនោះមានបញ្ញត្តិមួយចែងថា «ត្រូវបំបែកចាមកុំឲ្យរស់នៅផ្តុំគ្នានៅក្នុងប្រទេសកម្ពុជា» ។

ទីពីរ គ្រីហ្គោរី បាននិយាយដល់អំណះអំណាងរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដូចខាងក្រោម÷

ដូចដែលលោក គ្រេក អិច ឆេសាន់ បានកត់សម្គាល់រួចមកហើយថា «ភ័ស្តុតាងដែលមានទម្ងន់ដែលថា ខ្មែរក្រហមក៏បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើជនជាតិវៀតណាមដែរ» និងការអះអាងរបស់ ស៊ីវ ដែលថាជនជាតិវៀតណាមទាំងអស់សុទ្ធតែជា «ជនបរទេស» គឺមិនមានអ្វីទាក់ទងក្រោមអនុសញ្ញាស្តីអំពីការប្រល័យពូជសាសន៍ទេ ។ ទោះបីជាជនជាតិវៀតណាមជាជនបរទេសយ៉ាងណាក៏ដោយ ប៉ុន្តែជនជាតិវៀតណាមទាំងនេះគឺជាក្រុមជាតិសាសន៍មួយ ហើយការបំផ្លាញក្រុមនេះនឹងក្លាយជាអំពើប្រល័យពូជសាសន៍ហើយ ។ បន្ថែមពីលើនេះទៀត ការអះអាងរបស់ ហានណាំ ដែលថាការកម្ទេចប្រជាជននៅភូមិភាគបូព៌ានៃប្រទេសកម្ពុជាក៏ជាអំពើប្រល័យពូជសាសន៍ដែរ ដោយសារការបំផ្លាញដោយផ្នែកនៃក្រុមជនជាតិ(កម្ពុជា) នោះប្រហែល

ជាពង្រីកដែនសមត្ថកិច្ចរបស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍កាន់តែធំ ពីព្រោះនេះជាការសម្លាប់ដែលធ្វើឡើងដោយជនជាតិខ្មែរនៅតំបន់មួយចំនួនមកលើជនជាតិខ្មែរនៅតំបន់មួយទៀត។ ការសម្លាប់ប្រជាជននៅភូមិភាគបូព៌ាជាទ្រង់ទ្រាយធំ គឺធ្វើឡើងដោយនយោបាយរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា»។

លោកបណ្ឌិត គ្រីហ្គោរី បញ្ជាក់ទៀតថា «ការសម្លាប់នេះត្រូវបានធ្វើឡើងជាប្រព័ន្ធ ហើយសមាជិកនៃក្រុមជនរងគ្រោះត្រូវខ្មែរក្រហមដាក់តម្រុយសម្គាល់ដោយឲ្យប្រើក្រមាក្រឡាចត្រង្គខៀវលាយស។ នេះជាតម្រុយដែល ប៉ែន យៀវនិន និងខ្ញុំ រកឃើញនៅឆ្នាំ១៩៨៦ នៅពេលដែលក្រុមជនរងគ្រោះទាំងនេះដើរកាត់ទីក្រុងភ្នំពេញក្នុងពេលជម្លៀសចេញពីភូមិភាគបូព៌ា»។ ខ្មែរក្រហមបានចាត់ទុកប្រជាជនភូមិភាគបូព៌ាថាជាជាតិពន្ធផ្សេងពីប្រជាជនកម្ពុជាដទៃទៀត ដោយហៅថា «ក្បាលយួនខ្លួនខ្មែរ»។ ការឲ្យនិយមន័យរបស់ជនដៃដល់ទៅលើពាក្យជាតិពន្ធ ឬជាតិសាសន៍ គឺជាលក្ខណៈពិសេសនៃអំពើប្រល័យពូជសាសន៍។

នៅចុងបញ្ចប់ លោកបណ្ឌិត គ្រីហ្គោរី ផ្តល់យោបល់ថា «លោក ស្តាបាស ចាំបាច់ត្រូវតែពិនិត្យអង្គហេតុរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តទាំងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការវិវត្តន៍ថ្មីៗនៃច្បាប់ចាប់តាំងពីមានតុលាការនៅនូរិមប៊ឺកមក។ លោកក៏គួរតែទទួលស្គាល់ថាអំពើប្រល័យពូជសាសន៍និងការបោសសម្អាតជាតិពន្ធមិនមែនខុសគ្នាទេ ហើយអំពើទាំងនេះត្រូវបានប្រព្រឹត្តរួចហើយនៅក្នុងប្រទេសកម្ពុជានិងប្រទេសកូសូវ៉ូ»។

ខ្ញុំយល់ស្របជាមួយលោកបណ្ឌិត គ្រីហ្គោរី ដែលថាបទល្មើសប្រព្រឹត្តឡើងដោយខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ គឺជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ មានហេតុផលជាច្រើនដែលធ្វើឲ្យខ្ញុំយល់ស្របជាមួយគាត់។ ទីមួយ នៅក្នុងប្រទេសកម្ពុជាក្រុមមនុស្សដែលត្រូវបានមេដឹកនាំខ្មែរក្រហមចាត់ទុកថាគ្មានកន្លែងនៅក្នុងរបៀបរបបបដិវត្តសង្គមត្រូវបានហាមឃាត់ រំលាយតាមលក្ខណៈសង្គមសាស្ត្រ ហើយក្នុងករណីចាំបាច់ កម្ទេចចោលតែម្តង។ ក្រុមមនុស្សត្រូវបានហាមឃាត់ ឬមិនទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។ ខ្មែរក្រហមប្រើពាក្យរំលាយតាមសង្គមសាស្ត្រថាខ្ចាត់ខ្ចាយអស់រលីង។ តាមការពិតក្រុមមនុស្សទាំងអស់មិនអាចចេះតែត្រូវគេយកមកធ្វើជាច្បាប់ឬកំណត់ចេញពីអត្តិភាព និងការហាមឃាត់តាមផ្លូវច្បាប់ និងការកម្ចាត់កម្ចាយត្រូវរង់ចាំដោយការកម្ចាត់ឲ្យអស់រលីងនោះទេ។

ទីពីរអ្នកដឹកនាំរបស់ក្រុមដែលត្រូវបំបាត់ត្រូវសម្លាប់ចោលទៅតាមក្រុមដែលមិនព្រមរំលាយខ្លួន។ មានមនុស្សច្រើននាក់ទៀតស្លាប់ដោយសារលក្ខខណ្ឌរស់នៅពិបាកពេក ដូចជាកង្វះ



អាហារ (របបអាហារត្រូវកាត់បន្ថយដោយរដ្ឋ) និងការលួច ព្រមទាំងជំងឺដែលគ្មានការព្យាបាល ដែលជាផលវិបាកនៃការរំលាយប្រព័ន្ធសុខាភិបាលដែលមានពីមុនមក និងការយកទៅសម្លាប់ចោលនូវបុគ្គលិកសុខាភិបាលមានការហ្វឹកហ្វឺនត្រឹមត្រូវ ដោយសារតែបុគ្គលិកទាំងនេះមានកម្រិតអប់រំឬហ្វឹកហ្វឺននៅក្រៅប្រទេស ។

ទីបី ក្រុមដែលជាមុខសញ្ញានៃការបោសសម្អាតដោយមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា រួមមានក្រុមសាសនាធំៗរបស់កម្ពុជា ព្រះសង្ឃ ក្រុមជនជាតិភាគតិច និងមួយភាគធំនៃ «ក្រុមជនជាតិភាគច្រើន» ដែលត្រូវបានធ្វើឲ្យខូចដោយឥទ្ធិពល «សក្តិភូមិ» «គហបតី» ឬ «បរទេស» ។

ដូចដែលចែងនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍ អំពើប្រល័យពូជសាសន៍គឺជាការបំផ្លិចបំផ្លាញជាលក្ខណៈអន្តរជាតិ ទាំងស្រុងឬដោយផ្នែក ទៅលើជនជាតិ ជាតិពន្ធុ ជាតិសាសន៍ ឬក្រុមសាសនាតាមរយៈការសម្លាប់ ។ ការធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់រូបរាងកាយឬខាងសតិស្មារតី លក្ខខណ្ឌរស់នៅ ការរារាំងមិនឲ្យមានកំណើតទារកនៅក្នុងក្រុម ឬផ្ទេរកុមារដោយបង្ខំចេញពីក្រុមមួយទៅក្រុមមួយ ។

### តួនាទីរបស់ជនរងគ្រោះនៅក្នុងការផ្សះផ្សាជាតិ

ជនរងគ្រោះគឺជាស្នូលដ៏សំខាន់នៃដំណើរការបង្រួបបង្រួមផ្សះផ្សានៅក្នុងសង្គមទាំងឡាយដែលងើបរួចផុតពីជម្លោះអស់ជាច្រើនឆ្នាំ ។ វាមានសារសំខាន់ណាស់ដែលអ្នកតាក់តែងនយោបាយនិងថ្នាក់ដឹកនាំសង្គមស៊ីវិលត្រូវយល់ដឹងអំពីមុខងារជាច្រើនរបស់ជនរងគ្រោះ ។ ការយល់ដឹងនេះត្រូវតែនាំផ្លូវស្វែងរកកម្មវិធីសម្រាប់ជនរងគ្រោះឲ្យបានគ្រប់គ្រាន់ ទោះបីជាមធ្យោបាយមិនមានគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាសម្រាប់ជនរងគ្រោះគ្រប់ៗរូបដែលទទួលរងការឈឺចាប់ជាបុគ្គលឬជាសមូហភាព ផ្ទាល់ឬប្រយោល ថ្ងៃនេះឬថ្ងៃអនាគតក៏ដោយ ។ ក្នុងលក្ខខណ្ឌចាំបាច់ជាទូទៅ មានតែសិទ្ធិជាសារវន្តមួយផ្នែករបស់អ្នកដែលត្រូវរំលោភ ដែលនឹងត្រូវទទួលយកថាជាជនរងគ្រោះ«ពិតប្រាកដ» ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ជនរងគ្រោះទាំងនេះអាចបំពេញតួនាទីដោយភាពវិជ្ជមាន ដោយតំណាងឲ្យជនរងគ្រោះច្រើនផ្សេងទៀតនៅក្នុងដំណើរការបង្រួបបង្រួមផ្សះផ្សាជាផ្លូវការ ។

នៅក្នុងប្រព័ន្ធច្បាប់ទំនើប បណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះជាគោលការណ៍ គឺសំដៅប្តឹងទាមទារសំណងការខូចខាតបណ្តាលមកពីការរំលោភបំពាន ។ ក៏ប៉ុន្តែផលប្រយោជន៍នៃការរសាយចិត្តតាមរយៈសំណងរដ្ឋប្បវេណីគឺឃើញមាននៅប្រទេសបារាំង អ៊ីស្រាអែល អាហ្វ្រិកខាងត្បូង និង អេត្យូពី ។ ដូចនេះការចូលរួមដោយផ្ទាល់ពីសំណាក់ប្រជាជននៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម គួរតែជួយជនរងគ្រោះជាច្រើនក្នុងការដោះស្រាយជាមួយអតីតកាលរបស់ខ្លួន ហើយចូលរួមចំណែកនៅក្នុងដំណើរការបង្រួបបង្រួមផ្សះផ្សាជាតិ ។ បើគ្មានការបង្រួបបង្រួមផ្សះផ្សាជាតិទេ ស្ថិរភាពនៅកម្ពុជានាពេលអនាគតក៏នៅតែជាបញ្ហាដដែល ។ និយាយឲ្យកាន់តែជាក់ស្តែងជាងនេះគឺថា បណ្តឹងរបស់ភាគីបណ្តឹងរដ្ឋប្បវេណីក៏មានឥទ្ធិពលទៅលើដំណើរជំនុំជម្រះក្តីតាមបែបព្រហ្មទណ្ឌដែរ ។

នៅក្នុងករណីណាក៏ដោយ រដ្ឋាភិបាលកម្ពុជាកំពុងតែមានផែនការរៀបចំយន្តការតុលាការសម្រាប់ជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ។ ជាគោលការណ៍ សេចក្តីសម្រេចក្នុងការចោទប្រកាន់គឺជាអំណាចរបស់ព្រះរាជអាជ្ញាពិសេស ប្រហែលរួមមានព្រះរាជអាជ្ញាមិនមែនជាជនជាតិខ្មែរម្នាក់ផង ។ ដូចនេះមិនទំនងថារាជរដ្ឋាភិបាលកម្ពុជាធ្វើឲ្យចន្លោះប្រហោងនូវតួនាទីណាមួយរបស់ជនរងគ្រោះឡើយនៅក្នុងបរិបទនេះ ។

ផលប្រយោជន៍មួយដ៏សំខាន់ក្នុងចំណោមផលប្រយោជន៍សំខាន់ផ្សេងៗទៀតនៃនីតិវិធីនេះ គឺថាវាផ្តល់នូវមធ្យោបាយដោយផ្ទាល់សម្រាប់ជនរងគ្រោះ ក្នុងការបំពេញព័ត៌មានទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ ឬបង្ហាញនូវភ័ស្តុតាងនៅក្នុងពេលបើកសវនាការ ។ ប្រការនេះមានប្រយោជន៍មិនតិចទេនៅក្នុងករណីប្រទេសកម្ពុជា ដែលមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានធ្វើការងារជាច្រើនឆ្នាំមកហើយ ក្នុងគោលបំណងស្វែងរកការពិតក្នុងរបបខ្មែរក្រហម (ដូចជាកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍) ។ មាត្រា២៧នៃបទបញ្ញត្តិរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក៏ចែងដែរថា «ស្នាក្តី

របស់ភាគីធ្វើអន្តរាគមន៍ត្រូវតែមានសិទ្ធិប្រើឯកសារដូចជាស្នាក្តីរបស់ជនជាប់ចោទដែរ» ដែលប្រការនេះក្លាយជាការធានាបន្ថែមទៅលើដំណើរការវិនិច្ឆ័យទោសនៅក្នុងតុលាការ ។

ការបញ្ចូលនូវបទបញ្ញត្តិនេះនៅក្នុងច្បាប់ថ្មីដែលកំពុងព្រាងដោយរាជរដ្ឋាភិបាលកម្ពុជា គឺពិតជាចូលរួមដល់ដំណើរការនេះ ឬការបង្រួបបង្រួមផ្សះផ្សាជាតិដោយធ្វើឲ្យប្រជាជនកម្ពុជាចូលរួមនៅក្នុងដំណើរការជម្រះក្តីរបស់ខ្លួនឯងផ្ទាល់ ។ ទន្ទឹមពេលនេះដែរ វាអាចជាភ័ស្តុតាងដ៏មានទម្ងន់ បញ្ជាក់អំពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់នូវការធានាឲ្យការជំនុំជម្រះក្តីប្រកបដោយសេរីភាព និងមិនលម្អៀង ដោយមិនបាច់ធ្វើសម្បទានបន្ថែមទៀតដល់អង្គការសហប្រជាជាតិទាក់ទងនឹងការពិនិត្យពិច័យពីខាងក្រៅមកលើដំណើរការជំនុំជម្រះក្តីនេះទេ ។

ប្រជាជនភាគច្រើនប្រាថ្នាចង់ចាកផុតពីការឈឺចាប់ និងត្រឡប់ទៅរកជីវិតគ្រួសារដូចពីមុន ដែលបានអាក់ខានដោយសារធ្លាប់មានឋានៈជាជនភៀសខ្លួន និងរងសម្ពាធនយោបាយជម្លៀសដោយបង្ខំ ។ ចំពោះអ្នកទាំងនេះយល់ថា ការបង្រួបបង្រួមផ្សះផ្សាពិតប្រាកដនឹងរកបាននៅពេលសេចក្តីទុកចិត្តគ្នាវិលត្រឡប់មករកបុគ្គលដែលធ្លាប់មានបញ្ហាជាមួយគ្នា មានន័យថា នៅពេលដែល«គេអាចញញឹមបាន និងទុកចិត្តគ្នាទៅវិញទៅមក» ។

ដូចនេះ ចម្លើយស្ថិតនៅលើការស្វែងរកយន្តការសម្រាប់ដោះស្រាយបញ្ហាទាំងនេះជាលក្ខណៈបុគ្គល និងតាមរបៀបដែលសមស្របទៅតាមមូលដ្ឋានគ្រឹះនៃវប្បធម៌របស់ខ្មែរ ។ ផ្លូវដ៏សំខាន់មួយសម្រាប់ស្វែងរកការបង្រួបបង្រួមផ្សះផ្សានេះគឺតាមរយៈសាសនារបស់ជាតិ (ព្រះពុទ្ធសាសនា) ដែលយ៉ាងហោចណាស់មានប្រជាជនកម្ពុជា៩០ភាគរយជឿលើព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនានេះទៀតសោតមានឥទ្ធិពលមកលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ។ ព្រះពុទ្ធសាសនាមានសារសំខាន់ ពោលគឺ មេត្តាធម៌ និង ការបង្រួបបង្រួមផ្សះផ្សា ។

ក្នុងការដោះស្រាយជាមួយនឹងស្នាមទុយ៌សខាងផ្លូវអារម្មណ៍ដែលបន្សល់ទុកដោយសង្គ្រាមជាច្រើនឆ្នាំ ប្រជាជនកម្ពុជាបានងាកមកជឿលទ្ធិសាសនាមួយដែលបានទទួលរងការវាយប្រហារយ៉ាងឃោរឃៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកបស្ចិមប្រទេសជាច្រើនចាត់ទុកព្រះពុទ្ធសាសនាថា ជាលទ្ធិមួយដែលអាចទទួលយកបាន ដែលរារាំងយ៉ាងមានប្រសិទ្ធភាពមិនឲ្យមានការផ្លាស់ប្តូរសង្គម ។

ប្រសិនបើព្រះពុទ្ធសាសនាជាឧបករណ៍ដ៏មានសារសំខាន់នៅក្នុងដំណើរការបង្រួបបង្រួមផ្សះផ្សាជាតិ យើងត្រូវតែធានាថា ព្រះពុទ្ធសាសនាមិនអាចក្លាយទៅជាលក្ខណៈនយោបាយដូចជាចំណុចខ្លះនៅក្នុងដំណើរការបង្រួបបង្រួមផ្សះផ្សានោះទេ ។ សម្តេចព្រះ នរោត្តម សីហនុ មានព្រះរាជតម្រិះស្នើបូជាអដ្ឋិធាតុជនរងគ្រោះដើម្បីកុំឲ្យព្រលឹងជនរងគ្រោះនៅវិលវល់ ប៉ុន្តែសម្តេច ហ៊ុន សែន ជឿថា ចាំបាច់ត្រូវតែថែរក្សាអដ្ឋិធាតុទុកជាកេរដំណែលប្រវត្តិសាស្ត្រ ។ នៅពេលដែលទស្សនៈរបស់សម្តេច ហ៊ុន សែន ប្រហែលជាមានលក្ខណៈជាក់ស្តែងជាងអ្នកទាំងពីរអះអាងថា ខ្លួនសុទ្ធតែជឿលើសាសនា ហើយប្រើសាសនាដើម្បីជាហេតុផលឲ្យសមទៅនឹងជំហរប្រឆាំងរបស់ខ្លួន ។ ដើម្បីជៀសវាងនយោបាយភាវូបនីយកម្មលើសាសនា ព្រះភិក្ខុខេមចារោ យស់ ហ៊ុត គាំទ្រ«ផ្លូវកណ្តាល» ដែលប្រើសម្រាប់ប្រៀបធៀបនៅក្នុងលទ្ធិព្រះពុទ្ធសាសនា ដែលផ្លូវនេះជៀសវាងមិនប្រយុទ្ធគ្នា ហើយក៏មិនរត់គេចដែរ ។ ផ្លូវកណ្តាលដែលជ្រើសរើសយកអហិង្សានិងមេត្តាធម៌ គឺជាគំរូមួយសម្រាប់ដោះស្រាយបញ្ហានយោបាយដោយមិនប្រើភាពប្រទូសរ៉ាយប្រកាន់បក្សពួក ។ ដោយសារគំនិតទាំងនេះកើតចេញពីទស្សនៈរបស់ខ្មែរ គំនិតនេះអាចជួយឲ្យប្រជាជនកម្ពុជាស្វែងរកសន្តិភាពដោយខ្លួនឯង ជាជាងមានអារម្មណ៍ថាបញ្ហារបស់ខ្លួនឯងមានតែអ្នកក្រៅទេដែលអាចដោះស្រាយបាន ។

## ***សេចក្តីសន្និដ្ឋាន***

ជម្រើសតួនាទីនេះគឺជាចំណុចដ៏សំខាន់មួយក្នុងការរៀបចំនិងប្រព្រឹត្តទៅនៃកម្មវិធីបង្រួបបង្រួមផ្សះផ្សា ។ ជាការច្បាស់ណាស់ថា គ្មានការរួបរួមគ្នាឬយោគយល់គ្នាណាកើតមានឡើងឡើយ ប្រសិនបើអំពើឃោរឃៅឥតដាច់មិនត្រូវបានទទួលស្គាល់

និងគ្មានការសារភាពទទួលកំហុស ។ មានមនុស្សច្រើនណាស់ដែលនឹងបដិសេធមិនព្រមទទួលខុសត្រូវ ។

ប្រការនេះក៏នឹងធ្វើឲ្យជនដៃដល់ដោះសាបានដោយងាយស្រួល ។ ក៏ប៉ុន្តែទស្សនៈរបស់អ្នកដែលនៅរស់រានមានជីវិតអាចមានសារសំខាន់នៅក្នុងកាលៈទេសៈដែលផ្លាស់ប្តូរ ហើយបរិយាកាសផ្លាស់ប្តូរនេះជួយឲ្យជនរងគ្រោះនិងអ្នកប្រព្រឹត្តបទល្មើសបង្កើតនូវសកម្មភាពសហប្រតិបត្តិការមួយចំនួនឆ្ពោះទៅរកការបង្រួបបង្រួមផ្សះផ្សា ។

ការទទួលស្គាល់ជនរងគ្រោះគឺជាបញ្ហាសំខាន់ក្នុងការស្វែងរកការបង្រួបបង្រួមផ្សះផ្សា ។ ខាងក្រោមនេះគឺជាបថមវិធានមួយចំនួនសម្រាប់ការពិចារណា ដែលអាចជួយឲ្យភ្នាក់ងារក្នុងស្រុកនិងអន្តរជាតិដោះស្រាយបញ្ហានេះបានគ្រប់គ្រាន់÷

◆ យល់ដឹងអំពីផលវិបាកជាច្រើនទាក់ទងដល់ការជ្រើសរើសនិយមន័យនៃពាក្យ "ជនរងគ្រោះ" តាមន័យនយោបាយនិងន័យច្បាប់ ។

◆ គោរពការយល់ឃើញរបស់ជនរងគ្រោះផ្ទាល់នូវអ្វីដែលបានកើតឡើងចំពោះរូបគាត់ ។ នៅក្នុងករណីខ្លះ ប្រការនេះមានន័យថាចាត់ទុកគាត់មិនមែនជាជនរងគ្រោះ ប៉ុន្តែជាអ្នករស់រានមានជីវិត ។ នៅទន្ទឹមពេលគ្នានេះ អ្នកតាក់តែងនយោបាយត្រូវតែទទួលស្គាល់ថា ការយល់ឃើញទាំងនេះងាយបត់បែននិងផ្លាស់ប្តូរទៅតាមពេលវេលា ។ ដំណើរប៉ះទង្គិចផ្លូវអារម្មណ៍គឺជាមេរោគដែលវិវត្តយឺតៗ ។

◆ ទទួលស្គាល់ថាដំណើរជាសះស្បើយរបស់ជនរងគ្រោះត្រូវឆ្លងកាត់ជាច្រើនដំណាក់កាល ។

◆ ចាត់វិធានការដោះស្រាយបញ្ហាថែទាំសុខភាព អប់រំ និងឲ្យលំនៅជ្រកកោន ដែលជាការជួយដល់សហគមន៍ទាំងមូល និងបញ្ចូលអ្នកដែលមិនទទួលការប៉ះប៉ូវពីកម្មវិធីទាំងនេះ ។

◆ ស្តាប់តម្រូវការចាំបាច់របស់ជនរងគ្រោះដែលនៅតែជាជនរងគ្រោះរស់ក្នុងប្រទេសជិតខាង ។

ខ្ញុំសង្ឃឹមថា បញ្ហាសំខាន់ៗអាចដោះស្រាយបាន ហើយដំណើរការនេះនឹងមានសន្ទុះឡើងវិញ ។ តុលាការមានសារសំខាន់ណាស់ ដោយសារតុលាការនឹងលាតត្រដាងនូវការពិតអប់រំប្រជាជន អំពីអតីតកាល ផ្តល់នូវយុត្តិធម៌សម្រាប់ជនរងគ្រោះ និងធ្វើឲ្យប្រសើរឡើង ព្រមទាំងនាំមកវិញនូវធម្មាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ហើយក៏ត្រូវផ្តល់តួនាទីសម្រាប់ប្រជាជនធម្មតាឲ្យចូលរួមសម្រេចឲ្យបាននូវការបង្រួបបង្រួមផ្សះផ្សារាល់ៗថ្ងៃ ចំពោះអ្នកដែលនៅតែមានការប៉ះទង្គិចផ្លូវអារម្មណ៍ធ្ងន់ធ្ងរនៅឡើយ ។ វេទិកានោះគឺជាជំហានមួយដូចជាកម្មវិធីតាមមូលដ្ឋានដែលរៀបរាប់ខាងលើនេះ ។ ជាពិសេសទៅទៀត ជំហានទាំងនេះគួរតែធ្វើឲ្យស្របទៅតាមផ្លូវកណ្តាល ដោយមានការពិគ្រោះយ៉ាងពេញលេញជាមួយប្រជាជនកម្ពុជាផ្ទាល់ ។

**ខ្វូន សុភារិទ្ធិ**





# សុន្ទរកថារបស់ប្រទេសហុល្លង់អំពីតុលាការខ្មែរក្រហម នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ

**ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៣**

លោកប្រធានជាទីគោរព

យើងមិនបានប្រឆាំងនឹងការអនុម័តសេចក្តីសម្រេចទេ ប៉ុន្តែយើងពិតជាចង់បញ្ជាក់នូវកង្វល់មួយចំនួនទាក់ទិនទៅនឹងមាគ៌ាដែលនឹងត្រូវដើរ ។ យើងមានបំណងឲ្យមានការចរចាបន្តទៀតរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឲ្យបានថា បទដ្ឋានយុត្តិធម៌អន្តរជាតិត្រូវបានបំពេញ ។

យើងខ្ញុំគាំទ្រកិច្ចប្រឹងប្រែងរបស់ក្រុមចរចារបស់អង្គការសហប្រជាជាតិ ដើម្បីកែប្រែឲ្យប្រសើរឡើងនូវចំណុចទាំងឡាយនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដូចដែលអាចធ្វើទៅបាន ។ យើងខ្ញុំសូមគាំទ្ររបាយការណ៍ដ៏មានតុល្យភាព ធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អង្គការសហប្រជាជាតិបានបំពេញការងារដ៏ជោគជ័យ បើយើងពិចារណាទៅលើកាលៈទេសៈនិងអាណត្តិដ៏ពិបាកដែលបានបង្កើតនៅក្នុងសេចក្តីសម្រេច ៥៧/២២៨ ។

អត្ថបទនេះជាការរីកចម្រើនពីអត្ថបទមុនដែលបានយកទៅពិភាក្សានៅក្នុងការចរចាមុនៗ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងនៅតែមានចម្ងល់ដូចលោកអគ្គលេខាធិការដែរថា តើកិច្ចព្រមព្រៀងអាចធានាឲ្យអង្គជំនុំជម្រះវិសាមញ្ញគោរពតាមបទដ្ឋានយុត្តិធម៌អន្តរជាតិឬក៏អត់ ។ បទដ្ឋានយុត្តិធម៌អន្តរជាតិគួរតែជាលក្ខខណ្ឌដំបូងបង្អស់សម្រាប់រាល់ជំនួយការរបស់អង្គការសហប្រជាជាតិ ។

កង្វល់ដែលនៅតែលេចឡើងគឺមានទំហំធំធេងដែរ ហើយមានចាប់ពីកត្តាឯករាជ្យភាពតុលាការនិងព្រះរាជអាជ្ញា ច្បាប់ពាក់ព័ន្ធដំណើរការសម្រេចចិត្ត រហូតដល់ការការពារសាក្សី ។ យើងក៏កត់សម្គាល់ទៅលើការខ្វាយខ្វល់ដែលបញ្ជាក់ឡើងដោយទីប្រឹក្សាច្បាប់នៅថ្ងៃទី១ ខែឧសភា អំពីកង្វះចន្លោះនៃមតិភាគច្រើនសម្រាប់ចៅក្រមអន្តរជាតិ និងកង្វះខាតនូវភាពច្បាស់លាស់អំពីតួនាទីរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីផ្នែករដ្ឋបាលរបស់តុលាការ ។

រដ្ឋាភិបាលរបស់ប្រទេសហុល្លង់បានយល់ស្របទៅលើសំណើរបស់លោកអគ្គលេខាធិការ អំពីរចនាសម្ព័ន្ធ ការគ្រប់គ្រងនិងសមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចដែលបានចែងនៅក្នុងកថាខ័ណ្ឌទី១៦នៃរបាយការណ៍របស់លោក ។ គួរឲ្យសោកស្តាយខ្លាំងណាស់ សំណើទាំងនេះត្រូវបានបដិសេធ ។ យើងខ្ញុំក៏សោកស្តាយដែរថាសំណើដើម្បីពង្រឹងធាតុអន្តរជាតិនៅក្នុងដំណាក់កាលស៊ើបអង្កេតនិងការកាត់ទោស (កថាខ័ណ្ឌ ២២) មិនអាចទទួលយកបាន ។

ប្រទេសហុល្លង់បានសម្រេចចិត្តបោះឆ្នោតអនុបវាទនៅក្នុងការបោះឆ្នោតអនុម័តសេចក្តីសម្រេច ៥៧/២២៨ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ដែលបានស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិវិលត្រឡប់ទៅកាន់តុចរចាជាមួយរដ្ឋាភិបាលប្រទេសកម្ពុជា ។ ក្នុងពេលនោះ យើងខ្ញុំយល់ថាសេចក្តីព្រាង ៥៧/២២៨ មិនអាចធានាឲ្យបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិនិងភាពត្រឹមត្រូវតាមច្បាប់ទេ ។

នៅទីបញ្ចប់ ខ្ញុំសូមដកស្រង់របាយការណ៍របស់អគ្គលេខាធិការ ត្រង់កថាខ័ណ្ឌទី៥១ ពាក់ព័ន្ធទៅនឹងមាត្រាទី២៨នៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ។

“...បើរដ្ឋាភិបាលកម្ពុជាផ្លាស់ប្តូររចនាសម្ព័ន្ធនិងការគ្រប់គ្រងនៃអង្គជំនុំជម្រះវិសាមញ្ញនៅពេលក្រោយ ដែលនាំឲ្យរដ្ឋាភិបាលកម្ពុជាពុំអាចបំពេញតាមកិច្ចព្រមព្រៀងនោះ កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិក្នុងការផ្តល់ជំនួយការក្រោមកិច្ចព្រមព្រៀងនឹងត្រូវបញ្ចប់” ។

តាមរយៈហេតុផលនេះ ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែត្រួតពិនិត្យយ៉ាងពេញទំហឹងដោយសហគមន៍អន្តរជាតិ ។

សូមអរគុណ ។

# សុន្ទរកថារបស់ប្រទេសស៊ុយអែដអំពីកិច្ចព្រមព្រៀងតុលាការខ្មែរក្រហមក្នុងតួនាទីជាប្រទេសនៅអឺរ៉ុបខាងជើង នៅក្នុងគណៈកម្មាធិការទីបីរបស់មហាសន្និបាតអង្គការសហប្រជាជាតិ



ខ្ញុំសូមថ្លែងក្នុងនាមជាប្រទេសនៅអឺរ៉ុបខាងជើង ប្រទេសដាណឺម៉ាក ហ្វាំងឡង់ អាយឡែន ន័រវេស និងប្រទេសរបស់ខ្ញុំគឺស៊ុយអែដ ។

*លោកប្រធានជាទីគោរព*

ប្រទេសនៅអឺរ៉ុបខាងជើងសប្បាយចិត្តណាស់ដែលនៅទីបំផុតកិច្ចព្រមព្រៀងមួយត្រូវបានបង្កើតឡើងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលប្រទេសកម្ពុជា ទៅលើការរៀបចំតុលាការខ្មែរក្រហមដើម្បីកាត់ទោសជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតទៅលើអំពើឃោរឃៅក្នុងរបបខ្មែរក្រហម ។

*ទោះជាយ៉ាងណាក៏ដោយ*

យើងនៅតែជឿជាក់ថា ការផ្តល់ជំនួយហិរញ្ញវត្ថុតាមរយៈការចូលវិភាគទានដែលបានប៉ាន់ស្មានទុក នឹងអាចជាជំនួយដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះយ៉ាងឆាប់រហ័ស ។ នៅក្នុងរបាយការណ៍ (ក/៥៧/៧៦៩) លោកអគ្គលេខាធិការក៏បានកត់សម្គាល់អំពីចំណុចនេះដែរ ហើយបានលើកឡើងអំពីបញ្ហាដែលកើតមានឡើងក្នុងការចូលវិភាគទានដោយស្ម័គ្រចិត្តនៅក្នុងករណីតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ។ ដោយសារតែឡូវនេះ វិធីសាស្ត្ររួមវិភាគទានដោយស្ម័គ្រចិត្តត្រូវបានជ្រើសរើស យើងសូមអំពាវនាវឲ្យរដ្ឋជាសមាជិកទាំងអស់ចូលវិភាគទានដោយមិនពន្យារពេល ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមអនុវត្តការងារយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

*លោកប្រធានជាទីគោរព*

ប្រទេសនៅអឺរ៉ុបខាងជើងមានបំណងថ្លែងបញ្ជាក់ថា ទោះជាឥឡូវនេះអង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិក៏ដោយ ក៏ការកាត់ទោសត្រូវតែប្រព្រឹត្តឡើងដោយមិនលម្អៀងមានប្រសិទ្ធភាពនិងឯករាជ្យ ហើយគោរពទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ និងត្រឹមត្រូវតាមច្បាប់ ។ ដើម្បីបំពេញនូវចំណុចខាងលើនេះ កិច្ចព្រមព្រៀងត្រូវតែយកទៅអនុវត្តឲ្យបានពេញលេញ ។ ក្នុងករណីនេះ យើងក៏សូមលើកឡើងអំពីបទបញ្ញត្តិដែលមានចែងអំពីការដកថយរបស់អង្គការសហប្រជាជាតិ ក្នុងករណីកិច្ចព្រមព្រៀងមិនត្រូវបានអនុវត្តនិងគោរពតាម ។

*នៅទីបញ្ចប់ និង ក្នុងមូលហេតុនេះ*

យើងសូមបញ្ជាក់អំពីសារប្រយោជន៍នៃការផ្តល់ជារបាយការណ៍ដោយលោកអគ្គលេខាធិការទៅមហាសន្និបាតអំពីការអនុវត្តសេចក្តីសម្រេចដូចដែលបានចែងនៅក្នុងកថាខ័ណ្ឌដំណើរការទី៤ ។ របាយការណ៍នេះគួរតែត្រូវធ្វើឡើងឲ្យបានជាប់ជានិច្ច ហើយមិនត្រឹមតែបកស្រាយអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះទេ ត្រូវនិយាយអំពីបញ្ហាទាំងឡាយដែលជួបប្រទះដោយអង្គការសហប្រជាជាតិទាក់ទងទៅនឹងមាត្រាទី២៨នៃកិច្ចព្រមព្រៀងអំពីការបញ្ឈប់កិច្ចសហប្រតិបត្តិការដែរ ។ សូមអរគុណ ។

**(តមកពីទំព័រ៣៨)**

ជាច្រើនដូចជា ការមិនធានាគ្រប់គ្រាន់នូវការជំនុំជម្រះក្តីដែលមានគំរូបទដ្ឋានអន្តរជាតិ ការមិនធានាគ្រប់គ្រាន់ឲ្យមានតុលាការមួយឯករាជ្យ និងមិនលម្អៀង ការខកខានមិនបានបញ្ចូលនូវគោលការណ៍ដ៏មានទម្ងន់បំផុតនៃទទួលខុសត្រូវពីបទព្រហ្មទណ្ឌ និងច្បាប់ស្តីអំពីការការពារខ្លួន ការការពារជនរងគ្រោះនិងសាក្សីមិនគ្រប់គ្រាន់ ការមិនមានចែងបទបញ្ញត្តិអំពីសំណងខូចខាត និងការខកខានមិនបានភ្ជាប់នីតិវិធីតុលាការដែលស្នើឡើងទៅនឹងការកសាងឡើងវិញនូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ។

ហេតុផលពីរយ៉ាងដែលអង្គការលើកលែងទោសអន្តរជាតិទទូចចង់ឲ្យនាំខ្លួមេដឹកនាំខ្មែរក្រហមមកកាត់ទោសចំពោះមុខច្បាប់គឺទីមួយ ដើម្បីយ៉ាងហោចណាស់ធានាឲ្យបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះ និងគ្រួសាររបស់ខ្លួនដែលទទួលរងការឈឺចាប់ដោយសារបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរបំផុតក្រោមរបបខ្មែរក្រហម ហើយទីពីរគឺដើម្បីបញ្ចប់វប្បធម៌និទណ្ឌភាពដែលបានយាយីប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃ ។

# ជប៉ុនៈ ការសញ្ជឹងគិតរបស់ខ្ញុំទៅលើបញ្ហាខ្មែរក្រហម



កិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិៈ ព្រឹត្តិការណ៍ជុំវិញនៅថ្ងៃទី ១ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការទីបី នៃមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីសម្រេចយល់ព្រមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីទៅតាមច្បាប់កម្ពុជា ទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រទេសកម្ពុជា ជប៉ុន បារាំង និងប្រទេសមួយចំនួនទៀតបានសហការរ៉ាប់រងនូវសេចក្តីសម្រេចនេះ ។ ប្រការនេះមានន័យថា ដំណើរការចរចាដ៏វែងឆ្ងាយនិងពិបាករកបាននេះបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៩មកម្ល៉េះ រវាងកម្ពុជានិងអង្គការសហប្រជាជាតិ មកដល់ឥឡូវនេះជិតចប់ចុងចប់ដើមហើយ ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាចាត់វិធានការចាំបាច់នានាដើម្បីកែតម្រូវច្បាប់ខ្មែរក្រហមនិងផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ ជំហានបន្ទាប់មកទៀតគឺការបង្កើតឡើងនូវអង្គតុលាការមួយ ។ សូមចូលរួមអបអរសាទរ! ខ្ញុំសូមកោតសរសើរចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាអ្នកដឹកនាំ និងឯកឧត្តម សុខ អាន ដែលខំអត់ធ្មត់និងមានសមត្ថភាពដ៏ប្រពៃក្នុងនាមជាប្រធានក្រុមការងារចរចាអំពីបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ការចរចាកន្លងមកពិតជាពិបាកខ្លាំងណាស់ ហើយបានជួបវិបត្តិធ្ងន់ធ្ងរជាច្រើនករណី ។ នៅមុនដំបូងមានទស្សនៈប្រឆាំងអំពីប្រភេទតុលាការ ។ អង្គការសហប្រជាជាតិចង់បង្កើតឡើងនូវតុលាការអន្តរជាតិ ចំណែកឯកម្ពុជាចង់បានតុលាការក្នុងស្រុក ។ នៅខែកក្កដា ឆ្នាំ២០០០ ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងមួយដើម្បីបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញក្រោមច្បាប់កម្ពុជា ដោយមានជំនួយពីចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ ។ ក៏ប៉ុន្តែទន្ទឹករណ៍បេះតែបន្តមានតទៅទៀតរហូតមកដល់ខែកុម្ភៈ ឆ្នាំ២០០២ ភាគីអង្គការសហប្រជាជាតិបានសម្រេចចិត្តឈប់ចរចាមួយរំពេចនិងជាឯកច្ឆ័ន្ទ ។ វាជាការពិបាកណាស់ក្នុងការនាំឲ្យអង្គការសហប្រជាជាតិត្រឡប់មកកាន់តុចរចាវិញ ។ ចំណុចសំខាន់នៃការលំបាកនោះគឺ (មកដល់សព្វថ្ងៃក៏ដូច្នោះដែរ) ការមិនទុកចិត្តគ្នាទៅវិញទៅមករវាងភាគីទាំងសងខាង ។ ភាគីអង្គការសហប្រជាជាតិមិនចង់លាក់បាំងនូវចម្ងល់ទៅលើភាពគួរឲ្យទុកចិត្តបាននៃប្រព័ន្ធច្បាប់និងយុត្តិធម៌របស់កម្ពុជា ចំណែកខាងរដ្ឋាភិបាលកម្ពុជាវិញហាក់ដូចជាមានការអាក់អន់ស្រពន់ចិត្តចំពោះជំហររបស់អង្គការសហប្រជាជាតិ ។ សហគមន៍អន្តរជាតិមានភាពអត់ធ្មត់ក្នុងការជំរុញហើយជំរុញទៀតឲ្យរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិធ្វើឲ្យដំណើរការបេះតែទៅមុខបន្តទៀត ។ ដូច្នេះ តាមរយៈសេចក្តីសម្រេចលេខ ៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានស្នើឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ចាប់ផ្តើមការចរចាជាមួយរដ្ឋា-ភិបាលកម្ពុជា ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមការចរចាជាថ្មីឡើងវិញនៅខែមករា នៅទីក្រុងញូវយ៉ក ហើយបន្តបញ្ចប់កិច្ចព្រមព្រៀងនៅខែមីនា នៅទីក្រុងភ្នំពេញ ។

## ឱកាសដ៏មានតម្លៃសម្រាប់កម្ពុជាបង្ហាញនូវសមត្ថភាពក្នុងការធ្វើឲ្យមានតុលាការដែលអាចទុកចិត្តបាន

ទោះបីជាអង្គការពិភពលោកបានអនុម័តទៅលើអត្ថបទកិច្ចព្រមព្រៀងយល់ព្រមឲ្យភាគីទាំងពីរធ្វើការជាមួយគ្នាក៏ដោយ ក៏លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅតែនិយាយនៅក្នុងរបាយការណ៍របស់ខ្លួន ជម្រាបជូនមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី៣១ ខែមីនា ថា លោកនៅតែមានការព្រួយបារម្ភថា តុលាការជាតិកម្ពុជាមិនអាចធានាបាននូវបទដ្ឋានយុត្តិធម៌ត្រឹមត្រូវតាមច្បាប់ដែលមានលក្ខណៈជាអន្តរជាតិឡើយ (កថាខ័ណ្ឌទី២៨) ។ ជាអកុសល ប្រទេសជាសមាជិកមួយចំនួន

បានចូលរួមកផ្តល់ជាមួយលោកអគ្គលេខាធិការអង្គការសហ-ប្រជាជាតិទៅលើប្រព័ន្ធតុលាការកម្ពុជា ។

ខ្ញុំមានអារម្មណ៍ផ្ទាល់ខ្លួនថា ទោះបីជាប្រព័ន្ធតុលាការរបស់កម្ពុជាមានភាពទន់ខ្សោយយ៉ាងណាក៏ដោយ ប៉ុន្តែកម្ពុជាបាននិងកំពុងតែខិតខំធ្វើឲ្យស្ថានការណ៍នេះកាន់តែប្រសើរឡើង ហើយដោយមានជំនួយពីអ្នកជំនាញការអន្តរជាតិ យន្តការដែលរាក់បញ្ញត្តិរួចហើយនេះនឹងអាចរៀបចំបានត្រឹមត្រូវនូវអង្គជំនុំជម្រះក្តីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលភាគច្រើនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងអំពើឃោរឃៅ ។ ពិភពលោកកំពុងតែឃ្លាំមើលអ្វីនឹងកើតឡើងនាពេលខាងមុខ ។ ក្នុងផ្លូវដែលជាឱកាសដ៏មានតម្លៃរបស់កម្ពុជាដើម្បីបង្ហាញឲ្យពិភពលោកមើលឃើញថា ដោយមានកិច្ចសហប្រតិបត្តិការសហគមន៍អន្តរជាតិអាចរៀបចំចាត់ចែងតុលាការមួយដែលមានបទដ្ឋានអន្តរជាតិ ដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ បទពិសោធន៍ទាំងនេះអាចនឹងជួយធ្វើឲ្យគុណភាពប្រព័ន្ធតុលាការកម្ពុជាមានភាពប្រសើរឡើង ។ សហគមន៍អន្តរជាតិនៅស្ថិតនៅពីក្រោយការខិតខំប្រឹងប្រែងរបស់កម្ពុជា ។

## តុលាការខ្មែរក្រហម និង ប្រទេសជប៉ុន

ខ្ញុំដឹងថា បញ្ហាខ្មែរក្រហមគឺជារឿងដែលពិបាកដោះស្រាយ និងមានលក្ខណៈស្មុគស្មាញសម្រាប់ប្រជាជនកម្ពុជាភាគច្រើន ។ ប្រជាជនស្ទើរតែទាំងអស់ដែលខ្ញុំបានជួប សុទ្ធតែបានឆ្លងកាត់បទពិសោធន៍ជូរចត់ផ្ទាល់ខ្លួននៅសម័យខ្មែរក្រហមជាមួយ (ឬ) ក្រុមគ្រួសារនិងមិត្តភក្តិរបស់គាត់ ។ ទន្ទឹមនឹងនេះដែរ មានប្រជាជនមួយចំនួន ឬក្រុមគ្រួសាររបស់គាត់ អ្នកខ្លះគាំទ្រ អ្នកខ្លះក៏មិនគាំទ្រទៅតាមទំនោរចិត្តរបស់ខ្លួន ។ សុបិនអាក្រក់ និងការប៉ះទង្គិចផ្លូវចិត្តនៅតែដក់ជាប់ក្នុងចិត្តរបស់ប្រជាជនទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿថាភាគច្រើននៃប្រជាជនកម្ពុជាចង់បានយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើរឃោរឃៅប្រព្រឹត្តដោយពួកខ្មែរក្រហម ។ ការស្ទាបស្ទង់មតិកន្លងមកបានបង្ហាញការពិតបែបនេះ ។ មិនតែប៉ុណ្ណោះ ខ្ញុំយល់ទៀតថា ក្រោយពីបានយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះភាពស្មុគស្មាញនិងពិបាកដោះស្រាយនៃបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំមូលដ្ឋានសម្រាប់អនុវត្តការវិនិច្ឆ័យទោសក្នុងស្មារតីបង្រួបបង្រួមផ្សះផ្សាជាតិ ។

ជំហរជាមូលដ្ឋានរបស់រដ្ឋាភិបាលរបស់ខ្ញុំទៅលើបញ្ហាជាពិសេសនេះ គឺគោរពចំពោះឆន្ទៈរបស់រដ្ឋាភិបាលនិងប្រជាជនកម្ពុជា ។ ហេតុដូចនេះ យើងបានគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានព្យាយាមជួយសម្រួលដល់ការចរចាដ៏ពិបាកដែលរាជរដ្ឋាភិបាលបានពុះពារហូតដល់បានសម្រេចនៅទីបញ្ចប់ ។ មកដល់ដំណាក់កាលនេះ ខ្ញុំសូមនិយាយដោយត្រង់ថា ជប៉ុនបានដើរតួនាទីសំខាន់នៅក្នុងបញ្ហានេះដោយមានកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជានិងប្រទេសមួយចំនួនទៀតដែលមានចិត្តដូចគ្នា ដូចជាប្រទេសបារាំងនិងអូស្ត្រាលីជាដើម ។ តាមការពិត ខ្ញុំមានសេចក្តីរីករាយដោយឃើញថាមានប្រទេសមួយចំនួនតូចប៉ុណ្ណោះដែលបានព្យាយាមជួយជ្រោមជ្រែងមិនឲ្យការចរចាប្រែជាបរាជ័យ ។

## តើជប៉ុនបានធ្វើអ្វីខ្លះ? ហេតុអ្វីបានជាជប៉ុនធ្វើដូច្នេះ?

នៅពេលដែលអង្គការសហប្រជាជាតិប្រកាសដកខ្លួនថយឈប់ចរចានោះ ជប៉ុននិងប្រទេសមួយចំនួនទៀតបានព្យាយាមបញ្ចុះបញ្ចូលអង្គការសហប្រជាជាតិត្រឡប់មកកាន់តុចរចាវិញ ។ មានការទាញហេតុផលថា ជាការត្រឹមត្រូវចំពោះការដកថយរបស់អង្គការសហប្រជាជាតិ ហើយប្រទេសមិនតិចឡើយដែលគាំទ្រដល់គំនិតដកថយនេះ ។ ពេលនោះរដ្ឋាភិបាលជប៉ុន ក៏បានចាត់តាំងអ្នកការទូតជាន់ខ្ពស់ដែលមានចំណេះដឹងស៊ីជម្រៅខាងបញ្ហាកម្ពុជានិងអង្គការសហប្រជាជាតិ និងមានទំនាក់ទំនងជាបុគ្គលយ៉ាងជិតស្និទ្ធជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ឲ្យមកគាំទ្រចំពោះដំណើរការនេះ ។ ការទាក់ទងទៅវិញទៅមកខាងការទូតទទួលបានជោគជ័យក្នុងការនាំយកមកវិញនូវការចរចាជាថ្មីរវាងភាគីទាំងពីរ ។ អង្គការសហប្រជាជាតិទាមទារឲ្យមានអាណត្តិថ្មីមួយសម្រាប់បន្តការចរចានេះ ។ ក្នុងសភាពការណ៍បែបនេះមានន័យថា មហាសន្និបាតអង្គការសហប្រជាជាតិត្រូវតែអនុម័តនូវសេចក្តីសម្រេចថ្មីមួយជំរុញឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិចាប់ផ្តើមការចរចាឡើងវិញ ។ ការអនុម័តទៅលើសេចក្តីសម្រេចនោះមិនមែនជារឿងងាយស្រួលទេ ពីព្រោះថាមានមតិសង្ស័យរបស់

ប្រទេសជាសមាជិកជាច្រើនអំពីលទ្ធភាពនិងភាពស្មោះត្រង់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់នូវយុត្តិធម៌មួយដែលអាចជឿទុកចិត្តបាន ។ ជប៉ុនបានដើរតួយ៉ាងសំខាន់ជាមួយប្រទេសបារាំងក្នុងនាមជាអ្នកធានារ៉ាប់រងរួមគ្នាទៅលើសេចក្តីសម្រេចនេះ ។ នៅក្នុងដំណើរការទាំងមូល យើងតែងតែព្យាយាមយ៉ាងខ្លាំងក្នុងការពន្យល់អំពីភាពស្មោះត្រង់របស់រដ្ឋាភិបាលកម្ពុជាចំពោះអង្គការសហប្រជាជាតិ និងប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ហើយនៅពេលជាមួយគ្នានោះដែរ ជប៉ុនបានព្យាយាមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្ហាញជូននូវភាពអាចបត់បែនទៅតាមសភាពជាក់ស្តែង ទាក់ទងនឹងការព្រួយបារម្ភរបស់សហគមន៍អន្តរជាតិ ។ មានការពិគ្រោះពិភាក្សាយ៉ាងគំហុករវាងប្រទេសជប៉ុននិងកម្ពុជា ទាំងនៅទីក្រុងភ្នំពេញនិងនៅទីក្រុងញូវយ៉ក ។ រដ្ឋាភិបាលជប៉ុនបានបង្ហាញជូននូវភាពអាចបត់បែនបានទៅតាមការចាំបាច់ជាក់ស្តែង ។ នៅទីបញ្ចប់ សេចក្តីសម្រេចត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ដោយមានប្រទេសចំនួន ១៥០គាំទ្រ និងគ្មានប្រទេសដែលប្រឆាំង ប៉ុន្តែមានប្រទេស ៣០ដែលអនុបវាទ ។

***សារសំខាន់ជាអន្តរជាតិៈ សមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ***

ជប៉ុនបានធ្វើការយ៉ាងសកម្មដើម្បីសម្រួលដល់ដំណើរការនេះ ដោយមានជំនឿថា នេះគឺជាឆន្ទៈរបស់កម្ពុជាក្នុងការទទួលបាននូវយុត្តិធម៌ទៅលើបញ្ហាខ្មែរក្រហម ។ យើងក៏ជឿទៀតថា ការអនុវត្តបានសម្រេចនូវតុលាការនេះគឺមានប្រយោជន៍ខ្លាំងណាស់ហួសពីកម្រិតជាតិទៅទៀត ។ មិនចាំបាច់និយាយក៏ដឹងដែរថា សម័យខ្មែរក្រហមគឺជាផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។ សហគមន៍អន្តរជាតិបាននិងកំពុងតែផ្តោតការចាប់អារម្មណ៍ចង់ឃើញថាតើបញ្ហានេះត្រូវបានដោះស្រាយដោយរបៀបណាជាមួយប្រជាជនកម្ពុជា ។ វាក៏ជាបញ្ហាសំខាន់ខាងសិទ្ធិមនុស្សដែរ ។ ការអនុវត្តគ្រប់គ្រាន់របស់តុលាការក្រោមច្បាប់កម្ពុជា និងការរកយុត្តិធម៌ប្រកបដោយជោគជ័យនឹងក្លាយជាជំហានដ៏សំខាន់ចាកចេញពីវប្បធម៌និទណ្ឌភាពដែលពេលខ្លះជះឥទ្ធិពលទៅលើទស្សនៈមតិពិភពលោកមកលើកម្ពុជា ។

កាលពីអតីតកាលធ្លាប់មានករណីជាច្រើនទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ។ ប្រទេសកម្ពុជាគឺជាករណីដោយឡែកពោលគឺជាគំរូតុលាការក្នុងស្រុកដែលមានការចូលរួមពីអន្តរជាតិ ។ ជោគជ័យរបស់តុលាការនេះគឺជាគំរូដ៏ល្អសម្រាប់អនាគត ។ សំខាន់ជាងនេះទៅទៀត ការបញ្ចប់ដោយជោគជ័យរបស់តុលាការនេះនឹងជួយជំរុញឲ្យកម្ពុជាឲ្យទៅមុខមួយកម្រិតឆ្ពោះទៅរកសមាហរណកម្មចូលក្នុងសហគមន៍ពិភពលោក ដែលជាធាតុផ្សំដ៏សំខាន់នៃយុទ្ធសាស្ត្រត្រីកោណរបស់ សម្តេច ហ៊ុន សែន ។

ខ្ញុំសូមប្រសិទ្ធិពរជ័យសិរីសួស្តីដល់ប្រជាជននិងរដ្ឋាភិបាលកម្ពុជា ។ **ហ្គោតារ៉ូ អូហ្កាវ៉ា**

## អង្គការឃ្លាំមើលសិទ្ធិមនុស្សចង់ឱ្យមានវិសោធនកម្មទៅលើសេចក្តីព្រាងកិច្ចព្រមព្រៀង

នៅក្នុងសេចក្តីប្រកាសពត៌មានធ្វើឡើងដោយអង្គការឃ្លាំមើលសិទ្ធិមនុស្សនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ម៉ៃ ហ្សង់ជ្រេហ្សិក ប្រធានឃ្លាំមើលសិទ្ធិមនុស្សប្រចាំនៅទីក្រុងវ៉ាស៊ីនតោន ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅអាស៊ីមានប្រសាសន៍ថា "ប្រជាជនកម្ពុជាគួរតែទទួលបាននូវយុត្តិធម៌ដែលមានគំរូបទដ្ឋានអន្តរជាតិក្នុងការកាត់ទោសជនទាំងឡាយដែលមានការទទួលខុសត្រូវ ។ ប្រជាជនកម្ពុជាសមតែដឹងអំពីការពិតថាអ្វីខ្លះបានកើតឡើងហើយកើតឡើងដោយសារហេតុអ្វី" ។ សេចក្តីសង្ខេបនៃសេចក្តីប្រកាសពត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សលើកឡើងអំពីការព្រួយបារម្ភខ្លាចក្រែងរដ្ឋាភិបាលកម្ពុជាធ្វើការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់តុលាការទៅលើច្បាប់កាត់ទោសខ្មែរក្រហមដែលមានលក្ខណៈប្របូកប្របល់ និងមានលក្ខណៈប្រទាំងប្រទើសគ្នា និងការខ្វះនូវផែនការជាក់ស្តែងសម្រាប់ការការពារសាក្សី ជនរងគ្រោះ និង បុគ្គលិកតុលាការ ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ និយាយដោយត្រង់ៗឥតលាក់លៀមទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាថា សមាជិកសំខាន់ៗនៃមហាសន្និបាតអង្គការសហប្រជាជាតិបានដាក់សម្ពាធឲ្យលោកចុះហត្ថលេខាលើសេចក្តីព្រាងនេះ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សជឿថាតុលាការមួយដែលធ្វើតាមគំរូបទដ្ឋានអន្តរជាតិគួរតែគេបង្កើតឡើងតាំងពីច្រើនឆ្នាំមុនម៉្លេះ ប៉ុន្តែដោយសារការបូកផ្សំរវាងនយោបាយក្នុងស្រុកនិងនយោបាយអន្តរជាតិបានរារាំងមិនឲ្យតុលាការមានចរិតបែបនេះលេចចេញជារូបរាងឡើង ។

# ឃើញតែរូបថត



កាលពីខ្ញុំមានអាយុប្រហែល ១២ឆ្នាំ ជារឿយៗខ្ញុំតែងតែឃើញម៉ាក់របស់ខ្ញុំអុជធូបសែននំចំណីនិងម្ហូបអាហារនៅមុខរូបថតបុរសចាស់ម្នាក់រាល់ថ្ងៃសីលនិងថ្ងៃបុណ្យទានផ្សេងៗ ។ ខ្ញុំចេះតែឆ្ងល់ថាមនុស្សនៅក្នុងរូបថតនោះជានរណា ។ ខ្ញុំក៏សួរម៉ាក់អំពីមនុស្សម្នាក់នោះ ។ ម៉ាក់ប្រាប់ថា នោះគឺជាកុងរបស់ខ្ញុំ ។ គាត់ឈ្មោះ ទុយ ជក់ ស្លាប់តាំងពីឆ្នាំ១៩៧៨ម្ល៉េះ ។

ម៉ាក់បាននិយាយរឿងរ៉ាវហូរហែពីការស្លាប់របស់ប្អូនស្រី ឪពុក និងបងថ្លៃប្រុសរបស់គាត់នៅក្រោមរបបខ្មែរក្រហម ។ ជួនកាល ម៉ាក់និយាយប្រាប់ខ្ញុំលាយនឹងសំណើចអំពីអនុស្សាវរីយ៍ល្អៗដែលគាត់ធ្លាប់មានជាមួយអ្នកទាំងបី ។ ពេលខ្លះទៀត ម៉ាក់និយាយទាំងទឹកភ្នែកដោយសារតែការសោកស្តាយចំពោះការបាត់បង់សាច់ញាតិជាទីស្រលាញ់របស់គាត់ ។

ក្នុងរបប លន់ ណុល គ្រួសាររបស់ប៉ានិងម៉ាក់ រស់នៅក្នុងឃុំកំពង់ក្តី ស្រុកជីក្រែង ចម្ងាយប្រមាណ៦០គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប ។ ប៉ាបានប្រាប់ខ្ញុំថា ក្នុងឆ្នាំ១៩៧០ តំបន់មួយចំនួនក្នុងខេត្តសៀមរាប រួមទាំងឃុំកំពង់ក្តី ធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ខ្មែរក្រហមបានហៅតំបន់ទាំងនោះថា តំបន់រំដោះ ។

ចាប់តាំងពីការចូលមកដល់របស់ខ្មែរក្រហម អ្វីៗទាំងអស់នៅក្នុងឃុំបានផ្លាស់ប្តូរ ។ ខ្មែរក្រហមបានហាមប្រាមមិនឲ្យមានការជួញដូរ បំបិទមិនឲ្យមានសាលារៀន មន្ទីរពេទ្យ វត្តអារាម លើកលែងតែក្រដាសប្រាក់ដែលនៅតែបន្តចាយដោយលួចលាក់រហូតដល់ខែមីនាឆ្នាំ១៩៧៥ ។ ដោយសារតែមូលហេតុនេះហើយ ទើបប៉ាម៉ាក់ខ្ញុំនិងបងប្អូនរបស់គាត់ត្រូវបញ្ឈប់ការសិក្សាចាប់តាំងពីពេលនោះ ។ ឪពុកម្តាយជាច្រើនបានរៀបចំទុកដាក់កូនប្រុសស្រីឲ្យមានគូស្រករ ដើម្បីគេចវេះពីការចាប់បង្ខំកូនប្រុសឲ្យធ្វើទាហាន និងការគំរាមកំហែងរបស់កងទ័ពខ្មែរក្រហមមកលើកូនស្រី ។ ដោយឡែក ប៉ានិងម៉ាក់របស់ខ្ញុំពុំទទួលរងនូវការបង្ខំនេះទេ ដោយសារតែមានការព្រមព្រៀងពីសំណាក់ចាស់ទុំតាំងពីពេលមុនមក ។ គាត់ទាំងពីរបានរៀបការតាមប្រពៃណីខ្មែរនាពាក់កណ្តាលឆ្នាំ១៩៧៣ ។ ម៉ាក់បាននិយាយថាបន្ទាប់ពីអាពាហ៍ពិពាហ៍របស់គាត់ កុំថាឡើយរៀបការ សូម្បីតែស្រលាញ់គ្នាក៏ខ្មែរក្រហមមិនឲ្យមានដែរ ។ ខ្មែរក្រហមចាត់ទុកសេចក្តីស្នេហាជាការរំលោភសីលធម៌ ។

ពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានភាពរស់នៅរបស់ប្រជាជនកាន់តែលំបាកឡើង ។ ប្រជាជនមិនអាច ធ្វើដំណើរចេញឬចូលតំបន់រំដោះដោយគ្មានការអនុញ្ញាតពីខ្មែរក្រហមឡើយ ។ ខ្មែរក្រហមចាប់ផ្តើមចម្រាញ់អ្នករកស៊ីធំៗ ជនជាតិបរទេសនិងជនណាដែលត្រូវសង្ស័យថាមានទំនាក់ទំនងជាមួយរដ្ឋាភិបាល លន់ ណុល ។ ខុសពីប៉ា គ្រួសាររបស់ម៉ាក់ជាកូនកាត់ចិន ដូច្នេះទាំងអស់គ្នាដឹងយ៉ាងច្បាស់ថា ខ្មែរក្រហមមិនសូវពេញចិត្តនឹងក្រុមគ្រួសាររបស់គាត់ប៉ុន្មានទេ ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៤ ឪពុកនិងបងថ្លៃប្រុសរបស់ម៉ាក់ឈ្មោះ ហម សេងលី ត្រូវខ្មែរក្រហមហៅទៅ “រៀនសូត្រ” ។ សមាជិកទាំងអស់ក្នុងគ្រួសារដឹងយ៉ាងច្បាស់ថានឹងមានអ្វីកើតឡើងចំពោះអ្នកទាំងពីរ ព្រោះមានមនុស្សជាច្រើនហើយដែលមិនឃើញត្រឡប់មកវិញទាល់តែសោះបន្ទាប់ពីការហៅទៅរៀនសូត្រ ។ ចាប់តាំងពីថ្ងៃនោះមក គ្មាននរណាម្នាក់បានឃើញជីតានិងអ៊ំថ្លៃរបស់ខ្ញុំម្តងទៀតឡើយ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាពេលដែលប្រទេសកម្ពុជាទាំងមូលធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ បន្ទាប់ពីទទួលបាននូវរបបគ្រប់គ្រងថ្មី មនុស្សទាំងអស់ត្រូវជម្លៀសចេញពីទីក្រុងនិងទីប្រជុំជននានា ហើយត្រូវបង្ខំឲ្យទៅរស់នៅតាមទីជនបទដាច់ស្រយាល ។ នៅក្នុងឃុំកំពង់ក្តីដែលជាស្រុកកំណើតរបស់ប៉ានិងម៉ាក់ខ្ញុំ មនុស្សម្នាក៏ត្រូវជម្លៀសចេញ

ដែរ ក្នុងនោះអ៊ីស្រីរបស់ខ្ញុំត្រូវជម្លៀសទៅតំបន់មួយដែលមានឈ្មោះថា ព្រៃឆ្ការ ។ ខ្មែរក្រហមបានចាត់តាំងប្រជាជនខ្លះឲ្យទៅលើកទំនប់ ខ្លះទៀតដកស្ទូងនិងភ្ជួររាស់ស្រែនិងធ្វើការងារធ្ងន់ៗផ្សេងទៀត ។ ប៉ាបានប្រាប់ខ្ញុំថា មនុស្សភាគច្រើនដែលត្រូវជម្លៀសពីកន្លែងមួយទៅកន្លែងមួយ គឺជាជនជាប់និន្នាការ ឬជនដែលខ្មែរក្រហមជឿថា មានការគេស៊ើបលួចលាក់ប្រឆាំងនឹងរបបរបស់ខ្លួន ។ ក្នុងចំណោមប្រជាជនជម្លៀស អ្នកខ្លះក៏ឃើញត្រឡប់មកវិញ ឯអ្នកខ្លះទៀតក៏បាត់រហូត ។ ចាប់តាំងពីឆ្នាំ១៩៧៥ ការបម្រាញ់អ្នកធ្វើការឲ្យរបបមុន សិស្ស និស្សិត និងបញ្ញវន្ត មានសន្ទុះកាន់តែខ្លាំងឡើងៗ ។

ម៉ាក់និងប៉ារបស់ខ្ញុំត្រូវបំបែកឲ្យរស់នៅផ្សេងពីគ្នា ។ ប៉ាខិតខំធ្វើការធ្ងន់ធ្ងរជាងអ្នកដទៃ ។ គាត់មិនដែលហ៊ានជំទាស់នឹងបញ្ជាណាមួយឡើយ ។ ប៉ាមិនដែលស្នើសុំឈប់សម្រាកសូម្បីតែមួយថ្ងៃ លើកលែងតែពេលដែលប៉ាឈឺធ្ងន់ប៉ុណ្ណោះ ។ ហេតុដូច្នេះហើយទើបប៉ាតែងតែរួចខ្លួនពីការយកទៅសម្លាប់ ក្នុងខណៈដែលមិត្តភក្តិជាច្រើនរបស់ប៉ាត្រូវខ្មែរក្រហមសម្លាប់ជាបន្តបន្ទាប់ ។


ឪពុកម្តាយរបស់ ផាត រចនា ក្នុងថ្ងៃរៀបការ

ចំណែកម៉ាក់វិញ ដោយសារថា ម៉ាក់ចេះដេរសម្លៀកបំពាក់ ទើបម៉ាក់ពុំសូវប្រឈមមុខនឹងការអត់អាហារដូចប្រជាជនភាគច្រើននៅក្នុងភូមិ ។ ជាញឹកញាប់ ម៉ាក់តែងតែបានទទួលស្បៀងបន្ថែមពីបណ្តាសមមិត្តនារីដែលធ្វើការក្នុងរោងបាយក្បែររោងកាត់ដេររបស់ម៉ាក់ ។ បងប្អូនទាំងអស់របស់ម៉ាក់សុទ្ធសឹងតែខិតខំធ្វើការឥតសម្រាកដើម្បីរួចជីវិត ។ ម៉ាក់និយាយថា បើប្រៀបធៀបជាមួយគ្រួសារដទៃ ក្រុមគ្រួសាររបស់យើងមានសំណាងណាស់ ព្រោះមានសមាជិកគ្រួសារខ្លះត្រូវខ្មែរក្រហមធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនិងសម្លាប់ចោល ឬស្លាប់ដោយអត់អាហារ ។

ក្នុងឆ្នាំ១៩៧៧ ប្អូនស្រីរបស់ម៉ាក់ឈ្មោះ ទុយ ហាក់មួយ ដែលមានអាយុ១៨ឆ្នាំ បានធ្វើអត្តឃាត ។ ក្រោមអំណាចរបស់ខ្មែរក្រហម ទោះជាការស្លាប់បានក្លាយទៅជារឿងធម្មតាក៏ដោយ ប៉ុន្តែការស្លាប់របស់ប្អូនស្រីម៉ាក់បានធ្វើឲ្យម៉ាក់និងបងប្អូនទាំងអស់មានការឈឺចាប់និងសោកស្តាយជាខ្លាំង ។ រហូតមកដល់បច្ចុប្បន្ននេះ គ្មាននរណាម្នាក់ដឹងច្បាស់អំពីមូលហេតុនៃការធ្វើអត្តឃាតរបស់ប្អូនស្រីម៉ាក់ទេ ។ ក្នុងពេលនោះ ក្រុមគ្រួសារមិនបានរៀបចំធ្វើពិធីបុណ្យសពប្អូនស្រីរបស់ម៉ាក់ឲ្យបានត្រឹមត្រូវតាមប្រពៃណីឡើយ ។ រហូតដល់ក្រោយការដួលរលំនៃរបបខ្មែរក្រហម ទើបម៉ាក់និងបងប្អូនទាំងអស់បានយកឆ្អឹងរបស់ប្អូនស្រីម៉ាក់មកធ្វើបុណ្យតាមប្រពៃណី ។

មិនខុសពីកុងនិងអ៊ីទេ ខ្ញុំបានត្រឹមតែឮឈ្មោះនិងស្គាល់អ៊ី តាមរយៈរូបថតប៉ុណ្ណោះ ។ មកដល់ពេលនេះខ្ញុំមានអាយុ២១ឆ្នាំហើយ ។ រាល់ពេលភ្ជុំបិណ្ឌម្តងៗ ខ្ញុំតែងតែឧទ្ទិសកុសលដល់កុង អ៊ី និង អ៊ីជានិច្ច ។ នៅក្នុងជំនឿរបស់ប្រជាជនខ្មែរ ពេលរដូវភ្ជុំបិណ្ឌយមរាជដោះលែងព្រលឹងទាំងអស់ឲ្យមកទទួលផលានិសង្សពីកូនចៅនិងសាច់ញាតិដែលបានធ្វើឧទ្ទិសឲ្យ ។ ខ្ញុំគិតថា កុង អ៊ី និងអ៊ីរបស់ខ្ញុំពិតជាបានទទួលកុសលផលបុណ្យដែលខ្ញុំបានឧទ្ទិសឲ្យគាត់ជាមិនខាន ។

ប្រសិនបើគ្មានរបបខ្មែរក្រហម ខ្ញុំប្រហែលជាបានស្គាល់មុខមាត់ពិតប្រាកដរបស់ កុង អ៊ី និង អ៊ី ពុំមែនឃើញតែរូបថតដូចពេលនេះទេ ។ ខ្ញុំគិតថា ប្រជាជនខ្មែរទាំងអស់សុទ្ធសឹងតែមានប្រវត្តិផ្សេងៗគ្នាក្រោមរបបប៉ុលពត ហើយមិនមែនមានតែខ្ញុំទេដែលឆ្ងល់ថា ហេតុអ្វីបានជាខ្មែរក្រហមដែលមានឈាមជាខ្មែរ បែរជាសម្លាប់ជាតិឯងដោយគ្មានហេតុផលយ៉ាងនេះ?

**ផាត រចនា**

# សិទ្ធិដែលបាត់បង់



ឆ្នាំនេះខ្ញុំមានអាយុ១៨ឆ្នាំ ហើយ ។ នៅពេលដែលខ្ញុំប្រារព្ធពិធីបុណ្យខួបកំណើត ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយបំផុត ។ ខ្ញុំសប្បាយរីករាយ ពីព្រោះតែខ្ញុំបានទទួលអំណោយខួបកំណើតជាច្រើនពីសំណាក់មិត្តភក្តិ បងប្អូន ឪពុកម្តាយ ហើយអ្នកទាំងអស់ថែមទាំងបានផ្តល់នូវពេលវេលាដ៏មានសេចក្តីសុខសម្រាប់រូបខ្ញុំនាថ្ងៃបុណ្យខួបកំណើតរបស់ខ្ញុំទៀតផង ។ ទន្ទឹមនឹងនេះ ខ្ញុំមានមោទកភាពណាស់ ព្រោះខ្ញុំបានក្លាយជាមនុស្សពេញវ័យ ឯករាជ្យ មានសិទ្ធិបញ្ចេញមតិ ហើយនិងមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតនៅក្នុងប្រទេសរបស់ខ្ញុំ ។ ខ្ញុំពិតជាមានភ័ព្វសំណាងល្អណាស់បើប្រៀបធៀបទៅនឹងសម័យកាល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលខ្មែរក្រហមបានដកហូតសិទ្ធិទាំងអស់ពីឪពុកម្តាយបងប្អូនសាច់ញាតិរបស់ខ្ញុំនិងប្រជាជនកម្ពុជា ។

ប៉ាម៉ាក់បាននិយាយថា “ថ្ងៃណាក៏កូនគិតថា មានសារសំខាន់និងមានន័យដែរ ។ ផ្ទុយទៅវិញ នៅក្នុងរបបខ្មែរក្រហម ម៉ាក់និងប៉ាមិនដែលនឹកនាដល់ថ្ងៃបុណ្យទាំងអស់នោះឡើយ” ។ ដោយការងឿងឆ្ងល់អំពីពាក្យសម្តីប៉ុន្មានម៉ាត់នេះ ខ្ញុំក៏ឆ្លៀតឱកាសសួរប៉ាម៉ាក់នូវរឿងរ៉ាវទាំងអម្បាលម៉ានដែលគាត់ទាំងពីរនាក់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។

ម៉ាក់និយាយប្រាប់ខ្ញុំថា គាត់បានកើតនៅក្នុងត្រកូលអភិជនមួយ ។ ម៉ាក់មានដើមកំណើតនៅស្រុកកៀនស្វាយក្រៅ ខេត្តកណ្តាល ។ ម៉ាក់ជាកូនច្បងបង្អស់ក្នុងចំណោមបងប្អូនប្រាំបីនាក់ដែលស្ថិតនៅក្នុងរង្វង់គ្រួសារអ្នកចេះដឹង ។ លោកតា គឺជានាយកសាលានៅឯស្រុកកោះធំ ខេត្តកណ្តាល ចំណែកលោកយាយជាមេផ្ទះដ៏ល្អមួយរូប ។ ម៉ាក់បានរៀបអាពាហ៍ពិពាហ៍នៅពេលដែលគាត់មានអាយុ២០ឆ្នាំ តាមការផ្សំផ្គុំរបស់ចាស់ទុំនិងសាច់ញាតិបងប្អូន ។ អាពាហ៍ពិពាហ៍របស់លោកទាំងពីរ ប្រារព្ធឡើងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៤ ដោយមានការចូលរួមអបអរសាទរពីសំណាក់ឪពុកម្តាយ សាច់ញាតិ បងប្អូនជិតឆ្ងាយ ។ បន្ទាប់ពីរៀបការរួច ម៉ាក់និងប៉ាក៏ផ្លាស់ទីលំនៅមករស់នៅភ្នំពេញ ម្តុំខាងជើងស្តាតអូឡាំពិក ។ ប៉ាគឺជាអនុប្រធានអង្គការមនុស្សធម៌ទស្សនៈពិភពលោក (WORLD VISION) ទទួលខុសត្រូវខាងការផ្គត់ផ្គង់សម្ភារបរិក្ខារ និងកសាងជំរំជូនជនភៀសខ្លួនតាមខេត្ត-ក្រុង ។ ម៉ាក់គឺជាមេផ្ទះដ៏ចំណាប់ចំណូន ។ លោកទាំងពីររស់នៅជាមួយគ្នាប្រកបដោយសុភមង្គលបំផុត ។

ជាអកុសល ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជា ហើយចាប់ផ្តើមដកហូតកម្មសិទ្ធិទ្រព្យសម្បត្តិ ផ្ទះសម្បែង និងសិទ្ធិសេរីភាពសុភមង្គលពីម៉ាក់និងប៉ាអស់រលីង ។ កងទ័ពខ្មែរក្រហមពីរបីនាក់ស្លៀកពាក់ខោជើងវែងនិងអាវដៃវែងពណ៌ខ្មៅ ព្រមទាំងមានក្រមាពណ៌ក្រហមចងយ៉ាងណែនជុំវិញចង្កេះ ខ្លះទៀតជូតក្បាលក្រមា ប្រដាប់ដោយអាវុធគ្រប់ដៃ បានសម្រុកចូលមកក្នុងលំនៅដ្ឋានរបស់ម៉ាក់និងប៉ានៅម្តុំស្តាតអូឡាំពិក ។ នៅក្នុងខណៈដែលពួកខ្មែរក្រហមកំពុងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហមបានសម្តែងឲ្យឃើញយ៉ាងច្បាស់ក្រឡែតនូវសកម្មភាពដ៏អមនុស្សធម៌ ។ ខ្មែរក្រហមបានគំរាមប្រជាជនឲ្យឆាប់ចុះចេញពីគេហដ្ឋានរបស់ខ្លួនយ៉ាងប្រញាប់ប្រញាល់ ហើយមិនអនុញ្ញាតឲ្យនិយាយស្តី សួរនាំគ្នា ឬក៏មានប្រតិកម្មអ្វីទាំងអស់លើកលែងតែការរៀបចំអីវ៉ាន់របស់ខ្លួនឲ្យឆាប់រួចរាល់ បើពុំនោះសោតនឹងត្រូវបាញ់ឲ្យស្លាប់នៅនឹងកន្លែង ។ ហេតុដូចនេះ ម៉ាក់និងប៉ាក៏ដូចជាប្រជាជនឯទៀតដែរ គិតតែរួតរះរៀបចំអីវ៉ាន់ឲ្យបានឆាប់ន្ទាលនឹងចាកចេញ ព្រោះខ្លាចខ្មែរក្រហមទាំងនោះសម្លាប់ ។ ម៉ាក់និងប៉ាបានធ្វើដំណើរទៅរស់នៅស្រុកកំណើតនៅឯស្រុកកៀនស្វាយក្រៅវិញ ។

នៅរដូវវស្សាឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសម៉ាក់និងប៉ាចេញពីស្រុកកៀនស្វាយក្រៅ ខេត្តកណ្តាល ឲ្យទៅរស់នៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។ មកដល់ទីនេះ អង្គការខ្មែរក្រហមបានផ្តល់នូវផ្ទះឈើធំមួយឲ្យម៉ាក់និងប៉ាស្នាក់នៅជាមួយគ្រួសារកងទ័ពខ្មែរក្រហមពីរ-បីគ្រួសារទៀត ។ ម៉ាក់និងប៉ាត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើស្រែចម្ការយ៉ាងនឿយលំបាកជាទីបំផុត ហើយបានទទួលរបបអង្ករតែមួយកំប៉ុងប៉ុណ្ណោះក្នុងមួយគ្រួសារ សម្រាប់រយៈពេលមួយថ្ងៃ ជាហេតុធ្វើឲ្យរាងកាយរបស់គាត់ស្គមស្គាំងជាខ្លាំង ។ នៅពេលយប់ងងឹត កងឈ្លបមកពួនសម្ងំលួចស្តាប់នៅក្រោមផ្ទះរបស់ប្រជាជន ។ បើប្រជាជនណាមានទិន្នាការផ្ទុយនឹងមាគ៌ារបស់អង្គការ ឬហ៊ាននិយាយអំពីគុណវិបត្តិរបស់អង្គការ នឹងត្រូវយកទៅសម្លាប់ចោលជាមិនខាន ។ ដូច្នេះគ្មាននរណាម្នាក់ហ៊ាននិយាយស្តីអ្វីឡើយ ។

រស់នៅស្រុកព្រះនេត្រព្រះបានរយៈពេលប្រហែលមួយខែ ម៉ាក់និងប៉ាត្រូវអង្គការជម្លៀសពីស្រុកមួយទៅស្រុកមួយគ្មានឈប់ឈរ ។ នៅក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនម៉ាក់និងប៉ាទៅរៀនសូត្រនៅភូមិជប់ នៅក្នុងឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្ននៅក្នុងខេត្តបន្ទាយមានជ័យ) អស់រយៈពេល៥ថ្ងៃ ។ ទោះជាគោលនយោបាយដែលខ្មែរក្រហមបានបង្រៀនសុទ្ធតែមានលក្ខណៈផ្ទុយពីឆន្ទៈរបស់គាត់ទាំងពីរ ក៏ដោយក៏ម៉ាក់និងប៉ាមិនដែលហ៊ានសម្តែងនូវអាការៈមិនពេញចិត្តចំពោះប្រការណាមួយឡើយ ។ គាត់ខំសម្តែងនូវការលើកតម្កើង ស្ងើចសរសើរ ទះដៃអបអរសាទរចំពោះអង្គការជាដរាប ដើម្បីបានរួចពីសេចក្តីស្លាប់ ។

នៅដើមខែវស្សាឆ្នាំ១៩៧៦ ប៉ាត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅគោកតាយូ ខេត្តបន្ទាយមានជ័យ ។ ចំណែកម៉ាក់ត្រូវអង្គការយកទៅដាក់គុកអស់រយៈពេល៣ខែ ដោយគ្មានបញ្ជាក់ហេតុផលថាម៉ាក់បានប្រព្រឹត្តអ្វីខុសឡើយ ។ មុនដំបូងម៉ាក់ត្រូវជាប់ឃុំនៅក្នុងគុកស្រុកសេរីសោភ័ណ ។ ម៉ាក់ត្រូវឈ្លបដាក់ច្រវាក់ជើងមិនអាចដើរទៅណាមកណាបាន ។ សុខភាពរបស់ម៉ាក់ស្រុតចុះដោយសារតែបរិយាកាសកខ្វក់និងអាប់អួនៅក្នុងគុក ។ ក្នុងរយៈពេលពេញមួយខែ ខ្មែរក្រហមអនុញ្ញាតឲ្យអ្នកទោសងូតទឹកសម្អាតខ្លួនតែម្តងគត់ ។ ម៉ាក់បានទទួលរបបអាហារតែបាយមួយចានចង្កឹះ និងអំបិលពីរបីគ្រាប់ប៉ុណ្ណោះ ។



នង ខត្តតារា និងក្រុមគ្រួសារ ក្នុងឆ្នាំ១៩៩៨

ម៉ាក់រស់នៅក្នុងសភាពអត់ឃ្លានខ្លាំងណាស់ ។ ម៉ាក់ត្រូវខ្មែរក្រហមហៅទៅសួរចម្លើយម្តងហើយម្តងទៀត ។ អ្នកសួរចម្លើយរបស់ខ្មែរក្រហមសួរម៉ាក់តែសំណួរដដែលៗគឺ តើមានជាប់ទាក់ទងនឹងអ្នកនយោបាយសំខាន់ៗឬក៏ភ្នាក់ងារសេ.អ៊ី.អាកា.ហ្សេ.បេ ណាម្នាក់ឬទេ? រាល់លើក ម៉ាក់តែងតែឆ្លើយដោយសម្តីសុភាពរាបសាទន់ភ្លន់ថា គាត់មិនដែលមានជាប់ទាក់ទងនឹងអ្នកទាំងនោះឡើយ គាត់គ្រាន់តែជាស្ត្រីសាមញ្ញម្នាក់ប៉ុណ្ណោះ ។

នៅអំឡុងខែកក្កដា ឬសីហា ឆ្នាំ១៩៧៦ ម៉ាក់ក៏ត្រូវខ្មែរក្រហមបញ្ជូនទៅដាក់គុកនៅកន្លែងផ្សេងមួយទៀតដែលមានលក្ខណៈធូរស្រាលជាងមុន ។ នៅទីនេះខ្មែរក្រហមមិនដាក់ច្រវាក់ជើងម៉ាក់ទេ ហើយម៉ាក់បានទទួលរបបចំណីអាហារគ្រប់គ្រាន់ ។ ទោះជាយ៉ាងនេះក្តី ក៏ម៉ាក់និងស្ត្រីឯទៀតមានការភ័យខ្លាចខ្លាំងណាស់ ព្រោះមានស្ត្រីមួយចំនួនដែលជាប់និន្នាការជាមួយរបបលន់ ណុល ត្រូវទាហានខ្មែរក្រហមយកទៅសួរចម្លើយនិងធ្វើទារុណកម្មរហូតដល់ស្លាប់ក៏សឹងមាន ។ ស្ត្រីមួយចំនួនបានធ្វើអត្តឃាតដោយសារតែមិនអាចទ្រាំទ្រនូវការធ្វើទារុណកម្មបាន ។ ម៉ាក់បាននិយាយថា រយៈពេលដែលនៅក្នុងគុកគឺជារយៈពេលដែលមានសភាពអាប់អួនិងភ័យរន្ធត់ជាទីបំផុត ។ រហូតមកដល់ពេលនេះ ម៉ាក់នៅតែមិនដឹងថាខ្លួនគាត់បានធ្វើអ្វីខុសទើបត្រូវខ្មែរក្រហមយកទៅដាក់គុក ។

ប្រហែលនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៦ ម៉ាក់ត្រូវបានដោះលែងឲ្យមករស់នៅជាមួយប៉ានៅគោកតាយូវិញ ។ ម៉ាក់ប្រាប់ថា គាត់ពិតជាមានការសង្វេគចំពោះប៉ាខ្លាំងណាស់ ព្រោះប៉ាក្អកធ្លាក់ឈាម និងមានរាងកាយទ្រុឌទ្រោមយ៉ាងខ្លាំង ។ ម៉ាក់និងប៉ាខិតខំប្រឹងប្រែងធ្វើការងារបម្រើអង្គការ ដោយក្នុងចិត្តសង្ឃឹមថានឹងមានសំណាងរួចផុតពីសេចក្តីស្លាប់ ជាងនេះទៅទៀតគាត់ក៏សង្ឃឹមថារបបនេះនឹងផុតរលត់ទៅយ៉ាងឆាប់រហ័ស ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ម៉ាក់បានផ្តល់កំណើតបងស្រីច្បងរបស់ខ្ញុំ ។ ម៉ាក់ពិតជាមិនដឹងថាតើកំណើតកូនស្រីដំបូងរបស់គាត់ម្នាក់នេះធ្វើឲ្យគាត់សប្បាយចិត្តឬក៏សោកសង្រេងឡើយ ពីព្រោះមានទារកនិងកុមារជាច្រើនបានស្លាប់ដោយសារការអត់ឃ្លាន ។ អង្គការមិនចែករបបអង្ករឬម្ហូបចំណីអ្វីបន្ថែមឲ្យប្រជាជនទេ ។ កសិផលដែលប្រជាជនខិតខំព្យាយាមធ្វើជូនអង្គការរយៈពេលកន្លងទៅ មិនឃើញប្រជាជនណាម្នាក់បានទទួលនូវចំណែកស្បៀងឲ្យស័ក្តិសមនឹងការងាររបស់ខ្លួនឡើយ ។ មនុស្សជាច្រើនបានស្លាប់ដោយសារជំងឺនិងភាពអត់ឃ្លាន ។ ប៉ាមានជំងឺហើមដោយសារខ្វះជាតិអំបិល ចំណែកបងស្រីច្បងរបស់ខ្ញុំដែលទើបតែមានអាយុប្រាំខែនោះ កើតជំងឺប៉េស្ត ។ ប្រជាជនម្នាក់ៗមានរូបរាងដូចគ្រោងឆ្អឹង គ្មានសភាពពេញលេញជាមនុស្សឡើយ ។ ប្រជាជនបរិភោគអ្វីដែលជាតិជាមនុស្សមិនគួរបរិភោគ ដូចជា សត្វកណ្តូប ជីងចក់ ដង្កូវ កណ្តុរជាដើម ។ រុក្ខជាតិដែលមានស្លឹកជាប់ដោយបន្ទាមុតស្រួចក៏មនុស្សស៊ូទ្រាំបេះយកមកបរិភោគដែរ ។ មនុស្សជាច្រើនបានស្លាប់ដោយពុលចំណីអាហារ ។ ដោយទ្រាំនូវការលំបាកវេទនា នេះស្ទើរតែពុំបានប៉ាបានបបួលម៉ាក់លួចរត់ជាច្រើនលើកច្រើនសា ប៉ុន្តែម៉ាក់បានបដិសេធរាល់លើក ។ នៅក្នុងភូមិដែលម៉ាក់និងប៉ារស់នៅ ខ្មែរក្រហមបានសម្លាប់ប្រជាជនណាដែលព្យាយាមលួចរត់ ។ ម៉ាក់យល់ថា ពេលនេះជាពេល “ចុះទឹកជួបក្រពើ ឡើងលើជួបខ្លា” ទើបម៉ាក់សម្រេចចិត្តតស៊ូរស់នៅក្នុងគុកឥតជញ្ជាំងនេះតទៅទៀត ។

អស់រយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ម៉ាក់និងប៉ាក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ ត្រូវរស់នៅក្នុងភាពអន្ធការ ត្រូវខ្មែរក្រហមដកហូតសិទ្ធិសេរីភាពគ្រប់យ៉ាងរលីងពីខ្លួន សូម្បីតែសិទ្ធិរស់រានមានជីវិតក៏គ្មានដែរ ។ តើគាត់ទាំងអស់មានពេលវេលាឯណាដើម្បីនឹកគិតដល់ថ្ងៃបុណ្យសំខាន់ផ្សេងៗរបស់ជាតិនិងអន្តរជាតិដូចក្មេងៗជំនាន់ខ្ញុំសម័យនេះ?

**ឆង ឧត្តរា**

# សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# មិនមែនជាគំនិតចងអាឃាតទេ

ខ្ញុំបាទឈ្មោះ អ៊ាន ធិន កើតនៅថ្ងៃទី១១ កញ្ញា ១៩៥២ នៅភូមិអន្ទង់ឃ្វាំង ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។

សូមគោរពចំពោះលោក ឆាំង យុ នាយកការផ្សាយទស្សនាវដ្ដីស្វែងរកការពិត ព្រមទាំងសហការីទាំងអស់ ជាទីស្រលាញ់ ។ ខ្ញុំបាទបានអានទស្សនាវដ្ដីនេះជាច្រើនឆ្នាំហើយ ព្រោះវាត្រូវនឹងចំណង់ចិត្តរបស់ខ្ញុំបាទដែលជាជនរងគ្រោះនៅក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតនេះ ឪពុកខ្ញុំបាទឈ្មោះ អ៊ាន ឌិត ត្រូវគេចាប់យកទៅសម្លាប់នៅទួលភ្លងក្នុងស្រុកស្ទោង ។ ឪពុកមាឈ្មោះ អ៊ាន ឌឹម ត្រូវចាប់សម្លាប់នៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប រួមទាំងប្អូនស្រីម្នាក់ទៀតឈ្មោះ អ៊ាន នីលវណ្ណា (ជានារី) ។ ថ្មីៗនេះ ខ្ញុំបាទបានជួបក្រុមការងារដើរស្រាវជ្រាវរបស់ទស្សនាវដ្ដីស្វែងរកការពិតពីថ្ងៃទី ៦-០៣-២០០៣ បានដំណឹងថា ឪពុកមាខ្ញុំបាទឈ្មោះ ស៊ឹ ឆេងហួត ភេទប្រុស ដែលគាត់មានឋានៈជាវិស្វករអគ្គិសនីពីសង្គមសម្ដេច សីហនុ បានត្រូវគេចាប់កាលពីថ្ងៃ១២-១២-១៩៧៥ ធ្វើឲ្យខ្ញុំបាទរឹតតែមានចិត្តសង្វេគកាន់តែខ្លាំង ចង់ជំរុញឲ្យមានការកាត់ទោសអ្នកទទួលខុសត្រូវ នោះកាន់តែឆាប់ដើម្បីជម្នះនូវទម្លាប់រួចទោសរបស់អ្នកទទួលខុសត្រូវ នេះមិនមែនជាគំនិតចងអាឃាតទេ តែជាអនុសាសន៍សម្រាប់ថ្នាក់ដឹកនាំជំនាន់ក្រោយ ជៀសវាងកំហុសឆ្គងដែលធ្វើឲ្យអន្តរាយមនុស្សជាតិ ។ ពេលខ្ញុំបាទនឹកឃើញអតីតកាល ស្ដាយយុវភាពដែលបានកប់នៅក្នុងភពងងឹត ខ្ញុំស្រក់ទឹកភ្នែករាប់មិនអស់ មិនដឹងជារកពាក្យអ្វីមកប្រៀបស្មើទំហំទុក្ខវេទនា ការព្រាត់ប្រាសមិត្តភក្ដិ ឪពុកម្ដាយបងប្អូនលោកគ្រូអ្នកគ្រូជាទីគោរព ។ ជាចុងក្រោយ ខ្ញុំបាទសូមជូនពរដល់លោកប្រធាន ឆាំង យុ ព្រមទាំងសហការីទាំងអស់របស់ទស្សនាវដ្ដី "ស្វែងរកការពិត" សម្រេចបានគោលដៅជាចុងក្រោយមួយរយភាគរយ ។ មួយវិញទៀត ក្នុងនាមខ្ញុំបាទផ្ទាល់ដែលជានាយកអនុវិទ្យាល័យប្រឡាយ សូមលោកនាយកមេត្តាផ្ដល់ទស្សនាវដ្ដី "ស្វែងរកការពិត" យកមកដាក់ក្នុងបណ្ណាល័យសាលាខ្ញុំបាទដោយអនុគ្រោះ ។

ប្រឡាយ ថ្ងៃទី ៧-០៣-២០០៣, នាយកសាលា, អ៊ាន ធិន





ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 41, May 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**